World Vision

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
Working Together for Positive Change

# ការធ្វៀលសហគមន៍ក្រីក្រចេញពីការចុះបញ្ជីដីធ្លី លក្ខណៈជាប្រព័ន្ធ ក្នុងរាជធានីភ្នំពេញ



ភ្នំពេញ កម្ពុជា
ខែមករា ឆ្នាំ ២០១៥

# ការផ្លៀសហគមន៍ក្រីក្រចេញពីការចុះបញ្ជីដីធ្លី លក្ខណៈជាប្រព័ន្ធ ក្នុងរាជធានីភ្នំពេញ

កាលបរិច្ឆេទបោះពុម្ពផ្សាយ៖ ខែមករា ឆ្នាំ២០១៥
បោះពុម្ពផ្សាយដោយ៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា
ស្រាវជ្រាវដោយ៖ កែវ ចិន្ដា Thierry Bouhours និង Brigitte Bouhours
សម្របសម្រួលការស្រាវជ្រាវដោយ៖ លោកស្រី សៅ វិច្ឆិកា មន្ត្រីស្រាវជ្រាវ
រចនាអត្ថបទដោយ៖ លោក ភួន យូ មន្ត្រីព័ត៌មាន និងការបោះពុម្ពផ្សាយ

## សេចក្ដីបញ្ជាក់៖

ទស្សនៈបង្ហាញក្នុងរបាយការណ៍នេះសុទ្ធតែជាទស្សនៈរបស់អ្នកនិពន្ធ ហើយមិនបង្ហាញពីទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជាទេ។ នៅពេលខ្លឹមសារនៃរបាយការណ៍នេះត្រូវគេដកស្រង់ ឬផលិតសារជាថ្មី ការទទួលស្គាល់ និងការសុំអនុញ្ញាតសិទ្ធិរបស់អ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយនឹងត្រូវគេអោយតម្លៃ។

© **វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា**, **ខែមករា ឆ្នាំ២០១៥**

# សេចក្តីថ្លែងអំណរគុណ

ក្រុមសិក្សាស្រាវជ្រាវ សូមសម្តែងនូវសេចក្តីដឹងគុណដ៏ជ្រាលជ្រៅចំពោះប្រជាជនដែលរស់នៅក្នុងសហគមន៍ក្រីក្រទាំង១២ ក្នុងទីក្រុងភ្នំពេញ ដែលស្ថិតនៅក្នុងការសិក្សានេះដែលបានចូលរួមក្នុងការឆ្លើយនឹងសំណួរនានា ក៏ដូចជារៀបរាប់នូវរឿងរ៉ាវរបស់ខ្លួនសម្រាប់ការសិក្សាស្រាវជ្រាវនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណផងដែរ ដល់ជំនួយការក្នុងការស្រាវជ្រាវរួមមាន អ្នកស្រី សរ សុភាព និង លោក ជួប សេរីវឌ្ឍនា ដែលបានចុះផ្ទាល់ប្រមូលព័ត៌មានជាមួយសហគមន៍។

យើងខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេសដល់មេភូមិ មេឃុំ អ្នកតំណាងឃុំ និងមន្ត្រីរាជរដ្ឋាភិបាល ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងការសម្ភាស សម្រាប់ការស្រាវជ្រាវនេះ។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងអង្គការទស្សនៈពិភពលោកកម្ពុជា ដែលបានផ្តួចផ្តើម និងជួយឧបត្ថម្ភឲ្យមានការស្រាវជ្រាវនេះកើតឡើង។ ជាពិសេសសូមអរគុណដល់មន្ត្រីចំនួនពីររូបនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (លោក ជា សារុំ និង លោកស្រី សៅ វិច្ឆិកា) ដែលបានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយនឹងក្រុមការងារស្រាវជ្រាវ និងបានផ្តល់នូវជំនួយបច្ចេកទេសនានាដ៏មានប្រយោជន៍ក្នុងកំឡុងពេលសិក្សាស្រាវជ្រាវ។

# មាតិកា


សេចក្តីសង្ខេប......iii
ពាក្យកាត់......vii
និយមន័យនៃពាក្យគន្លឹះ......viii

**I. សេចក្តីផ្តើម......១**
១.១ គោលបំណង និងកម្មវត្ថុ......៤
១.២ សំណួរស្រាវជ្រាវ......៤

**II. វិធីសាស្ត្រ......៥**
២.១ ការជ្រើសរើសទីតាំងសិក្សា......៦
២.២ វិធីសាស្ត្រប្រមូលទិន្នន័យ និងការជ្រើសរើសសំណាកគំរូ......៧
២.៣ ការវិភាគទិន្នន័យ......៩
២.៤ ដែនកំណត់ និងកត្តាប្រឈម......៩

**III. ការសិក្សាឯកសារដែលមានស្រាប់......១១**
៣.១ កម្មសិទ្ធិដីធ្លីនៅកម្ពុជា......១២
៣.១.១ ប្រវត្តិនៃកម្មសិទ្ធិដីធ្លី......១២
៣.១.២ ក្របខណ្ឌច្បាប់បច្ចុប្បន្ន......១៣
៣.២ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ......១៤
៣.២.១ គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីនិងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ......១៤
៣.២.២ ប័ណ្ណកម្មសិទ្ធិដីធ្លីនៅភ្នំពេញ......១៦
៣.២.៣ ដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងដែនកំណត់របស់វា......២០
៣.៣ សហគមន៍ក្រីក្រនៅរាជធានីភ្នំពេញ......២៥
៣.៤ ការបណ្តេញចេញ និងការបន្លាស់ទី......២៨

**IV. លទ្ធផលនៃការស្រាវជ្រាវ......៣១**
៤.១ ព័ត៌មាននៃសហគមន៍ទាំង ១២ នៅក្នុងការសិក្សា......៣២
៤.១.១ សហគមន៍ថៅពញាហុក សង្កាត់បឹងកេងកង ខណ្ឌចំការមន......៣២

៤.១.២ សហគមន៍បឹងត្របែក សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន............៣៣
៤.១.៣ សហគមន៍ភូមិអ្នកតា សង្កាត់ជើងឯក ខណ្ឌដង្កោ........................៣៣
៤.១.៤ សហគមន៍ចេក សង្កាត់ជើងឯក ខណ្ឌដង្កោ...................................៣៤
៤.១.៥ សហគមន៍ផ្លូវរថភ្លើង សង្កាត់ស្រះចក ខណ្ឌដូនពេញ...................៣៥
៤.១.៦ ប្លុកតាន់ប៉ា សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ...................................៣៦
៤.១.៧ សហគមន៍ព្រែកតានូ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ......៣៧
៤.១.៨ សហគមន៍ថ្មសាន សង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ.....................៣៧
៤.១.៩ សហគមន៍ទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ..........................៣៨
៤.១.១០ សហគមន៍បុរី ១០០ ខ្នង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ..............៣៩
៤.១.១១ សហគមន៍ ១០២ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក.................៤០
៤.១.១២ សហគមន៍ ៣៤៧ សង្កាត់បឹងកក់ ១ ខណ្ឌទួលគោក................៤១
៤.២ ការទទួលបានសេវាសាធារណៈ..........................................................៤២
៤.៣ ព័ត៌មានសេដ្ឋកិច្ចសង្គមនៃគ្រួសារក្នុងសហគមន៍ក្រីក្រនៅទីក្រុង..........៤៣
៤.៤ ប្រភេទដីដែលសហគមន៍ក្រីក្រតាំងទីលំនៅ និងមូលហេតុនៃការ ផ្ទៀលចេញ........................................................................................៤៧
៤.៥ ការយល់ដឹងរបស់ប្រជាជនស្តីពីការផ្ទៀលចេញពីការចុះបញ្ជីដីធ្លីមាន លក្ខណៈជាប្រព័ន្ធ..............................................................................៤៩
៤.៦ ការយល់ច្រឡំអំពីភស្តុតាងនៃសិទ្ធិកាន់កាប់........................................៥២
៤.៧ ផែនការបណ្តេញចេញ.......................................................................៥៣
៤.៨ ផលប៉ះពាល់នៃការផ្ទៀលចេញ..........................................................៥៤
៤.៨.១ ការភ័យខ្លាច និង ក្តីកង្វល់..........................................................៥៦
៤.៨.២ ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គម................................................៦០
៤.៨.៣ ការលំបាកក្នុងការលក់ដូរអចលនទ្រព្យ.......................................៦១
៤.៨.៤ ការរើសអើង និងការមិនរាប់អានពីសង្គម......................................៦១
៤.៩ កិច្ចខិតខំប្រឹងប្រែងដើម្បីទទួលបានប្លង់រឹង.........................................៦២
៤.១០ ការរំពឹងទុក និងដំណោះស្រាយ.......................................................៦៤

**V. ការពិភាក្សា និងសេចក្តីសន្និដ្ឋាន និងអនុសាសន៍..................................៦៧**
៥.១ ការពិភាក្សា និងសេចក្តីសន្និដ្ឋាន.........................................................៦៨
៥.២ អនុសាសន៍....................................................................................៧១
**ឯកសារយោង.......................................................................................៧៥**
**ឧបសម្ព័ន្ធ..........................................................................................៧៧**
ឧបសម្ព័ន្ធ A ៖ ផែនទីនៃទីតាំងសហគមន៍ក្រីក្រនៅទីក្រុងដែលបានជ្រើសរើស..៧៧
ឧបសម្ព័ន្ធ B ៖ កម្រងសំណួរ.......................................................................៧៨

# សេចក្តីសង្ខេប

ការធានាបាននូវសិទ្ធិកាន់កាប់ដីធ្លី នៅតែជាក្តីបារម្ភដ៏ធំធេងសម្រាប់ប្រជាជនខ្មែរជាច្រើនដែលពុំមានប័ណ្ណកម្មសិទ្ធិជាផ្លូវការ លើអចលនទ្រព្យដែលពួកគាត់បានស្នាក់នៅជាច្រើនឆ្នាំមកហើយនោះ។ នៅក្នុងឆ្នាំ ២០០១ ច្បាប់ភូមិបាលថ្មីបានបង្កើតឡើង ហើយរាជរដ្ឋាភិបាលកម្ពុជា បានខិតខំរៀបចំឡើងវិញនូវគម្រោងកម្មសិទ្ធិដីធ្លីស្របច្បាប់ព្រមទាំងបានបង្កើតហេដ្ឋារចនាសម្ព័ន្ធរដ្ឋបាលដីធ្លីផងដែរ។ នៅឆ្នាំ ២០០២ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតនូវគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីដែលមានទ្រង់ទ្រាយធំ (LMAP) ហើយស្ថិតនៅក្រោមក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ដោយមានការឧបត្ថម្ភពីម្ចាស់ជំនួយនានា។ គោលបំណងជារួមនៃកម្មវិធីនេះគឺបង្កើននូវសុវត្ថិភាពដីធ្លី កាត់បន្ថយ និងជៀសវាងជម្លោះដីធ្លីព្រមទាំងជួយជម្រុញដល់ការអភិវឌ្ឍ និងកាត់បន្ថយភាពក្រីក្រ។ សមាសភាគសំខាន់នៃគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីនេះ គឺការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដែលសំដៅដល់ទៅការចេញប័ណ្ណកម្មសិទ្ធិឲ្យរាល់ប្លង់ដីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ស្របពេលដែលកម្មវិធីនេះបានបង្ហាញភាពជោគជ័យយ៉ាងធំធេងនៅតាមបណ្តាជនបទ សហគមន៍ក្រីក្រជាច្រើននៅរាជធានីភ្នំពេញត្រូវបានផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះ ទោះបីជាមានភស្តុតាងនៃសិទ្ធិកាន់កាប់យ៉ាងណាក្តី។ មិនតែប៉ុណ្ណោះ ក៏ពុំមានការបកស្រាយជាផ្លូវការអំពីការផ្លៀលចេញពីការចុះបញ្ជីនេះដែរ។ មានមតិជាច្រើនបានលើកឡើងថា ការវិវត្តដ៏ឃើតយ៉ាវនៃការចុះបញ្ជីដីធ្លីនេះ ភាគច្រើនបណ្តាលមកពីមានការផ្លៀលចេញដ៏សម្បើមពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិនៅក្នុងទីប្រជុំជន ដែលពោរពេញដោយអចលនទ្រព្យមានតម្លៃខ្ពស់ និងទំនងជាបង្កអោយមានជម្លោះកើតឡើង។ បញ្ហាទាំងនេះមានលក្ខណៈធ្ងន់ធ្ងរចំពោះសហគមន៍ក្រីក្រនៅក្នុងទីប្រជុំជន ដែលមានករណីជាច្រើនដែលបង្ករអោយមានការបណ្តេញចេញដោយបង្ខំ ត្រូវបានកត់ត្រា។ អង្គការទស្សនៈពិភពលោកកម្ពុជា (WVC) និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF) បានផ្តួចផ្តើមរួមគ្នាបង្កើតឲ្យមានការសិក្សាស្រាវជ្រាវមួយដើម្បីស្វែងយល់អំពីមូលហេតុដែលរាជរដ្ឋាភិបាលផ្លៀលសហគមន៍ក្រីក្រជាច្រើន នៅរាជធានីភ្នំពេញចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងផលប៉ះពាល់នានានៃ

ការផ្លៀលចេញនេះទៅលើគ្រួសារនានាក្នុងសហគមន៍ក្រីក្រ ជាពិសេសលើស្ត្រី និងកុមារ។

ការសិក្សានេះ បានធ្វើឡើងនៅក្នុងសហគមន៍ក្រីក្រនៅទីប្រជុំជនចំនួន ១២ ដែលត្រូវបានផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ នៅក្នុងខណ្ឌចំនួន ៦ ដែលដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធបានបញ្ចប់ ឬជិតបានបញ្ចប់។ វិធីសាស្ត្រប្រមូលទិន្នន័យ គឺរួមបញ្ចូលទាំងការសម្ភាសជាមួយប្រជាជនចំនួន ៦០គ្រួសារ ដែលត្រូវបានគេផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ជាមួយមេភូមិ អ្នកតំណាងឃុំ មន្ត្រីរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។ ការវិភាគទិន្នន័យរួមមានការវិភាគបែបបរិមាណ និងគុណភាព ហើយស្វែងរកមូលហេតុនៃការផ្លៀលចេញ ព្រមទាំងផលប៉ះពាល់លើសេដ្ឋកិច្ចសង្គមរបស់គ្រួសារដែលត្រូវបានផ្លៀលចេញ។ ទិន្នន័យបន្ទាប់បន្សំដែលបានពីការសិក្សាលើឯកសារដែលមានស្រាប់មានសារៈសំខាន់ជាខ្លាំងក្នុងការផ្ទៀងផ្ទាត់ និងបំពេញបន្ថែមទៅលើទិន្នន័យបឋមរបស់ការសិក្សានេះ។

សហគមន៍ក្រីក្រទាំង ១២ នៅក្នុងការសិក្សានេះ បានប្រើប្រាស់អគ្គិសនីរបស់រដ្ឋ ក្នុងនោះសហគមន៍ចំនួន ១១ មានទឹកស្អាតប្រើប្រាស់ សហគមន៍ចំនួន៦ មានប្រព័ន្ធលូបង្ហូរទឹក និងសហគមន៍ចំនួន ៤ ប៉ុណ្ណោះ ទទួលបានសេវាប្រមូលសំរាម។ ក្នុងចំណោមសំណាកគំរូទាំង ៦០គ្រួសារ ដែលបានជ្រើសរើសសម្រាប់ការសិក្សានេះ មានសមាជិកក្នុងគ្រួសារសរុបចំនួន ៣៦០ នាក់ ដែលក្នុងនោះមាន ៥៣% ជាកុមារ។ គ្រួសារនីមួយៗជាមធ្យមមានសមាជិកចំនួន ៦នាក់។ ភាគច្រើននៃអ្នកដែលរស់នៅក្នុងសហគមន៍ក្រីក្រទាំងនោះ ជាអ្នកធ្វើការងារដែលទទួលបានប្រាក់កម្រៃទាប ដូចជា អ្នកលក់ដូរតាមចិញ្ចើមផ្លូវ អ្នកនេសាទត្រី អ្នកលក់ដូរចាប់ហ៊ួយតូចតាច អ្នករត់ម៉ូតូឌុប ឬរត់តាក់ស៊ី។ គ្រួសារដែលបានចូលរួមក្នុងការសម្ភាស ជាទូទៅមានជីវភាពក្រីក្រជាងគ្រួសារទូទៅនៅរាជធានីភ្នំពេញ។ ពួកគាត់ច្រើនតែមានកូនច្រើនដែលជាបន្ទុកធ្ងន់ធ្ងរដល់បញ្ហាថវិកាគ្រួសារ។ កូនៗរបស់គាត់មួយចំនួនបានបោះបង់ចោលការសិក្សាដោយសារតែភាពក្រីក្រ។ ជាមួយគ្នានេះដែរ មានសមាជិកគ្រួសារខ្លះបានធ្លាក់ខ្លួនឈឺរ៉ាំរ៉ៃ ត្រូវការការថែទាំព្យាបាលដែលជាការបន្ថែមបន្ទុកលើគ្រួសារ។ គ្រួសារភាគច្រើនជំពាក់បំណុលគេ ហើយមិនមានប័ណ្ណកម្មសិទ្ធិដីធ្លី ដែលជាហេតុធ្វើអោយពួកគាត់មិនមានលទ្ធភាពខ្ចីប្រាក់ពីធនាគារ

តែផ្ទុយទៅវិញបានពឹងផ្អែកទៅលើការខ្ចីបុលពីអ្នកចងការប្រាក់ឯកជន ដែលមានការប្រាក់ខ្ពស់។

សហគមន៍ក្រីក្រចំនួន ១១ រស់នៅលើដីសាធារណៈរបស់រដ្ឋ (ឧ. តាមចិញ្ចើមផ្លូវរថភ្លើង តាមចិញ្ចើមផ្លូវដើរ)។ មានតែអ្នកចូលរួមក្នុងការសម្ភាសប្រមាណពាក់កណ្តាលប៉ុណ្ណោះ ដែលបានដឹងថាផ្ទះរបស់ខ្លួនបានសាងសង់លើដីសាធារណៈរបស់រដ្ឋ។ ប៉ុន្តែអ្នកខ្លះបានគិតថា គ្រួសារគាត់រស់នៅលើដីឯកជនដោយសារតែគ្រួសារពួកគាត់បានមករស់នៅលើដីនោះមុនពេលមានច្បាប់ភូមិបាល ឬបានទិញដីនោះពីម្ចាស់មុនមក។ សហគមន៍ក្រីក្រចំនួន ១០ ក្នុងចំណោម ១២ សហគមន៍ ត្រូវបានគេប្រាប់យ៉ាងជាក់លាក់ថា សហគមន៍របស់ពួកគាត់ត្រូវបានផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ក៏ប៉ុន្តែមានតែពាក់កណ្តាលនៃគ្រួសារទាំងនោះត្រូវបានគេផ្តល់ដំណឹងអំពីមូលហេតុនៃការផ្លៀលចេញនេះ។ មានគ្រួសារជាច្រើនរួមទាំងអាជ្ញាធរមូលដ្ឋានផងដែរ ខ្វះខាតការយល់ដឹង និងមិនយល់អំពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ ពួកគេថែមទាំងមិនយល់ថាអ្វីខ្លះដែលអាចបញ្ជាក់បាននូវភាពជាម្ចាស់កម្មសិទ្ធិ។ ជាទូទៅ ស្ទើរតែទាំងអស់នៃគ្រួសារដែលបានចូលរួមក្នុងការសិក្សានេះមានអារម្មណ៍ថា ការផ្លៀលចេញពុំមានជះឥទ្ធិពលអវិជ្ជមានអ្វីធ្ងន់ធ្ងរដល់សេដ្ឋកិច្ចសង្គមរបស់ពួកគាត់ឡើយ។ ចំណែកគ្រួសារមួយចំនួនតូចដែលរស់នៅក្នុងសហគមន៍ក្រីក្រនៅខណ្ឌខាងក្នុងក្រុង ដែលគាត់ជាអ្នកធ្វើអាជីវកម្មតូចតាចបានរាយការណ៍ពីផលប៉ះពាល់ជាអវិជ្ជមានចំពោះសេដ្ឋកិច្ចសង្គម ច្រើនជាងអ្នករស់ក្នុងសហគមន៍ក្រីក្រនៅខណ្ឌជាយក្រុង។ ការដែលមិនមានប្លង់រឹងមានន័យថាពួកគាត់ ពុំអាចទៅខ្ចីប្រាក់ពីធនាគារដែលមានការប្រាក់ទាបដើម្បីដាក់ទុនវិនិយោគក្នុងមុខរបរ ឬក៏កែលម្អលំនៅឋានរបស់ពួកគាត់ឡើយ។ ពួកគាត់ក៏ពុំអាចលក់នូវអចលនទ្រព្យរបស់ខ្លួនក្នុងតម្លៃខ្ពស់នោះទេ ហើយមានអ្នកខ្លះទទួលអារម្មណ៍ថាជាប់គាំងក្នុងសហគមន៍បច្ចុប្បន្នដោយមិនអាចផ្លាស់ប្តូរលំនៅឋានបាន។ ពួកគាត់ក៏ពុំមានទំនុកចិត្តថានឹងមានអ្វីជាកេរ្តិ៍ដំណែល សម្រាប់ផ្ទេរទៅអោយកូនចៅជំនាន់ក្រោយទៀត។

បើទោះជាមើលទៅហាក់មិនទាន់មានហានិភ័យ ពីការបណ្តេញចេញពីសហគមន៍ តែពាក់កណ្តាលនៃគ្រួសារក្នុងសហគមន៍ក្រីក្រក្នុងការសម្ភាសដែលភាគច្រើនជាស្ត្រី បានបង្ហាញនូវការភ័យព្រួយពីស្ថានភាពរបស់ពួកគាត់។ ពាក់ព័ន្ធនឹងអារម្មណ៍តានតឹងនេះ វាបណ្តាលអោយពួកគាត់មានអារម្មណ៍មិនច្បាស់លាស់

សម្រាប់អនាគត ក៏ដូចជាជីវភាពរស់នៅក្នុងសហគមន៍សព្វថ្ងៃនេះ។ គ្រួសារភាគច្រើនហាក់មានក្តីសង្ឃឹមតិចតួចណាស់ថា នៅថ្ងៃណាមួយពួកគាត់នឹងទទួលបានបណ្ណ័កម្មសិទ្ធិ ដោយសារពួកគាត់ជឿជាក់ថាពួកគាត់បានរស់នៅលើដីសាធារណៈរបស់រដ្ឋ ឬសំណង់អនាធិបតេយ្យដែលពុំអាចមានកម្មសិទ្ធិ។ ការផ្លៀលចេញនេះ ធ្វើឲ្យស្ថានភាពមិនជាក់លាក់ដែលមានស្រាប់របស់ពួកគាត់កាន់តែមានលក្ខណៈធ្ងន់ធ្ងរឡើង និងបង្កើននូវភាពមិនពិតប្រាកដដល់អនាគតរបស់ពួកគាត់។ ការដែលគ្មានប័ណ្ណកម្មសិទ្ធិ និងមិនមានសុវត្ថិភាពនៃសិទ្ធិកាន់កាប់ បានធ្វើឲ្យពួកគាត់មានអារម្មណ៍ថា បាត់បង់សុវត្ថិភាពដីធ្លី និងសិទ្ធិអំណាច។ របាយការណ៍នេះបានបញ្ចប់ដោយផ្តល់នូវអនុសាសន៍ចំនួន១៥ចំណុចៈ ការយល់អំពីបញ្ហា ភាពច្បាស់លាស់ និងតម្លាភាព ការដោះស្រាយចំពោះការផ្លៀលចេញ និងការដោះស្រាយជាមួយសហគមន៍ក្រីក្រ។

# ពាក្យកាត់

| | |
|---|---|
| AC | គណៈកម្មការរដ្ឋបាល |
| CC | គណៈកម្មការសុរិយោដី |
| CSES | ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា |
| DK | កម្ពុជាប្រជាធិបតេយ្យ |
| ELC | សម្បទានដីសេដ្ឋកិច្ច |
| FGD | ការពិភាក្សាជក្រុម |
| KII | ការសម្ភាសព័ត៌មានពីបុគ្គលសំខាន់ |
| LASSP | កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី |
| LICADHO | សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស |
| LMAP | គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី |
| LTR | ក្រុមចុះបញ្ជីដីធ្លី |
| MLMUPC | ក្រសួយរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MPP | សាលារាជធានីភ្នំពេញ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NGOF | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា |
| PPDLMUPC | មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រាជធានីភ្នំពេញ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SLC | សម្បទានដីសង្គមចិត្ត |
| SLR | ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ |
| SPSS | កម្មវិធីស្ថិតិវិភាគវិទ្យាសាស្ត្រសង្គម |
| SSI | ការសម្ភាសពាក់កណ្តាលទម្រង់ការណ៍ |
| STT | សមាគមធាងត្នោត |
| UN | អង្គការសហប្រជាជាតិ |
| UPC | សហគមន៍ក្រីក្រនៅទីក្រុង |
| UPS | ការតាំងទីលំនៅរបស់សហគមន៍ក្រីក្រនៅទីប្រជុំជន |

# និយមន័យនៃពាក្យគន្លឹះ

## *សហគមន៍ក្រីក្រ និងសំណង់អនាធិបតេយ្យ*

សហគមន៍ក្រីក្រនៅទីប្រជុំជនជារឿយៗគេនិយមហៅថា «សំណង់អនាធិបតេយ្យ»។ មិនមាននិយមន័យជាផ្លូវការអំពីពាក្យថាសំណង់អនាធិបតេយ្យនេះទេ តែជាទូទៅគេយល់ថាវាជាទីកន្លែងរស់នៅដោយគ្មានការអនុញ្ញាតច្បាប់ ដែលភាគច្រើនបានប្រមូលផ្តុំរស់នៅដោយប្រជាពលរដ្ឋក្រីក្រ។[១] ការសិក្សានេះប្រើប្រាស់និយមន័យនៃពាក្យ «សំណង់អនាធិបតេយ្យ» របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិលំនៅឋាន (២០១២) ដែលផ្តល់និយមន័យថា ជាបណ្តុំនៃគ្រួសារនានាដែលមានលក្ខណៈខ្វះខាតនូវធនធានមួយ ឬច្រើននៃលក្ខខណ្ឌដូចខាងក្រោមនេះ ៖

១. សំណង់ផ្ទះរឹងមាំ៖ គឺជាសំណង់អចិន្ត្រៃយ៍ដែលមានគ្រឹះរឹងមាំអាចធន់ទ្រាំទៅនឹងស្ថានភាពអាកាសធាតុអាក្រក់ធ្ងន់ធ្ងរបាន។
២. បន្ទប់មានទំហំសមរម្យសម្រាប់រស់នៅ៖ មានមនុស្សរស់នៅក្នុងបន្ទប់ជាមួយគ្នាមិនលើសពី៣នាក់។
៣. មានភាពងាយស្រួល ក្នុងការទទួលបាននូវទឹកស្អាតប្រើប្រាស់ក្នុងបរិមាណសមស្រប និងក្នុងតម្លៃសមរម្យ។
៤. មានលទ្ធភាពកែលម្អសម្ភារៈអនាម័យ ដូចជាមានបង្គន់ជាលក្ខណៈឯកជន ឬជាសាធារណៈ ដែលប្រើប្រាស់រួមក្នុងបរិមាណមនុស្សសមស្រប។
៥. មានសុវត្ថិភាពសិទ្ធិកាន់កាប់ (ផ្លូវការ ឬមិនផ្លូវការ) និងការការពារពីការបណ្តេញចេញដោយបង្ខំ។

ការសិក្សានេះ បានប្រើប្រាស់ព័ត៌មានពីការអង្កេតរបស់សមាគមធាងត្នោតឆ្នាំ២០១៤ ដើម្បីជ្រើសរើសសំណាកគំរូពីសហគមន៍ក្រីក្រ។ សមាគមធាងត្នោត (២០១៤ ទំព័រទី៣) បានផ្តល់និយមន័យ ការតាំងទីលំនៅរបស់សហគមន៍ក្រីក្រ

---

[១] នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់សាលារាជធានីភ្នំពេញ បានប្រើប្រាស់និយមន័យ យ៉ាងស្តួចស្តើងលើពាក្យថា "សំណង់អនាធិបតេយ្យ" ថាជាការតាំងទីលំនៅមិនផ្លូវការរំលោភទៅលើដីរដ្ឋ (Channyda & Seift ២០១៣)។ នៅក្នុងការអង្កេតឆ្នាំ២០១២ សាលារាជធានីភ្នំពេញ បានប្រើពាក្យថា "សហគមន៍ក្រីក្រនៅទីក្រុង" ក៏ប៉ុន្តែពុំបានផ្តល់នូវនិយមន័យពេញលេញនោះទេ។

នៅទីប្រជុំជន (UPS) ថាជាក្រុមគ្រួសារដែលមានផ្ទះសម្បែងជាប់ៗគ្នាយ៉ាងតិច ១០ ឬ ច្រើនជាងនេះ ដែលសំណង់នោះមានទ្រង់ទ្រាយបង្ហាញពីសភាពខ្សត់ខ្សោយ ឬក៏ផ្ទះសម្បែងដែលសាងឡើងមិនតាមបទដ្ឋានត្រឹមត្រូវ ហើយពុំមានគ្រឹះរឹងមាំ។

## *សហគមន៍ដែលត្រូវបានផ្លៀសចេញ*

ការសិក្សានេះ ប្រើនិយមន័យដែលមានចែងក្នុងរបាយការណ៍របស់អង្គការ WVC និង NGOF ឆ្នាំ ២០១២ ដែលកំណត់ថា សហគមន៍ដែលត្រូវបានផ្លៀសចេញ គឺជាសហគមន៍ទាំងឡាយណាដែលត្រូវបានគេផ្លៀសចេញមុនពេល ឬក្នុងកំឡុងពេលនៃដំណើរការចុះវាស់វែង និងកំណត់ព្រំប្រទល់នៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ព្រមទាំងក្នុងករណីនានាដែលគេកាត់ទុកសិន ដោយសារតែដីនៅម្តុំនោះមានលក្ខណៈមិនច្បាស់លាស់ (World Vision និង NGO Forum ២០១២ ទំព័រ ii)។ អង្គការ CCHR (ឆ្នាំ២០១៣ ទំព័រទី១៧-១៨) បានលើកឡើងថា សហគមន៍ដែលត្រូវបានគេផ្លៀសចេញ គឺជាសហគមន៍ដែលមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិ ដោយសារតែសហគមន៍ទាំងនោះមានលក្ខណៈ «ស្មុគស្មាញពេក» ឬក៏ដីនោះមានលក្ខណៈមិនច្បាស់លាស់។ Bugalski & Pred (២០០៩ ទំព័រទី៤) បានផ្តល់និយមន័យថា គ្រួសារ និងសហគមន៍ដែលត្រូវបានគេផ្លៀសចេញ គឺជាក្រុមដែលត្រូវបានគេរាំងពីការធ្វើប័ណ្ណកម្មសិទ្ធិ ព្រោះដីរបស់ពួកគេ «អាចមានទំនាស់ ឬក៏ពុំមានលក្ខណៈច្បាស់លាស់»។ ការសិក្សានោះបានបរិយាយថា ពុំមានបញ្ញត្តិច្បាប់ណាមួយ ដែលចែងអំពីការផ្លៀសចេញនៅក្នុងឯកសារស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនោះទេ ហើយពាក្យថា «ដីមិនមានលក្ខណៈច្បាស់លាស់» ក៏ពុំត្រូវបានផ្តល់និយមន័យដែរ។



# I. សេចក្តីផ្តើម



# I. សេចក្តីផ្តើម

ជាងបីទសវត្សរ៍មកហើយ ក្រោយពីការបញ្ចប់នូវរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៩ ផលប៉ះពាល់នៃការប្តូររបបនយោបាយថ្មីដ៏ឆាប់រហ័ស ជាពិសេសការលុបចោលនូវកម្មសិទ្ធិឯកជន និងការបង្ខំឲ្យប្រជាពលរដ្ឋរាប់លាននាក់តាំងទីលំនៅថ្មី កំពុងតែស្ថិតនៅក្នុងមន្ទិល។ ក្របខណ្ឌនៃកម្មសិទ្ធិដីឯកជនដែលត្រូវបានបង្កើតឡើងនាសម័យអាណានិគមបារាំង ត្រូវបានបំផ្លាញចោលអស់ជាមួយនឹងកំណត់ត្រាដីធ្លីជាច្រើន។ មកដល់ទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០ មនុស្សម្នាបានវិលត្រឡប់ចូលទីក្រុងភ្នំពេញវិញ ហើយការកាន់កាប់អគារ និងដីទំនេរជាកម្មសិទ្ធិពីជំនាន់នោះពុំត្រូវបានគេទទួលស្គាល់សិទ្ធិជាម្ចាស់កម្មសិទ្ធិទៀតឡើយ ហើយប្រព័ន្ធកម្មសិទ្ធិដីធ្លីជាផ្លូវការនៅមានភាពខ្វះខាតនៅឡើយ។ ច្បាប់មួយចំនួនត្រូវបានតាក់តែងឡើងក្នុងគោលបំណង កសាងឡើងវិញនូវសិទ្ធិជាម្ចាស់កម្មសិទ្ធិនៃដីឯកជន ក៏ប៉ុន្តែកម្មសិទ្ធិដីធ្លី ឬសុវត្ថិភាពសិទ្ធិកាន់កាប់នៅតែជាការព្រួយបារម្ភសម្រាប់ប្រជាពលរដ្ឋកម្ពុជាជាច្រើន ដែលពុំមានប័ណ្ណកម្មសិទ្ធិលើអចលនទ្រព្យរបស់ពួកគាត់ដែលបានរស់នៅជាច្រើនឆ្នាំមកហើយនោះ។

ជាការព្យាយាម និងដោះស្រាយបញ្ហានេះ គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ដែលមានទ្រង់ទ្រាយធំមួយត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០២ ក្រោមក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដោយមានការឧបត្ថម្ភគាំទ្រពីពហុអ្នកផ្តល់ជំនួយ (Bridges Across Borders-Cambodia ២០១៤)។ គោលបំណងដែលបានដាក់ចេញ គឺដើម្បីធ្វើអោយប្រសើរឡើងដល់សុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋក្រីក្រ ព្រមទាំងកាត់បន្ថយ និងបញ្ចៀសបញ្ហាជម្លោះដីធ្លី និងការរំលោភសិទ្ធិដីធ្លី តាមរយៈការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងចេញប័ណ្ណកម្មសិទ្ធិទូទាំងប្រទេស (Bugalski & Pred ២០០៩)។ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គឺជាសមាសភាគមួយដ៏សំខាន់នៃសមាសភាគគ្រឹះទាំង ៥ នៃគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី។ គម្រោងនេះបានបញ្ចប់នៅឆ្នាំ ២០០៩ ក៏ប៉ុន្តែការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ នៅតែបន្តក្រោមកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីនៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅក្នុងខេត្តចំនួន ១៥ ក្នុងចំណោម ២៥ នៅកម្ពុជា។ មកទល់ខែ កញ្ញា ឆ្នាំ២០១៤ មិនលើសពី ១៣៩.០៦៧ ក្បាលដីត្រូវបាន

ផ្តល់ប័ណ្ណកម្មសិទ្ធិក្រោមការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅភ្នំពេញ។[២]

នៅខែ កញ្ញា ឆ្នាំ ២០១៤ មន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ បានប៉ាន់ស្មានថា មានប្រជាជនចំនួនជិត២៥.០០០គ្រួសារ រស់នៅក្នុងសហគមន៍ក្រីក្រនៅរាជធានីភ្នំពេញ។ ភាគច្រើននៃគ្រួសារទាំងនេះមិនមានសុវត្ថិភាពដីធ្លី ហើយប្រឈមនឹងហានិភ័យ ឬជាជនរងគ្រោះដោយសារការបណ្តេញចេញ ដោយបង្ខំ។ ដើម្បីធ្វើជាប្រយោជន៍ដល់គម្រោងអភិវឌ្ឍន៍ និងកែលម្អសោភណ្ឌភាពទីក្រុង ប្រជាជនក្រីក្រជាច្រើនត្រូវបានបណ្តេញចេញដោយបង្ខំដោយមានសំណង ឬជំនួយតិចតួច (Amnesty International ២០០៨ ទំព័រទី៦)។ ចន្លោះពីឆ្នាំ ១៩៩០ ដល់ ២០១១ មានប្រជាជនចំនួន ២៩.៣៥៨ គ្រួសារ ឬ (១៤៦.៧៩០ នាក់) ដែលរស់នៅតាមសំណង់អនាធិបតេយ្យនានានៅភ្នំពេញត្រូវបានជន្លៀសចេញពីលំនៅឋាន តាមរយៈផែនការផ្លាស់ប្តូរទីលំនៅ ឬបណ្តេញចេញដោយបង្ខំ (STT ២០១១)។ នៅក្នុងឆ្នាំ ២០១៣ យ៉ាងហោចណាស់មានកន្លែងចំនួន ៣៦ បានទទួលនូវសេចក្តីជូនដំណឹងអំពីការ បណ្តេញចេញ (STT ២០១៣ ទំព័រទី១១)។

មានគ្រួសារនៃសហគមន៍ក្រីក្រជាច្រើន នៅតែបន្តប្រឈមនឹងភាពគ្មានសុវត្ថិភាពដីធ្លី និងការភ័យខ្លាចអំពីការបណ្តេញចេញដោយសារមូលហេតុផ្សេងៗ ទោះបីជាពួកគាត់មានឯកសារបញ្ជាក់ពីសិទ្ធិកាន់កាប់ក្តី ដោយសារតែមានគ្រួសារក្នុងសហគមន៍ក្រីក្រខ្លះ ត្រូវបានផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ (CCHR ២០១៣; Lindstrom ២០១៣)។ មានទិន្នន័យជាសាធារណៈតិចតួចណាស់អំពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ហើយមានការពិបាកក្នុងការទទួលបានព័ត៌មានលម្អិតអំពីទំហំ និងមូលហេតុនៃការផ្លៀលចេញពីប្រភពជាផ្លូវការ។ ជាទូទៅភាពជោគជ័យនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធត្រូវបានគេវាស់វែង តាមរយៈបរិមាណនៃប័ណ្ណកម្មសិទ្ធិដែលបានចេញឲ្យ ប៉ុន្តែគេកម្ររកឃើញតាមរយៈការកាត់បន្ថយភាពក្រីក្រណាស់។ មានការសិក្សាតិចតួចដែលបានធ្វើឡើងអំពីផលប៉ះពាល់នៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ទៅលើការកាត់បន្ថយភាពក្រីក្រ (FIAN Germany ២០១១)។ អង្គការ WVC និង NGOF បានសហការគ្នារៀបចំឲ្យមានការសិក្សាស្រាវជ្រាវនេះឡើង ដើម្បីស្វែងរកហេតុផលដែលនៅពីក្រោយការផ្លៀល

---

[២] ស្ថិតិពីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់។ នៅក្នុងឆ្នាំ ២០១៣ គេប៉ាន់ប្រមាណថាមានប្រជាពលរដ្ឋចំនួន ១,៦៨៨,០៤៤ នាក់ ឬ ១១.៥% នៃប្រជាពលរដ្ឋខ្មែរ រស់នៅក្នុងទីក្រុងភ្នំពេញ (NIS, ២០១៣) ។

សហគមន៍ក្រីក្រចេញពីការបញ្ជីចុះដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងផលប៉ះពាល់នៃការផ្លៀលចេញ ទៅលើគ្រួសារក្រីក្រ ជាពិសេស ស្ត្រី និងកុមារ (ឧបសម្ព័ន្ធ A )។

## ១.១ គោលបំណង និងកម្មវត្ថុ

គោលបំណងនៃការសិក្សានេះ គឺស្វែងរកផលប៉ះពាល់ដែលកើតចេញពីការផ្លៀលសហគមន៍ក្រីក្រចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ នៅរាជធានីភ្នំពេញ លើជីវភាពរស់នៅរបស់គ្រួសារក្នុងសហគមន៍ទាំងនោះ ព្រមទាំងសិក្សាអំពីមូលហេតុនៃការផ្លៀលចេញនេះផងដែរ។ ការសិក្សានេះមានគោលបំណង៖

១. ស្វែងរកទីតាំងសហគមន៍ក្រីក្រដែលត្រូវបានផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ នៅក្នុងខណ្ឌចំនួន ៦ ក្នុងរាជធានីភ្នំពេញ
២. ស្វែងយល់អំពីផែនការរបស់រាជរដ្ឋាភិបាល និងមូលហេតុនៃការផ្លៀលសហគមន៍ក្រីក្រចេញ ក៏ដូចជាកត្តាជំរុញផ្សេងៗទៀត
៣. ប្រៀបធៀបជីវភាពគ្រួសារ ជាពិសេសស្ថានភាពស្ត្រី និងកុមារ មុន និងក្រោយពេលផ្លៀលចេញ
៤. ស្វែងយល់អំពីផលប៉ះពាល់នៃការផ្លៀលចេញ ទៅលើជីវភាពរស់នៅរបស់សហគមន៍ក្រីក្រ ដោយផ្តោតការយកចិត្តទុកដាក់លើស្ត្រី និងកុមារ។

## ១.២ សំណួរស្រាវជ្រាវ

ការសិក្សានេះឆ្លើយតបនូវសំណួរដូចខាងក្រោមនេះ ៖

១. តើសហគមន៍អ្នកក្រីក្រ ដែលត្រូវបានផ្លៀលចេញមានទីតាំងនៅកន្លែងណា ក្នុងខណ្ឌទាំង៦ ក្នុងរាជធានីភ្នំពេញ?
២. តើអ្វីជាមូលហេតុនៃការផ្លៀលសហគមន៍ក្រីក្រចេញពីដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ?
៣. តើការផ្លៀលចេញនេះ មានជះឥទ្ធិពលអ្វីទៅជីវភាពរស់នៅរបស់គ្រួសារនៅក្នុងសហគមន៍ទាំងនោះដែរឬទេ? ប្រសិនជាមាន តើតាមរបៀបណា?
៤. តើសហគមន៍ទាំងនេះមានទស្សនៈយ៉ាងណាចំពោះការផ្លៀលចេញនេះ?
៥. តើអ្វីខ្លះដែលអាចជាដំណោះស្រាយ ចំពោះការផ្លៀលចេញនេះ?
៦. តើអនុសាសន៍អ្វីខ្លះដែលអាចជាដំណោះស្រាយមានប្រយោជន៍ ចំពោះករណីផ្លៀលចេញនេះ?

# II. វិធីសាស្ត្រ



# II. វិធីសាស្ត្រ

## ២.១ ការជ្រើសរើសទីតាំងសិក្សា

រាជធានីភ្នំពេញមានខណ្ឌចំនួន១២៖[៣] ៧មករា ចំការមន ច្បារអំពៅ ជ្រោយចង្វារ ដូនពេញ ដង្កោ មានជ័យ ពោធិ៍សែនជ័យ ព្រែកព្នៅ ឫស្សីកែវ សែនសុខ និងទួលគោក។ ការសិក្សានេះផ្ដោតទៅលើខណ្ឌចំនួន ៦ គឺ ចំការមន ដង្កោ ដូនពេញ មានជ័យ សែនសុខ និងទួលគោក ដែលការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធត្រូវបានបញ្ចប់ ឬហៀបនឹងបញ្ចប់។ ទិន្នន័យនៃសហគមន៍ដែលបានផ្លៀលចេញជាផ្លូវការពុំមានជាសាធារណៈទេ។ តែទោះជាយ៉ាងនេះក្ដី នៅខែកុម្ភៈ ឆ្នាំ ២០១៤ សមាគមធាងត្នោត បានបញ្ចេញនូវរបាយការណ៍ការសិក្សាមួយស្ដីអំពីការតាំងទីលំនៅរបស់ប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុង ដែលបានផ្ដល់នូវព័ត៌មានអំពីការផ្លៀលសហគមន៍ទាំងនេះចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ (STT ២០១៤)។ ការសិក្សានោះ បានផ្អែកទៅលើការចុះទៅប្រមូលព័ត៌មាននៅមូលដ្ឋានដែលក្នុងនោះបានការចូលរួមពីគ្រួសារមកពីសហគមន៍ក្រីក្រចំនួន ៣៤០ សហគមន៍ និងអាជ្ញាធរមូលដ្ឋាននៅក្នុងខណ្ឌចំនួន ៩ នៅភ្នំពេញ តាមរយៈការសម្ភាស។ គេបានរកឃើញថា នៅក្នុងខណ្ឌទាំង ៦ ដែលការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធបានបញ្ចប់ ឬបានធ្វើឡើងកន្លងមកនេះ មានសហគមន៍ក្រីក្រចំនួន ២០៨ បានតាំងលំនៅដោយមានអ្នករស់នៅចំនួន២២.៩២០គ្រួសារ(សូមមើលតារាងទី១)។ ក្នុងចំណោមសហគមន៍ទាំងនេះ មានសហគមន៍ចំនួន៣១ ដែលត្រូវបានបញ្ជាក់ច្បាស់អំពីការផ្លៀលចេញ។ តាមរយៈព័ត៌មាននេះ ទិន្នន័យនៃការផ្លៀលចេញត្រូវបានផ្ទៀងផ្ទាត់ជាមួយអាជ្ញាធរមូលដ្ឋាន និងសហគមន៍ចំនួនពីរក្នុងមួយខណ្ឌដែលត្រូវបានជ្រើសរើសជាសំណាកគំរូដោយវិធីសាស្ត្រចាប់ដោយចៃដន្យ សម្រាប់ការសិក្សានេះ។

តារាងទី១ បង្ហាញអំពីចំនួនសហគមន៍ក្រីក្រដែលត្រូវបានផ្លៀលចេញនៅក្នុងខណ្ឌទាំង ៦ និងសហគមន៍ក្រីក្រចំនួន ១២ ដែលត្រូវបានជ្រើសរើសជាសំណាកគំរូក្នុងការសិក្សានេះ។ ឧបសម្ព័ន្ធ A បង្ហាញផែនទីនៃសហគមន៍ក្រីក្រដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សា។

[៣] ពាក្យ “ខណ្ឌ” ជាភាសាខ្មែរ មានន័យថា “ស្រុក” តែពាក្យខណ្ឌប្រើតែនៅក្នុងទីក្រុងប៉ុណ្ណោះ។

**តារាងទី១៖ ការតាំងទីលំនៅ និងការផ្លៀលចេញនៅក្នុងសហគមន៍ក្រីក្រ ក្នុងខណ្ឌទាំង ៦ (២០១៣)**

| ខណ្ឌ | ចំនួនសហគមន៍ | ចំនួនគ្រួសារ | ចំនួនសហគមន៍ត្រូវបានផ្លៀលចេញ | សហគមន៍ដែលត្រូវបានគេប្រាប់ថាបានផ្លៀលចេញ* |
|---|---|---|---|---|
| ចំការមន | ២៥ | ២.២៧០ | ២ | • **បឹងត្របែក**, ចៅពញាហុក |
| ដង្កោ | ២៥ | ៣.៩៧៦ | ១១ | • មូល (សំបុកចាប), មូរ, **ភូមិចេក**, **ភូមិអ្នកតា (រលួស)**, សេរីដីដុះ, ទឹកថ្លា,<br>• ៥ សហគមន៍គ្មានឈ្មោះ |
| ដូនពេញ | ១៧ | ៦១៤ | ៣ | • **ប្លុកតាន់ប៉ា**, **ផ្លូវរថភ្លើង**, ផ្លូវរូនភ្លង |
| មានជ័យ | ៨៩ | ៧.០១៧ | ៦ | • គ្រិស្តវាលស្បូវ, ភូមិជ្រោយបាសាក់, **ភូមិព្រែកតាន្ទ២**, ភូមិទួលរកា, សហគមន៍ព្រះ, ឆ្មោតជ្រុំ៥, ថ្មសាន **(ដើមស្លែង)** |
| សែនសុខ | ៣១១ | ៦.២៥៥ | ៦ | • **បុរី១០០ខ្នង**,ក្រុម៨, ភូមិ៥ខ្នង, ភូមិផ្សារលិច, **ទឹកថ្លា២**<br>• ១សហគមន៍គ្មានឈ្មោះ |
| ទួលគោក | ២១ | ២.២៨៨ | ៣ | • **សហគមន៍១០២**, **សហគមន៍៣៤៧**, ក្រោមស្ពាន |
| សរុប | ២០៨ | ២២.៤២០ | ៣១ | |

<u>កំណត់សម្គាល់៖</u> *ឈ្មោះសហគមន៍ដែលមានពណ៌ខ្មៅដិត ជាសហគមន៍ត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ។
ប្រភព៖ (STT ២០១៤ ទំព័រទី១៧)

## ២.២ វិធីសាស្ត្រប្រមូលទិន្នន័យ និងការជ្រើសរើសសំណាកគំរូ

វិធីសាស្ត្រប្រមូលទិន្នន័យរួមមាន៖ ការសម្ភាសពាក់កណ្ដាលទម្រង់ការណ៍ ការពិភាក្សាជាក្រុម ការសម្ភាសស៊ីជម្រៅ ការសម្ភាសអ្នកផ្ដល់ព័ត៌មានសំខាន់ និងការសង្កេតទីតាំង (សូមមើលឧបសម្ព័ន្ធ B សម្រាប់កម្រងសំណួរ)។ គ្រួសារចំនួន ៥ ត្រូវបានជ្រើសរើសដោយចៃដន្យចេញពីសហគមន៍នីមួយៗ ក្នុងចំណោមសហគមន៍ក្រីក្រទាំង១២ ដើម្បីសម្ភាសន៍ដោយប្រើកម្រងសំណួរពាក់កណ្ដាលទម្រង់ការណ៍ជាមួយមេគ្រួសារ (តារាងទី២)។ ការសម្ភាសតាមគ្រួសារត្រូវបានធ្វើ

ឡើងដោយក្រុមស្រាវជ្រាវដែលមានគ្នាចំនួន៣នាក់ ដែលក្នុងនោះមានជំនួយការប្រុសម្នាក់ និងស្រីម្នាក់។ ការសម្ភាសបានធ្វើឡើងក្នុងអំឡុងខែ សីហា និង កញ្ញា ឆ្នាំ២០១៤។ កិច្ចពិភាក្សាជាក្រុមត្រូវបានធ្វើឡើងជាមួយអ្នកតំណាងសហគមន៍នៅក្នុងសហគមន៍ចំនួន ២ និងជាមួយមន្ត្រីរាជរដ្ឋាភិបាលមួយក្រុមដែលមានគ្នាចំនួនប្រាំបីនាក់មកពីមន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ។ កិច្ចសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ត្រូវបានធ្វើជាមួយមេភូមិចំនួន៥រូប និងតំណាង អង្គការមិនមែនរដ្ឋាភិបាលចំនួនបីរូប មកពី GIZ និងសមាគមធាងត្នោត។ នៅក្នុងសហគមន៍ក្រីក្រនីមួយៗ ក្រុមស្រាវជ្រាវបានធ្វើការសង្កេតផ្ទាល់នៅទីកន្លែង ដោយរួមបញ្ចូលទាំងការសន្ទនាក្រៅផ្លូវការជាមួយអ្នករស់នៅទីនោះទៀតផង។

### តារាងទី២ ៖ សំណាកគំរូនៃអ្នកតបសម្ភាសន៍ និងទំហំសំណាក

| អ្នកចូលរួម | | | វិធីសាស្ត្រ |
|---|---|---|---|
| ប្រភេទ | ចំនួនសរុប | ចំនួនស្ត្រី (%) | |
| គ្រួសារក្នុងសហគមន៍ក្រីក្រ | ៦០ | ៤០ (៦៧%) | ការសម្ភាសដោយប្រើកម្រងសំណួរពាក់កណ្តាលទម្រង់ការណ៍ និង ការពិភាក្សាស៊ីជម្រៅ |
| មេភូមិ | ៥ | ១ (២០%) | ការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ |
| តំណាងសហគមន៍ក្រីក្រ (ព្រែកតានូ ២ និង ទឹកថ្លា២) | ១៧ | ៩ (៥៣%) | កិច្ចពិភាក្សាជាក្រុម |
| មន្ត្រីមន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់ | ៨ | 0 (0%) | កិច្ចពិភាក្សាជាក្រុម |
| តំណាងអង្គការ | ៣ | 0 (0%) | សម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ |
| សរុប | ៩៣ | ៥០ (៥៤%) | |

## ២.៣ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យរួមបញ្ចូលទាំងវិធីសាស្ត្របែបបរិមាណ និងបែបគុណភាព។ ទិន្នន័យប្រជាសាស្ត្រសង្គម និងសេដ្ឋកិច្ច ដែលបានមកពីការសម្ភាសជាមួយគ្រួសារសហគមន៍ក្រីក្រ ត្រូវបានដាក់ជាលេខកូដ ដើម្បីទទួលបានព័ត៌មានបែបបរិមាណសម្រាប់ធ្វើការវិភាគទិន្នន័យ។ ទិន្នន័យបែបគុណភាពពាក់ព័ន្ធនឹងដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការផ្លៀលចេញក៏ត្រូវបានដាក់លេខកូដដែរ។ ទិន្នន័យបែបពិពណ៌នា ត្រូវបានបង្កើតឡើងដោយប្រើប្រាស់កម្មវិធី SPSS[៤]។ ទិន្នន័យបែបគុណភាពដែលទទួលបានពីគ្រួសារនៅសហគមន៍ក្រីក្រ បានផ្តល់នូវព័ត៌មានសម្រាប់ធ្វើករណីសិក្សា។ ការសម្ភាសជាមួយមេភូមិ ក្រុមប្រឹក្សាឃុំ និងអ្នកតំណាងឃុំ បានផ្តល់នូវព័ត៌មានលក្ខណៈទូទៅអំពីស្ថានភាពសេដ្ឋកិច្ចសង្គមនៃសហគមន៍ក្រីក្រ ដែលអាចយកមកធ្វើការផ្ទៀងផ្ទាត់ជាមួយទិន្នន័យដែលបានមកពីការសម្ភាសតាមគ្រួសារ។ មេភូមិ និងមេឃុំក៏អាចបញ្ចេញយោបល់អំពីដំណើរការនៃចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ មូលហេតុនៃការផ្លៀលចេញ និងផលប៉ះពាល់នៃការផ្លៀលចេញដែរ។ ទិន្នន័យដែលមានស្រាប់ត្រូវបានប្រមូលតាមរយៈការសិក្សាឯកសារទាក់ទងនឹងសហគមន៍ក្រីក្រ និងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅកម្ពុជា។ ទិន្នន័យទាំងនោះមានប្រយោជន៍សំខាន់ក្នុងការបំពេញបន្ថែមជាទូទៅទៅលើការវិភាគទិន្នន័យបឋម។

## ២.៤ ដែនកំណត់ និងកត្តាប្រឈម

វិធីសាស្ត្រនៃការស្រាវជ្រាវ ផ្តោតជាសំខាន់ទៅលើការប្រមូលព័ត៌មានបែបគុណភាព និងផ្អែកទៅលើសំណាកគ្រួសារដែលមានទំហំតូច (ចំនួន ៥គ្រួសារ ក្នុងមួយសហគមន៍)។ ព័ត៌មានដែលប្រមូលបានមានភាពគ្រប់គ្រាន់ ដើម្បីជាតំណាងឲ្យសហគមន៍ក្រីក្រតូចៗ[៥] តែមិនតំណាងអោយសហគមន៍ក្រីក្រធំៗនោះទេ។ ការរក

[៤] SPSS (Statistical Package for Social Sciences) ជាកម្មវិធីដើម្បីវិភាគទិន្នន័យ។

[៥] សហគមន៍ធាងត្នោត (២០១៤) កត់សម្គាល់ថាភាគច្រើនសហគមន៍ក្រីក្រមានតិចជាង ៥០ខ្នងផ្ទះ។ ក្នុងការសិក្សារបស់យើង មានសហគមន៍ចំនួន ៨ ដែលមានខ្នងផ្ទះពី ១០ ទៅ ៥១ (ជាមធ្យម = ៣៥)។ ជាមធ្យមភាគនៃចំនួនអ្នកដែលត្រូវសម្ភាសន៍ក្នុងសហគមន៍ទាំង៨ គឺវាតំណាងឲ្យ ១៤% នៃគ្រួសារ។ សហគមន៍ ៤ ដ៏ទៃទៀតមានខ្នងផ្ទះ ន្លោះពី ១០០ ទៅ ៤០០ (ជាមធ្យម = 250)។

ឃើញក្នុងការសិក្សានេះ ពុំអាចប្រើប្រាស់ជាលក្ខណៈតំណាងទូទៅដល់សហគមន៍ក្រីក្រនៅភ្នំពេញទាំងអស់បានទេ ក៏ប៉ុន្តែវាបានរំលេចចេញនូវបញ្ហាសំខាន់ៗដែលជាមូលដ្ឋានគ្រឹះ សម្រាប់ការសិក្សាស្រាវជ្រាវនាពេលអនាគតដែលមានសំណាកគំរូធំៗ។ ការសិក្សារបស់យើងបានប្រមូលព័ត៌មានពីឯកសារដែលមានស្រាប់នានាជាពិសេស ការសិក្សារបស់សាលារាជធានីភ្នំពេញ និងសមាគមធាងត្នោតឆ្នាំ ២០១៤។ ការសិក្សាទាំងពីរនេះបានផ្តល់នូវទិន្នន័យ និងព័ត៌មានដ៏សំខាន់អំពីសហគមន៍ក្រីក្រនៅភ្នំពេញ។ យ៉ាងណាមិញ យើងពុំអាចប្រមែប្រមូលទិន្នន័យឲ្យបានគ្រប់គ្រាន់ពីប្រភពផ្លូវការ សម្រាប់ធ្វើជាទិន្នន័យសម្រាប់ដើម្បីផ្ទៀងផ្ទាត់បានឡើយ។ បញ្ហាសិទ្ធិដីធ្លី គឺជាប្រធានបទនយោបាយដ៏រសើបមួយនៅកម្ពុជា ហើយក្រុមស្រាវជ្រាវបានរកឃើញថា កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរ និងបណ្តាក្រសួងនានាគឺនៅមានកម្រិត។ មានករណីជាច្រើនដែលអាជ្ញាធរបានបដិសេធចំពោះការសុំសម្ភាសន៍។



# III. ការសិក្សាឯកសារដែលមានស្រាប់



# III. ការសិក្សាឯកសារដែលមានស្រាប់

## ៣.១ កម្មសិទ្ធិដីធ្លីនៅកម្ពុជា

### ៣.១.១ ប្រវត្តិនៃកម្មសិទ្ធិដីធ្លី

នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានអូសបន្លាយចាប់ពីខែ មេសា ឆ្នាំ១៩៧៥ ដល់ ខែ មករា ឆ្នាំ១៩៧៩ មានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សដោយរួមបញ្ចូលទាំងការអនុវត្តការលុបចោលកម្មសិទ្ធឯកជន។ ក្នុងទីក្រុងភ្នំពេញ និងទីប្រជុំជន ដទៃទៀតស្ទើរតែទាំងស្រុង ត្រូវបានជម្លៀសប្រជាជនដោយបង្ខំឲ្យទៅធ្វើកានៅទីជនបទ ដោយប្រើប្រាស់ដីស្រែចម្ការ។ ប័ណ្ណកម្មសិទ្ធិដីធ្លី និងឯកសារកត់ត្រាដីធ្លីស្ទើរតែទាំងអស់ត្រូវបានបំផ្លាញចោល។ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានដួលរលំនៅខែ មករា ឆ្នាំ១៩៧៩ ប្រជាជនដែលបានជន្លៀសទៅនាសម័យនោះបានត្រឡប់មករកភូមិឋានរបស់ខ្លួនវិញ និងចាប់ផ្តើមចាប់យកដីធ្លី និងផ្ទះសម្បែង។ មន្ត្រីមូលដ្ឋានបានធ្វើការបត់បែន ក្នុងការរៀបចំសម្របសម្រួលការកាន់កាប់ដីធ្លី ប៉ុន្តែការអនុវត្តនាពេលនោះវាពុំបានម៉ត់ចត់ ហើយជារឿយៗវាស្ថិតនៅក្រោមឥទ្ធិពលខ្សែស្រឡាយអ្នកមានអំណាចលុយកាក់ (Biddulph, ២០១៤)។ នៅទីក្រុងភ្នំពេញ អ្នកចំណូលថ្មីហាក់ត្រូវបានអនុញ្ញាតឲ្យរស់នៅដោយសេរីនៅតាមអគារ និងដីធ្លីដែលនៅទំនេរ (World Bank, ២០០៩)។ ចាប់តាំងពីមានប្រជាពលរដ្ឋរស់នៅប្រមាណ១០០.០០០ នាក់ នាចុងឆ្នាំ១៩៧៩ ចំនួនប្រជាពលរដ្ឋបានកើនឡើងរហូតដល់ទៅ៦១៥.០០០នាក់ ក្នុងឆ្នាំ១៩៩០។ ច្បាប់ភូមិបាលថ្មីមួយ ដែលបានស្តារឡើងវិញនូវសិទ្ធិកាន់កាប់ដីធ្លីលក្ខណៈជាឯកជនខ្លះ ត្រូវបានអនុម័តនៅក្នុង ឆ្នាំ ១៩៩២ ប៉ុន្តែបានបញ្ជាក់ថាសិទ្ធិលើអចលនទ្រព្យមុន ឆ្នាំ១៩៧៩ មិនត្រូវបានគេទទួលស្គាល់ទៀតឡើយ។

រាជធានីភ្នំពេញត្រូវបានពង្រីកយ៉ាងឆាប់រហ័ស ហើយនៅក្នុង ឆ្នាំ ១៩៩៨ ប្រជាពលរដ្ឋខ្មែរបានកើនឡើងលើសពី ៨៦០.០០០នាក់។ អំឡុងឆ្នាំ ១៩៨៩ ស្ទើរតែគ្មានការតាំងទីលំនៅអនាធិបតេយ្យនោះទេ ប៉ុន្តែកង្វះដីធ្លីកាន់តែមានសភាពកើនឡើង ហើយមកដល់ឆ្នាំ ១៩៩៤ មានការប៉ាន់ប្រមាណថាមានប្រជាពលរដ្ឋពី ១២ ទៅ ១៥% បានតាំងទីលំនៅដោយមិនត្រឹមត្រូវ (World Bank, ២០០៩)។ វិវាទដីធ្លីបានក្លាយជាប្រភពដែលអាចនាំមកនូវភាពវឹកវរ។ វិវាទទាំងនោះ ច្រើនតែកើតមានឡើងនៅពេលដែលមានអ្នកមានបុណ្យស័ក្តិខ្ពស់ ឬក្រុមហ៊ុនទាំងឡាយដែល

ពិបាកតាមដានរកប្រភពអត្តសញ្ញាណភ្លាមៗ មកដណ្តើមកាន់កាប់ដីធ្លីដែលមានតម្លៃពីអ្នកភូមិ ដែលក្រោយមកថាជាដីរបស់ពួកគាត់ ឬរបស់ក្រុមហ៊ុនគាត់ (William, ២០១៣)។ ហេតុនេះ ប្រព័ន្ធនៃការធានាសុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លីដ៏ច្បាស់លាស់ និងការគ្រប់គ្រងរដ្ឋបាល និងដីធ្លីដ៏ខ្លាំងក្លា ត្រូវការជាចាំបាច់នៅពេលនោះ។ នៅក្នុងឆ្នាំ១៩៩៩ ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ដ៏ថ្មីមួយត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រងលើការងារទាំងឡាយណាដែលពាក់ព័ន្ធនឹងបញ្ហាដីធ្លី។

## ៣.១.២ ក្របខណ្ឌច្បាប់បច្ចុប្បន្ន

ច្បាប់ភូមិបាលថ្មីមួយដែលនៅជាធរមាន បានអនុម័តកាលពីឆ្នាំ២០០១ ដែលផ្តល់នូវការពង្រឹងច្បាប់ដ៏មានសារៈសំខាន់បំផុត ដើម្បីការពារសិទ្ធិដីធ្លីនៅកម្ពុជា។ មាត្រា៧ នៃច្បាប់ភូមិបាលឆ្នាំ២០០១ បានចែងថា៖ ម្ចាស់កម្មសិទ្ធិដីធ្លី និងផ្ទះសម្បែងមុនឆ្នាំ ១៩៧៩ ត្រូវទុកជាមោឃៈ និងរួមបញ្ចូលទាំងបទដ្ឋាននានាដើម្បីទទួលបានកម្មសិទ្ធិ តាមរយៈការកាន់កាប់ និងប្រើប្រាស់ដីយ៉ាងតិចប្រាំឆ្នាំ។ ប៉ុន្តែវាអាចធ្វើទៅបានតែក្នុងករណីដែលសិទ្ធិកាន់កាប់នោះកើតមានឡើងមុនច្បាប់នេះ ត្រូវបានអនុម័តតែប៉ុណ្ណោះ។ ការកាន់កាប់ដីទាំងឡាយណាដែលធ្វើឡើងក្រោយច្បាប់នេះត្រូវបានអនុម័តនោះ ចាត់ទុកជាអំពើខុសច្បាប់។ ជាមួយគ្នានេះផងដែរ ច្បាប់បានការពារដល់អ្នកកាន់កាប់ស្របច្បាប់ រហូតដល់ពេលដែលគេបានទទួលកម្មសិទ្ធិពេញលេញ ហើយការបណ្តេញចេញណាមួយគឺជាការខុសច្បាប់ លុះណាតែសិទ្ធិកាន់កាប់ដីត្រូវបានសម្រេចតាមរយៈដំណើរការផ្លូវច្បាប់។ ការដកហូតដីឯកជនចេញពីការចុះបញ្ជី អាចធ្វើទៅបានដោយភាគីរដ្ឋតែប៉ុណ្ណោះដោយមានផ្តល់សំណងសមស្រប និងយុត្តិធម៌។

ច្បាប់បានកំណត់ប្រភេទដីជាបីចំណាត់ថ្នាក់គឺ ដីឯកជន ដីរដ្ឋ និងដីសមូហភាព ដែលផ្តល់នូវគោលការណ៍ជាមូលដ្ឋាន សម្រាប់រាល់សំណួរទាំងឡាយណាដែលពាក់ព័ន្ធនឹងបញ្ហាសិទ្ធិប្រើប្រាស់ដីធ្លីនៅតាមជនបទ និងទីប្រជុំជន។

- ដីឯកជន រួមមានដីលំនៅឋាន និងដីកសិកម្មប្រើប្រាស់ក្នុងគោលបំណងឯកជន។
- ដីសមូហភាព រួមបញ្ចូលទាំងអចលនទ្រព្យវត្តអារាម និងអចលនទ្រព្យរបស់សហគមន៍ជនជាតិដើមភាគតិច។

- ដីរដ្ឋ រាប់បញ្ចូលយ៉ាងទូលំទូលាយទាំងដីដែលមិនមែនជាដីសម្បត្តិ ឬឯកជន។ ដីរដ្ឋចែកចេញជាដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។ ដីសាធារណៈរបស់រដ្ឋរួមមានធម្មជាតិដើម ដូចជា បឹង ឆ្នេរសមុទ្រ ឬអ្វីដែលបានបង្កើតឡើងដើម្បីគោលបំណងជាសាធារណៈ ដូចជា ផ្លូវថ្នល់ ឬផ្លូវដែក ដែលដី ឬរបស់ទាំងនេះ មិនអាចលក់ដូរ ឬទិញបាន។ ចំណែកដីឯកជនរបស់រដ្ឋ គឺជាដីឯកជនទាំងឡាយរបស់រដ្ឋដែលគេអាចលក់ ឬធ្វើលទ្ធកម្ម (World Bank, ២០០៩)។ ការកាន់កាប់អចលនទ្រព្យសាធារណៈរបស់រដ្ឋ គឺជាអំពើមិនស្របច្បាប់ ទោះបីចាប់ផ្តើមពីពេលណាក៏ដោយ។ នៅក្នុងឆ្នាំ ២០០៥ អនុក្រឹតមួយបានបង្ហាញនូវចំណុចសំខាន់ៗអំពីដំណើរការដែលដីសាធារណៈរបស់រដ្ឋ អាចធ្វើចំណាត់ថ្នាក់ឡើងវិញបាន នៅពេលដែលដីនោះបានបាត់បង់នូវផលប្រយោជន៍សាធារណៈរបស់វា។ ដីនោះបន្ទាប់មកអាចធ្វើការអភិវឌ្ឍន៍ឡើងវិញ ឬលក់បាន។

ច្បាប់ភូមិបាលឆ្នាំ ២០០១ ត្រូវបានតាក់តែងឡើងជាលក្ខណៈទូទៅ ជាមួយអនុក្រឹត្យ សេចក្តីណែនាំ និងគោលនយោបាយនានា ដែលបានបកស្រាយលម្អិតជាក់លាក់ហើយត្រូវបានអនុម័ត។ ឧទាហរណ៍ មានអនុក្រឹត្យស្តីពីការកំណត់ព្រំដីរបស់រដ្ឋ អនុក្រឹត្យស្តីពីដីសម្បទានសង្គមកិច្ច (ជាយន្តការផ្តល់ជូនឡើងវិញនូវដីរដ្ឋសម្រាប់អ្នកគ្មានដីធ្លី និងគ្រួសារអ្នកក្រីក្រ) (Biddulph, ២០១៤)។

## ៣.២ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

### ៣.២.១ គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីនិងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ

ប័ណ្ណកម្មសិទ្ធិដីធ្លីផ្លូវការដែលទទួលបានតាមរយៈការកាន់កាប់ និងប្រើប្រាស់ដី គឺជាមធ្យោបាយមួយសម្រាប់ធានាដល់សុវត្ថិភាពកាន់កាប់សិទ្ធិ ក៏ដូចជាការផ្តល់នូវឱកាសសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ (Bugalski & Pred ២០០៩; FIAN Germany, ២០១១)។ ការចុះបញ្ជីដីសម្រេចបានតាមរយៈការចុះបញ្ជីជាលក្ខណៈដាច់ដោយដុំ តាមសេចក្តីត្រូវការរបស់គ្រួសារដាច់ដោយឡែកមួយៗ ដែលជាការងារត្រូវការប្រើប្រាស់ពេលវេលាច្រើន និងពុំសូវមានប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការទូទាំងប្រទេស។ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធត្រូវបាន

អនុម័តឡើង ក្នុងគោលបំណងដើម្បីធ្វើការចុះបញ្ជីតំបន់ជាច្រើនក្នុងពេលតែមួយ។[៦] ដោយមានការជួយឧបត្ថម្ភពីជំនួយអន្តរជាតិ រួមបញ្ចូលទាំងធនាគារពិភពលោក និង រដ្ឋាភិបាលហ្វាំងឡង់ដ៍ និងអាឡឺម៉ង់ ដើម្បីសម្រេចឲ្យបាននូវការចុះបញ្ជីជាទ្រង់ទ្រាយធំ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឲ្យមានគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) កើតមានឡើង។ កម្មវិធីរយៈពេល ៥ឆ្នាំ ត្រូវបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ ២០០២ តែត្រូវបានពន្យារយៈពេលបន្ត ២ឆ្នាំទៀត រហូតដល់ឆ្នាំ ២០០៧ ដោយមានគោលបំណងចេញប័ណ្ណកម្មសិទ្ធិឲ្យបានចំនួនមួយលានប័ណ្ណ នៅក្នុងខេត្តចំនួន ១០ និងរាជធានីភ្នំពេញ (World Vision និង NGO Forum ២០១២)។

សមាសភាគសំខាន់មួយនៃគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីនេះ ទាក់ទិនទៅនឹងដំណើរការមួយនៃការចុះបញ្ជីដ៏ច្រើនលើសលប់ ដែលក្រុមការងារចុះបញ្ជីបានចុះទៅមូលដ្ឋានផ្ទាល់ដើម្បីជួបជាមួយអ្នកភូមិ ធ្វើផែនទីគ្រប់ក្បាលដីនៅក្នុងភូមិ និងសម្គាល់ក្បាលដីជាមួយម្ចាស់ដីរៀងៗខ្លួន។ ក្រុមការងារចុះបញ្ជីនោះបានបង្កើតជាផែនទីភូមិមួយ ដែលបានបិទផ្សាយរយៈពេល ៣០ ថ្ងៃ ដើម្បីជាការទុកឱកាសអោយម្ចាស់ដីដែលចង់ធ្វើការតវ៉ាចំពោះការវាស់វែងក្បាលដីនេះ។ ប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានចេញជូនម្ចាស់ក្បាលដីទាំងឡាយណាដែលគ្មានការតវ៉ា កំឡុងពេលបិទផ្សាយ ចំណែកក្បាលដីដែលមានការតវ៉ា ត្រូវរក្សាទុកមិនចេញប័ណ្ណកម្មសិទ្ធិឲ្យ ដើម្បីធ្វើការវិនិច្ឆ័យដាច់ដោយឡែក បន្ទាប់ពីដំណើរការដោះស្រាយជម្លោះបន្តបន្ទាប់ ការធ្វើបែបនេះគឺក្នុងគោលបំណងជៀសវាងការរំខាន ឬពន្យាពេលដល់ការចេញប័ណ្ណកម្មសិទ្ធិដល់អ្នកភូមិទាំងឡាយដែលមិនមានបញ្ហាតវ៉ាចំពោះក្បាលដី។ មកដល់ចុងគម្រោងក្នុងឆ្នាំ ២០០៩ គោលដៅចំបងនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធត្រូវបានសម្រេច។ ជិត ១,៧ លានក្បាលដី ត្រូវបានអង្កេតវាស់វែង និងវិនិច្ឆ័យ ដែលក្នុងនោះប័ណ្ណកម្មសិទ្ធិជិត ១,៣ លានប័ណ្ណត្រូវបានផ្តល់ជូន ហើយមន្ត្រីដោះសុរិយោដីចំនួន ១.០០០ នាក់ ត្រូវបានផ្តល់ការបណ្តុះបណ្តាល និងបំពាក់បំប៉ន។ ជាពិសេស គឺការបង្កើននូវសមត្ថភាពស្ថាប័ន នៃក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ (Anttonen, ២០១២)។

---

[៦] តាមរយៈក្រសួងដែនដីនគររូបនីយកម្ម តំលៃផ្លូវការចុះបញ្ជីដាច់ដោយឡែកមានចន្លោះពី $១២,៥ សម្រាប់ជនបទ និង $ ៨៧,៥ នៅភ្នំពេញ នៅខណៈពេលដែលការចុះឈ្មោះជាលក្ខណៈប្រព័ន្ធអស់តែប្រហែល $ ១០ ប៉ុណ្ណោះ ក្នុងមួយក្បាលដី (CCHR ២០១៣)។

## ៣.២.២ ប័ណ្ណកម្មសិទ្ធិដីធ្លីនៅភ្នំពេញ

ខណៈពេលដែលការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ហាក់មានប្រសិទ្ធភាពនៅតាមតំបន់ជនបទដែលពុំមានការតវ៉ាដោយសារតែតម្លៃដីនៅទាប ជម្លោះកើតមានឡើងនៅពេលដែលដីត្រូវបានគេវិនិច្ឆ័យរួចឡើងថ្លៃ។ ឧទាហរណ៍ នៅពេលដែលដីនោះក្លាយជាគោលដៅសម្រាប់អភិវឌ្ឍន៍ជាលក្ខណៈឯកជន (Bugalski & Pred ២០០៩)។ បញ្ហាដីធ្លីមានលក្ខណៈធ្ងន់ធ្ងរ ជាពិសេសនៅភ្នំពេញ ដោយមានសន្ទុះកើនឡើងខ្លាំងនៃទីផ្សារអចលនទ្រព្យ ជាមួយនឹងការទិញដីបង្កកទុកជាច្រើន ព្រមទាំងការវិវត្តដ៏ឆាប់រហ័សដោយឥតគ្រោងទុកនៃរាជធានី និងការកើនឡើងនូវការតាំងទីលំនៅអនាធិបតេយ្យក្នុងទីក្រុង ដែលបណ្ដាលមកពីមានការកើនឡើងនៃអ្នកចំណូលថ្មីដែលបានចាប់ផ្ដើមបោះទីតាំងនៅលើដីណាដែលនៅទំនេរ។ មកទល់ឆ្នាំ ១៩៩៤ គេបានប៉ាន់ប្រមាណថាប្រជាជនបានកើនឡើងដល់១២០.០០០នាក់ រស់នៅក្នុងតំបន់អនាធិបតេយ្យ ហើយអ្នកតាំងទីលំនៅដែលមានចំណូលទាបបានកើនឡើងដល់ ១៧៥.០០០ នាក់ នាឆ្នាំ ២០០១ (World Bank Inspection Panel, ២០១០)។

ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅភ្នំពេញ បានធ្លាក់ចុះទាបជាងគោលដៅកំណត់ ដោយក្នុងនោះក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ គ្រោងនឹងធ្វើការអង្កេតវាស់វែង និងវិនិច្ឆ័យប័ណ្ណកម្មសិទ្ធិចំនួន ១៩៨.០០០ ចន្លោះពីឆ្នាំ ២០០២ និង ២០០៧ ប៉ុន្តែមានតែ ៤០% (ស្មើនឹង ៨៣.៦៦៥ ប័ណ្ណ) ប៉ុណ្ណោះត្រូវបានធ្វើការអង្កេតវាស់វែង ហើយប័ណ្ណកម្មសិទ្ធិចំនួន ៣៨.៥០០ ត្រូវបានប្រគល់ជូនម្ចាស់ដី (Bugalski & Pred ២០០៩)។ មានការលើកឡើងជាច្រើនថាការវិវត្តន៍ដ៏យឺតយ៉ាវនៃការការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ភាគច្រើនបណ្ដាលមកពីមានចំនួននៃការផ្លៀលចេញច្រើន ពីដំណើរការផ្ដល់ប័ណ្ណកម្មសិទ្ធិនៅតំបន់ទីប្រជុំជនដែលអចលនទ្រព្យដ៏មានតម្លៃ ត្រូវបានរក្សាទុកដោយបុគ្គលមានអំណាច និងក្រុមហ៊ុន សម្រាប់ការអភិវឌ្ឍន៍។ ដូច្នេះ វាអាចនឹងក្លាយជាបញ្ហាទំនាស់បើទោះបីជាមានការអះអាងពីអ្នករស់នៅតំបន់នោះថា ពួកគាត់រស់នៅដោយស្របច្បាប់ក្តី (Bidduph ២០១៤; Bugalski & Pred ២០០៩; Grimditch & Henderson ២០០៩; World Vision និង NGO Forum ២០១២)។ នៅក្នុងករណីទាំងនោះ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ហាក់ដូចជាបានធ្វើឲ្យគ្រួសារជនងាយរងគ្រោះទទួលភាពបរាជ័យ។ ក្នុងរយៈពេលនៃគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី

កំពុងដំណើរការ មានករណីបណ្តេញចេញដោយបង្ខំកើតឡើងចំពោះអ្នកតាំងទីលំនៅដែលមានប្រាក់ចំណូលទាប ត្រូវបានកត់ត្រាទុកនៅភ្នំពេញ។ ឧទាហរណ៍នៅកោះពេជ្រ នៅតំបន់បាសាក់ និងបឹងកក់ (OHCHR ២០១២; World Bank, ២០០៩; World Vision and NGO Forum ២០១២)។ បើទោះជាមានការចង្អុលបង្ហាញថាមានហេតុការណ៍បណ្តេញចេញខ្លះ កើតមានឡើងនៅក្រៅដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធ មានគ្រួសារពាក់ព័ន្ធខ្លះបាននិយាយថាពួកគេមានភស្តុតាងនៃសិទ្ធិកាន់កាប់ ដូច្នេះពួកគាត់គួរតែបានទទួលនូវការការពារពីច្បាប់ភូមិបាលឆ្នាំ ២០០១ (Anttonen ២០១២; William ២០១៣)។

នៅក្នុងឆ្នាំ២០០៩ មានអង្គការអន្តរជាតិមួយ បានដាក់ពាក្យបណ្តឹងទៅធនាគារពិភពលោក ដែលជាម្ចាស់ជំនួយនៃកម្មវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធចំពោះករណីនៃការបណ្តេញចេញនៅបឹងកក់ ដោយបានអះអាងថាប្រព័ន្ធនៃការចុះបញ្ជីពុំបានអនុវត្តន៍ឲ្យបានត្រឹមត្រូវ។ ស្ថិតក្នុងករណីនេះ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធបានចាប់ផ្តើមនៅក្នុងតំបន់នេះក្នុងឆ្នាំ ២០០៦ ក៏ប៉ុន្តែសហគមន៍ដែលស្ថិតនៅជុំវិញបឹងនេះ ត្រូវបានផ្លៀសចេញពីដំណើរការ ដោយហេតុផលថាដីទាំងនោះ «ពុំមានអត្តសញ្ញាណកម្មច្បាស់លាស់»។ ទោះជាយ៉ាងណា រដ្ឋាភិបាលបានជួលដីនោះឲ្យទៅក្រុមហ៊ុនអភិវឌ្ឍន៍មួយ តាមរយៈការធ្វើចំណាត់ថ្នាក់ឡើងវិញពីដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ។ ទោះបីជាមានប្រជាជនរស់នៅទីនោះមុនឆ្នាំ ២០០១ និងបានអះអាងថាពួកគាត់មានប័ណ្ណកម្មសិទ្ធិដីធ្លីមិនផ្លូវការក៏ពួកគាត់ក្បាលដីរបស់ពួកគាត់ ពុំត្រូវបានចុះបញ្ជីកត់ត្រាទុកក្នុងដំណើរការវិនិច្ឆ័យឡើយ។ ផ្ទុយទៅវិញពួកគាត់បែជាទទួលបាននូវសេចក្តីជូនដំណឹងពីការបណ្តេញចេញទៅវិញ។ នៅក្នុងឆ្នាំ ២០០៨ ក្រុមហ៊ុនអភិវឌ្ឍន៍បានចាប់ផ្តើមចាក់ខ្សាច់បំពេញបឹង បណ្តាលឲ្យមានទឹកជំនន់លិចផ្ទះសម្បែងរបស់ប្រជាជនក្នុងពេលដំណើរការនោះ។ គ្រួសារភាគច្រើនបានចាកចេញពីទីលំនៅរបស់ខ្លួនដោយបានទទួលសំណងជាអប្បបរិមា ឬត្រូវបណ្តេញចេញដោយបង្ខំ។ ការស៊ើបអង្កេតដោយគណៈកម្មការធនាគារពិភពលោកបានរកឃើញថា ធនាគារមានការផ្តាំផ្ញើឆ្គងក្នុងការអនុវត្តកាតព្វកិច្ចត្រួតពិនិត្យរបស់ខ្លួន និងមានការបំពានយ៉ាងធ្ងន់ធ្ងរលើគោលនយោបាយគាំពាររបស់ធនាគារ (Bank's safeguard policis) ដែលបណ្តាលអោយផលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រជាជននៅក្នុងតំបន់ (Biddulph ២០១៤; Bugalski & Pred ២០០៩; World Bank Inspection Panel ២០១០)។ នៅខែកញ្ញា ឆ្នាំ២០០៩ ធនាគារពិភពលោក

បានសម្រេចផ្អាកជាបណ្ដោះ អាសន្ននូវហិរញ្ញប្បទានសម្រាប់គម្រោងនោះ លុះត្រាតែរដ្ឋាភិបាលកម្ពុជាប្ដេជ្ញាចិត្តបញ្ឈប់នូវរាល់សកម្មភាពបណ្ដេញចេញ ដោយខុសច្បាប់ទាំងនោះ។ ក្រោយមកត្រូវបានតបវិញដោយការប្រកាសលុបចោលនៃគម្រោងនេះ ដោយសារធនាគារបានផ្ដល់នូវលក្ខខណ្ឌពិបាកៗច្រើនពេក។

ទោះបីជាធនាគារពិភពលោកបានដកខ្លួនចេញក៏ដោយ ក៏ប៉ុន្តែកម្មវិធីចុះបញ្ជីនៅតែបន្តក្រោមកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ដោយមានជំនួយពីទីភ្នាក់ងារអភិវឌ្ឍន៍កាណាដា ហ្វាំងឡង់ដ៍ និងអាល្លឺម៉ង់។ កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីថ្មីត្រូវបានដាក់ឲ្យអនុវត្តន៍នៅក្នុងខេត្តក្រុងទាំង ១៥ និងភ្នំពេញ។ ប៉ុន្តែតាមរយៈការសិក្សារបស់ World Vision and NGOF (២០១២) បានបង្ហាញថា ដំណើរការចុះបញ្ជីថ្មីនេះបានអនុវត្តប្រហាក់ប្រហែលនឹងគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ដែលបានប្រព្រឹត្តទៅយ៉ាងឆាប់រហ័សនៅតំបន់ស្រែចម្ការដែលមិនមានវិវាទ តែមានភាពយឺតយ៉ាវ និងផ្លៀលចេញច្រើនចំពោះការចុះបញ្ជីដីធ្លីនៅក្នុងតំបន់ទីប្រជុំជន ដែលអាចនឹងមានជម្លោះ និងទទួលរងការរិះគន់ឥតឈប់ឈរអំពីភាពខ្វះតម្លាភាព និងការដណ្ដើមយកដី (Biddulph ២០១៤; William ២០១៣)។

នៅក្នុងខែ ឧសភា ឆ្នាំ ២០១០ រាជរដ្ឋាភិបាលកម្ពុជា បានចេញនូវសរាចរមួយ ស្ដីអំពីដំណោះស្រាយចំពោះការតាំងទីលំនៅបណ្ដោះអាសន្នដោយខុសច្បាប់នៅលើដីរដ្ឋដែលបានកាន់កាប់នៅក្នុងរាជធានី ក្រុង និងទីប្រជុំជន (សារាចរលេខ ០៣)។ នៅក្នុងសរាចរនោះ បានបង្ហាញនូវជំហានដើម្បីដោះស្រាយករណីសហគមន៍ដែលកំពុងរស់នៅលើដីសាធារណៈរបស់រដ្ឋ និងមិនអាចទាមទារសិទ្ធិកាន់កាប់បាន បើទោះបីជាគាត់បានមករស់នៅទីនោះមុនច្បាប់ភូមិបាលឆ្នាំ ២០០១ ក៏ដោយ។[៧] ជំហានទាំងនេះគួរតែមានការចូលរួមដោយអាជ្ញាធរថ្នាក់មូលដ្ឋាន ក្រុមសហគមន៍ និងអង្គការសង្គមស៊ីវិលដែលរួមមាន ១) ការប្រមូលទិន្នន័យពីទីតាំងស្នាក់នៅជាបណ្ដោះអាសន្ន ២) ធ្វើអត្តសញ្ញាណកម្មផែនទី និងចំណាត់ថ្នាក់ដី ទីតាំងលំនៅបណ្ដោះអាសន្ន ៣) ធ្វើជំរឿនចំនួនគ្រួសារ និងសមាជិកក្នុងគ្រួសារនៅទីតាំងនោះ ៤) ស្វែងរក និងពិភាក្សាអំពីជម្រើសសម្រាប់ធ្វើការដោះស្រាយបញ្ហាតាំងទីលំនៅទាំងនោះ។ ជម្រើសនៃការដោះស្រាយរួមមាន ការអភិវឌ្ឍនៅនឹងកន្លែង ការប្ដូរឲ្យ

[៧] សារាចរលេខ០៣ មិនមែនជាច្បាប់ទេ ហើយអ្នកពាក់ពន្ធ័ក្នុងការអនុវត្តសារាចរនេះ តែងហៅ វាថាជា "ឧបករណ៍រដ្ឋបាល" ដែលមានសារជាតិបទបែន (Lindstrom, ២០១៣)។

ទៅនៅទីតាំងថ្មីប្រសិនបើទីតាំងចាស់ពុំអាចអភិវឌ្ឍន៍បាន និងដោះស្រាយតាមទំរង់ផ្សេងៗទៀត «ដោះស្រាយតាមករណីជាក់ស្តែង» (ការរៀបរាប់ លម្អិត និងវិភាគ សូមមើលនៅក្នុង Lindström, ២០១៣)។

កម្មសិទ្ធិដីធ្លី និងសុវត្ថិភាពសិទ្ធិកាន់កាប់ គឺជាបញ្ហាចម្បងនៅក្នុងសង្គមកម្ពុជាសម័យទំនើប ជាពិសេសបន្ទាប់ពីមានការកែទម្រង់យ៉ាងខ្លាំង និងការជន្លៀសប្រជាជនដ៏សម្បើមក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ ក្របខណ្ឌច្បាប់ថ្មីមួយត្រូវបានបង្កើតឡើងដើម្បីដោះស្រាយវិវាទ និងពង្រឹងសុវត្ថិភាពសិទ្ធិកាន់កាប់ ក៏ដូចជាការពារសិទ្ធិរបស់ប្រជាជនក្នុងសហគមន៍។ ស្ថិតនៅក្រោមក្របខណ្ឌនេះយុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិត្រូវបានចាប់ផ្តើមក្នុងឆ្នាំ ២០០២។ តាមរយៈរាជរដ្ឋាភិបាលកម្ពុជា ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំបានចេញប័ណ្ណកម្មសិទ្ធិដីធ្លីចំនួន ៣ លានប័ណ្ណ មកទល់ខែកញ្ញាឆ្នាំ ២០១៣ (CCHR, ២០១៣, ទំព័រទី១៧)។ ទោះបីជាទទួលបានភាពជោគជ័យយ៉ាងខ្លាំងក្នុងការចុះបញ្ជី តែការព្រួយបារម្ភនៅតែមានចំពោះការចុះបញ្ជីដែលមិនបានបង្កើនសុវត្ថិភាពដីធ្លី និងការការពារក្រុមជនងាយរងគ្រោះនៅតំបន់ប្រជុំជន បើទោះជាពួកគេមានភាពស្របច្បាប់ក្នុងការទាមទារដីក៏ដោយ។ ឧទាហរណ៍ មានករណីជាច្រើននៃសហគមន៍ ដែលមានឯកសារត្រឹមត្រូវបញ្ជាក់ពីសិទ្ធិកាន់កាប់តាំងពីយូរណាស់មកហើយក្តី ក៏ពួកគាត់នៅតែពុំត្រូវបានរាប់បញ្ចូលក្នុងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធដែរ ឬត្រូវផ្លៀលចេញក្នុងអំឡុងពេលដំណើរការនៃការចុះបញ្ជី។ បញ្ហានេះកើតមានឡើង ជាពិសេសចំពោះគ្រួសារក្រីក្រដែលរស់នៅទីប្រជុំជនលើដីដែលជាគោលដៅសម្រាប់ការអភិវឌ្ឍលក្ខណៈឯកជន ដែលគ្រួសារទាំងនោះនៅតែប្រឈមនឹងហានិភ័យនៃការបណ្តេញចេញ ឬមិនឲ្យកាន់កាប់ (Grimsditch & Henderson, ២០០៩)។ Grimditch និង Henderson (២០០៩, ទំព័រ៧) បានតវ៉ាថា «នៅពេលដែលមានការផ្តោតការយកចិត្តទុកដាក់ចំពោះតែការចេញប័ណ្ណកម្មសិទ្ធិជូនកន្លែងដែលមានសុវត្ថិភាពពីការបណ្តេញចេញ ប៉ុន្តែមានការផ្លៀលចេញនូវសហគមន៍ ដែលស្ថិតនៅក្នុងហានិភ័យនៃការគ្មានលំនៅឋានទាំងនៅទីប្រជុំជន និងទីជនបទ វាបានបង្ករអោយមានប្រព័ន្ធវិសមភាពកើតមានឡើងមុនពេលមានកម្មវិធីរៀបចំដែនដី និងរដ្ឋបាលដីធ្លី។ ការផ្លៀលចេញដែលមានទ្រង់ទ្រាយធំហាក់ដូចជាបានកើតឡើងនៅទីប្រជុំជនច្រើនជាងនៅតំបន់ជនបទ។ ឧទាហរណ៍ នៅក្នុងការសិក្សាមួយរបស់ World Vision និង NGO Forum (២០១២) ការផ្លៀលចេញ

ច្រើនតែអាចកើតមាននៅតាមទីប្រជុំជននៃរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ជាងទីកន្លែងដទៃទៀត។ នៅផ្នែកបន្ទាប់នឹងបង្ហាញពីដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ បញ្ហាទាំងឡាយដែលកើតមានឡើងតាមរយៈការផ្លៀលចេញពីដំណើរការ និងផលប៉ះពាល់ដែលអាចកើតមានចំពោះសហគមន៍ដែលត្រូវបានផ្លៀលចេញ។

### *៣.២.៣ ដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងដែនកំណត់របស់វា*

ច្បាប់ភូមិបាល ឆ្នាំ២០០១ បានបង្ហាញនូវមូលដ្ឋានគ្រឹះសម្រាប់ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធដែលត្រូវបានបង្ហាញលម្អិតបន្ថែមទៀតនៅក្នុងឆ្នាំ ២០០២ ដោយ*អនុក្រឹត្យលេខ៤៦ ស្តីអំពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី*។ ដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធមាន ៥ ដំណាក់កាលសំខាន់ៗ៖ ការត្រៀមរៀបចំ ការប្រតិបត្តិការបច្ចេកទេស ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ការសម្រេចលើឯកសារនៃការវិនិច្ឆ័យ និងដំណាក់កាលចុះបញ្ជី ចេញប័ណ្ណ និងចែកប័ណ្ណ៖

១. **ដំណាក់កាលត្រៀមរៀបចំ៖** អភិបាលរាជធានី ខេត្ត ក្រុង ធ្វើការជ្រើសរើស និងប្រកាសតំបន់សម្រាប់ធ្វើការវិនិច្ឆ័យ ហើយចាត់តាំងគណៈកម្មការរដ្ឋបាល ដែលរួមមានសមាជិកពីមន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដីមូលដ្ឋាន មន្ត្រីមូលដ្ឋាន និងអ្នកតំណាងពីភូមិនីមួយៗ។ ការប្រជុំជាសាធារណៈមួយត្រូវបានធ្វើ ឡើងក្នុងទីតាំងវិនិច្ឆ័យនីមួយៗ ដែលមានប្រធានក្រុមចុះបញ្ជីដីធ្លី[៨] ធ្វើការពន្យល់បកស្រាយអំពីដំណើរការនៃចុះបញ្ជីដីធ្លី និងឆ្លើយសំណួរទាំងឡាយដែលពាក់ព័ន្ធនៅក្នុងពេលប្រជុំ។

២. **ដំណាក់កាលប្រតិបត្តិការបច្ចេកទេស៖** ក្រោយពីដំណាក់កាលត្រៀមក្រុមការងារចុះបញ្ជី ចុះទៅជួបគ្រួសារក្នុងទីតាំងវិនិច្ឆ័យ ដើម្បីកត់ត្រាអំណះ

---

[៨] ក្រុមចុះបញ្ជីដីធ្លីរួមមានអ្នកវិនិច្ឆ័យដី អ្នកអង្កេតវាស់វែង អ្នកកំណត់តំបន់ភូមិសាស្ត្រ អ្នកគ្រប់គ្រងព័ត៌មានភូមិសាស្ត្រ និងអ្នកបញ្ចូលទិន្នន័យ។

អំណាងកម្មសិទ្ធិ អង្កេតវាស់វែងក្បាលដី។ ប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីម្ចាស់ក្បាលដី ត្រូវបានប្រមូលទុក។

៣. **ដំណាក់កាលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ៖** ផែនទី និងបញ្ជីឈ្មោះម្ចាស់ក្បាលដី ត្រូវបានដាក់តាំងជាសាធារណៈរយៈពេល ៣០ថ្ងៃ។ គ្រួសារនីមួយៗអាចធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ទិន្នន័យថាត្រឹមត្រូវ ឬមានកំហុសហើយបានកែតម្រូវ ព្រមទាំងធ្វើការជំទាស់ និងប្តឹងបាន។

៤. **ដំណាក់កាលសម្រេចលើឯកសារនៃការវិនិច្ឆ័យ៖** បន្ទាប់ពីបានដាក់តាំងបង្ហាញជាសាធារណៈអស់រយៈពេល ៣០ថ្ងៃ មក គណៈកម្មការរដ្ឋបាលធ្វើការបញ្ជាក់លើកំណត់ត្រាក្បាលដីដែលមិនមានជម្លោះ។ កំណត់ត្រានេះត្រូវបានបញ្ជូនទៅមន្ទីរសុរិយោដីរាជធានី ខេត្ត ក្រុង ដើម្បីត្រួតពិនិត្យលើលក្ខណៈបច្ចេកទេស និងចុះហត្ថលេខាដោយអភិបាលខេត្ត/ក្រុង ។

៥. **ដំណាក់កាលចុះបញ្ជី ចេញប័ណ្ណ និងចែកប័ណ្ណ៖** ដំណើរការនេះត្រូវបានបញ្ចប់ដោយការចុះបញ្ជី និងចេញប័ណ្ណកម្មសិទ្ធិ ។

ដំណើរការនេះគួរតែមានតម្លាភាព ហើយម្ចាស់ដែលមិនពេញចិត្តនឹងសេចក្តីសម្រេចនេះ អាចមានលទ្ធភាពដាក់ពាក្យបណ្តឹង (ព័ត៌មានលម្អិត សូមអានរបាយការណ៍ World Vision និង NGO Forum ២០១២)។ ប្រសិនបើមានវិវាទកើតឡើងក្នុងអំឡុងពេលអង្កេតវាស់វែង ឬក្នុងតំណាក់កាលបិទផ្សាយភាគីទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យធ្វើការសម្របសម្រួលទំនាស់ ដោយមានការជួយសម្របសម្រួលពីគណៈកម្មការរដ្ឋបាល។ ករណីដែលជម្លោះមិនអាចដោះស្រាយបាន បញ្ហានេះត្រូវបញ្ជូនបន្តទៅកាន់គណៈកម្មការសុរិយោដី។ អង្គភាពដោះស្រាយវិវាទត្រូវបានបង្កើតឡើងក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីដោះស្រាយបញ្ហាដីមិនទាន់ចុះបញ្ជី។[៩] ដីធ្លីមិនអាចចុះបញ្ជីបានឡើយ ដរាបណាទំនាស់មិនត្រូវបានដោះស្រាយរួចរាល់។

---

[៩] តួនាទីរបស់គណៈកម្មការសុរិយោដី បានកំណត់នៅក្នុងអនុក្រឹត្យឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។ យន្តការមួយទៀតនៃការដោះស្រាយវិវាទ គឺអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លីដែលបានកើតឡើងនៅក្នុងឆ្នាំ ២០០៦។ យ៉ាងណាមិញ វាល់វិវាទដែលកើតមានឡើងក្នុងអំឡុងពេលចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ជាទូទៅច្រើនតែបញ្ជូនទៅគណៈកម្មការសុរិយោដី ដែលត្រូវដោះស្រាយរាល់វិវាទលើដីមិនត្រូវបានចុះបញ្ជីនៅក្នុង ឬក្រៅតំបន់វិនិច្ឆ័យ។

## ការផ្ទៀលចេញពីផែនទីរដ្ឋបាល សម្រាប់ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងដីមានស្ថានភាពមិនច្បាស់លាស់

មិនមានទិន្នន័យជាផ្លូវការណាមួយអំពីការផ្ទៀលចេញនៅភ្នំពេញទេ ប៉ុន្តែតាមរយៈការសិក្សានានាបានកត់សម្គាល់ថា មានករណីផ្ទៀលសហគមន៍ទាំងមូលជាច្រើនចេញពីដំណើរវិនិច្ឆ័យមុន ឬក្នុងកំឡុងពេលនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះ។ លើសពីនេះ ចំនួនក្បាលដីជាច្រើនមិនត្រូវបានចុះបញ្ជី ដោយសារតែមានពុំមានស្ថានភាពច្បាស់លាស់ (CCHR ២០១៣; World Vision និង NGO Forum, ២០១២)។ សមាគមធាងត្នោត (២០១៤) បានប៉ាន់ប្រមាណថា មួយភាគបួននៃការតាំងទីលំនៅរបស់ជនក្រីក្រ ដែលពួកគេបានរកឃើញនៅភ្នំពេញក្នុងឆ្នាំ២០១៣ អាចត្រូវបានផ្ទៀលចេញ។ អង្គការ NGOF បានធ្វើការសិក្សាពីដំណើរការផ្តល់បណ្ណ័កម្មសិទ្ធិតំបន់វិនិច្ឆ័យទាំងបួនក្នុងខេត្តបន្ទាយមានជ័យ កំពង់ចាម ភ្នំពេញ និងព្រះសីហនុ។ នៅក្នុងខេត្តទាំងបី[១០] ដំណើរការអនុលោមតាមបទដ្ឋានច្បាប់ ហើយទំនាស់ភាគច្រើន ត្រូវបានដោះស្រាយក្នុងកំឡុងពេលពេលដំណើរ។ យ៉ាងណាមិញ នៅភូមិទំនប់នៅភ្នំពេញ បរិមាណនៃការផ្ទៀលចេញ និងទំនាស់មានចំនួនខ្ពស់។ មកទល់ពេលបញ្ចប់ដំណើរការវិនិច្ឆ័យ ៨0% នៃក្បាលដីនៅតែពុំបានចុះបញ្ជី។[១១] មិនមានការបញ្ជាក់ផ្លូវច្បាប់ណាមួយ ត្រូវបានផ្តល់ជូនអំពីការផ្ទៀលចេញនោះ ឡើយ។ ក្បាលដីដែលពុំបានចុះបញ្ជីនេះ ត្រូវបានចាត់ទុកថា «ពុំមានស្ថានភាព ច្បាស់លាស់» ហើយជាទូទៅវាស្ថិតនៅជាប់ ឬជាន់ព្រំប្រទល់គ្នាជាមួយដីរដ្ឋ ដែលពុំមានការកំណត់ព្រំដីច្បាស់លាស់។ គ្រួសារដែលបានចូលរួមក្នុងការសម្ភាសនេះបានធ្វើការកត់សម្គាល់ថា ពួកគេទទួលបាននូវព័ត៌មានយ៉ាងតិចតួចជាទីបំផុត ដែលក្នុងនោះអ្នកខ្លះទើបតែបានដឹងថា ក្បាលដីរបស់ពួកគាត់មិនអាចទទួលបាន ប័ណ្ណកម្មសិទ្ធិក្រោយពីដំណើរការបានបញ្ចប់ ហេតុនេះពួកគាត់ពុំមានឱកាសក្នុងការធ្វើការតវ៉ាឡើយ។

---

[១០] បញ្ហាផ្ទៀលចេញនិងវិវាទត្រូវបានកត់សម្គាល់នៅខេត្តព្រះសីហនុ ដែលមានក្បាលដីប្រហែលមួយភាគបី មិនត្រូវបានចុះបញ្ជី តាមរយៈការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅពេលបញ្ចប់។

[១១] "នៅភូមិទំនប់មានគ្រួសារ ៨៦១ នៅក្នុងតំបន់វិនិច្ឆ័យ ៦៦៦ គ្រួសារត្រូវបានផ្ទៀលចេញ។ ១៩៥ ត្រូវបានធ្វើការវិនិច្ឆ័យតែ ១៥៤ ត្រូវបានចាត់ទុកថា បញ្ហាស្មុគស្មាញពេក ឬខ្វះខាតទិន្នន័យ មានតែប័ណ្ណកម្មសិទ្ធិ៤១កន្លែង ដែលត្រូវបានចេញបានចេញប័ណ្ណជូន។

មានហេតុផលផ្លូវច្បាប់ជាច្រើន ដែលបញ្ជាក់ពីមូលហេតុដែលប្រជាពលរដ្ឋមិនអាចទទួលបានបណ្ណ័កម្មសិទ្ធ តាមរយៈការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធះ ១) ដីនោះជាដីអាចមានវិវាទដែលបានកើតមានមុន ឬក្នុងកំឡុងពេលធ្វើការវិនិច្ឆ័យ ហើយវាមិនអាចចុះបញ្ជីបានដរាបណាជម្លោះមិនទាន់ដោះស្រាយរួចរាល់។ ២) អ្នកកាន់កាប់ដីអវត្តមានកំឡុងពេលដំណើរការវិនិច្ឆ័យ ហើយដីរបស់ពួកគាត់មិនត្រូវបានកត់ត្រានាពេលនោះ។ ៣) ដីនោះត្រូវបានរកឃើញថាជាដីសាធារណៈរបស់រដ្ឋ (ឧទាហរណ៍ ដីនៅតាមចិញ្ចើមផ្លូវដែក) ដែលដីនោះមិនអាចផ្តល់ជាកម្មសិទ្ធិឯកជនបានឡើយ (World Vision និង NGO Forum, ២០១២)។ ទោះជាយ៉ាងនេះក្តីក៏ពុំមានលិខិតបទដ្ឋានគតិយុត្តិណាមួយធ្វើឡើងចំពោះការផ្លៀលចេញ ឬដកក្បាលដី ឬសហគមន៍ទាំងមូលចេញពីតំបន់វិនិច្ឆ័យនោះទេ។អនុក្រឹត្យលេខ ៤៦ បានបរិយាយថាវិវាទ និងអត្តសញ្ញាណកម្មដីដែលទាមទារត្រូវតែត្រួតពិនិត្យប្រកបដោយតម្លាភាពតាមរយៈដំណើរការវិនិច្ឆ័យ។ ក្នុងនោះដែរ មិនមានទិន្នន័យជាផ្លូវការណាមួយផ្សាយជាសាធារណៈ អំពីវិសាលភាពនៃហេតុផលក្នុងការផ្លៀលចេញនោះឡើយ។ ការសិក្សាស្រាវជ្រាវកន្លងមកបានរកឃើញថា ការផ្លៀលចេញជាទូទៅកើតមានឡើងក្នុងរូបភាពគ្មានតម្លាភាព ហើយមូលហេតុចំបងពីរនៃការផ្លៀលចេញគឺ «មានភាពស្មុគស្មាញពេក»សម្រាប់ការវិនិច្ឆ័យឬក្បាលដីនោះ«មានស្ថានភាពមិនច្បាស់លាស់» (World Vision និង NGO Forum ២០១២)។ ការស្រាវជ្រាវផ្សេងទៀត ក៏បានរកឃើញផងដែរថា ការផ្លៀលចេញបែបនេះកើតមានឡើងតែនៅក្នុងសហគមន៍ក្រីក្រ។ ឧទាហរណ៍ នៅបឹងកក់ ទន្លេបាសាក់ សហគមន៍៧៨ និងភូមិទំនប់ (Hap ២០០៧; Lindstràm ២០១៣)។ មូលហេតុសម្រាប់ការកាត់តំបន់នានាចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ពុំមានការពន្យល់ស្របច្បាប់នោះឡើយ ដូច្នេះវាជាការវិនិច្ឆ័យដែលអាចបណ្តាលអោយមានការផ្លៀលដីចេញពីដំណើរការ។ ការប្រើប្រាស់ការវិនិច្ឆ័យដើម្បីផ្លៀលដីចេញដោយគ្មានឯកសារច្បាប់ កំណត់ចំពោះគ្រួសារដែលទាមទារសិទ្ធិកាន់កាប់ ពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ វាសម្តែងឲ្យឃើញនូវភាពមិនប្រក្រតី ដែលអាចអនុញ្ញាតឲ្យមានការដណ្តើមយកដីសហគមន៍ក្រីក្រពីសំណាក់ភាគីអ្នកមានអំណាច។

## កង្វះខាតការធ្វើចំណាត់ថ្នាក់ដីរបស់រដ្ឋ

មានការស្រាវជ្រាវតិចតួចណាស់ អំពីរបៀបនៃការជ្រើសរើសតំបន់វិនិច្ឆ័យសម្រាប់ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ មានការផ្តល់យោបល់ខ្លះលើកឡើងថា ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធមានគោលដៅជាចម្បងតែនៅក្នុងតំបន់ដែលអាចមានវិវាទដីធ្លីជាអប្បបរិមាប៉ុណ្ណោះ ហើយបានជៀសវាងនៅក្នុងតំបន់ណាដែលវិវាទអាចកើតមានជាទូទៅ ឬតំបន់ដែលដីមានស្ថានភាពមិនច្បាស់លាស់។ ជាការពិត នៅក្នុងការពិនិត្យឡើងវិញនៃគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ធនាគារពិភពលោកបានកត់សម្គាល់ថា ដើម្បីធ្វើការពង្រឹងសមត្ថភាពរបស់ក្រុមការងារចុះបញ្ជី និងដើម្បីជៀសវាងការអូសបន្លាយការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ការសម្រេចត្រូវបានធ្វើឡើងដោយផ្តើមមិនផ្តល់កម្មសិទ្ធិដល់ដីនៅតំបន់ណាដែលមានជម្លោះអំពីស្ថានភាពដីរដ្ឋដូចជា ដីឯកជនរបស់រដ្ឋ និងដីសាធារណៈរបស់រដ្ឋ រហូតទាល់តែអត្តសញ្ញាណកម្មទាំងនោះត្រូវបានធ្វើការបកស្រាយរួចរាល់។ ទោះបីជាដំណើរការប្រព្រឹត្តទៅនេះ អាចជាហេតុផលត្រឹមត្រូវសមស្រប ដើម្បីកុំឲ្យជាប់គាំងក្នុងដំណើរចេញប័ណ្ណក្តី តែវានៅតែបង្កើតជាបញ្ហាព្រោះថាតំបន់ទាំងនេះជាទីដែលមិនមានសុវត្ថិភាពដីធ្លីក្នុងទំហំធំធេង និងជាកន្លែងដែលមានហានិភ័យខ្ពស់បំផុតសម្រាប់ការបណ្តេញចេញ។[១២]

លើសពីនេះទៅទៀត នៅក្នុងសមាសភាពទី៥ នៃគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ការគ្រប់គ្រងដីធ្លីដែលជាគោលបំណងនៃគម្រោងបានវាយតម្លៃ កំណត់ព្រំប្រទល់ ធ្វើចំណាត់ថ្នាក់ និងធ្វើផែនទីដីឯកជនរបស់រដ្ឋ និងដីសារធារណៈរបស់រដ្ឋទាំងអស់ដោយមានការពិគ្រោះយោបល់ជាមួយនឹងសហគមន៍ និងក្រុមសង្គមស៊ីវិល។ ទាំងនេះត្រូវបានគេសន្មត់ថា នៅពេលដែលការងារនេះបានបញ្ចប់ហានិភ័យនៃវិវាទដីធ្លីអាចនឹងត្រូវបានកាត់បន្ថយ ហើយវាអាចធ្វើឲ្យដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធប្រព្រឹត្តទៅកាន់តែមានប្រសិទ្ធភាព។ ទោះយ៉ាងណា

---

[១២] បន្ថែមទៅលើកង្វះខាតនៃការកំណត់ព្រំដី និងផែនទី ដីសាធារណៈរបស់រដ្ឋអាចនឹងត្រូវបានគេធ្វើចំណាត់ថ្នាក់ឡើងវិញ ទៅជាដីឯកជនរបស់រដ្ឋ ដែលអាចលក់ រឺជួលបាន។ អនុក្រឹតលេខ ១២៩ គូសបញ្ជាក់ពីដំណើរការនោះ ក៏ប៉ុន្តែមិនមាននីតិវិធីច្បាស់លាស់ និងមិនមានបញ្ញាត្តិណាមួយពាក់ព័ន្ធនិងការប្រកាស ឬពិភាក្សាជាសាធារណៈនោះទេ។ ក្នុងករណីណាក៏ដោយ រាជរដ្ឋាភិបាលបានត្រឹមតែចេញអនុក្រឹត្យដើម្បីធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ ដោយមិនខ្វល់ពីនិតិវិធីច្បាប់នោះឡើយ ឧទាហរណ៍ដូចដែលបានកើតឡើងក្នុងករណីតំបន់បឹងកក់ជាដើម (CCHR ២០១៣)។

ក៏ការអនុវត្តសមាសភាពទី៥នេះ នៅមានកម្រិត ហើយក៏មិនមានផែនទីជាផ្លូវការសម្រាប់ដីរដ្ឋធ្វើឡើងនោះឡើយ។ ការវាយតម្លៃគម្រោងបានចង្អុលបង្ហាញពី «ភាពអវត្តមាននៃផែនទីដីរបស់រដ្ឋ [......] ដែលជាចំណុចខ្សោយដ៏សំខាន់មួយដែលត្រូវធ្វើការដោះស្រាយសម្រាប់គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ដើម្បីឈានទៅរកភាពជោគជ័យ និងជួយដោះស្រាយបញ្ហាជម្លោះដីធ្លីនានា ក៏ដូចជាសុវត្ថិភាពដីធ្លី» (World Bank ២០០៩ ទំព័រទី៦)។

បញ្ហាមួយទៀតគឺថា បើសិនជាអ្នកកាន់កាប់ដីដែលត្រូវបានចាត់ទុកថាជាដីសាធារណៈរបស់រដ្ឋ មិនអាចត្រូវបានផ្តល់ភាពជាម្ចាស់កម្មសិទ្ធិ វានៅតែមានភាពមិនច្បាស់លាស់ ថាតើបញ្ហានេះសំដៅទៅលើស្ថានភាពដីនៅពេលដែលមាន*ការកាន់កាប់ដំបូង* ឬក៏នៅក្នុងពេល*វិនិច្ឆ័យ*។ មានអ្នកកាន់កាប់ខ្លះបានបោះទីតាំងនៅលើដីទំនេរជាង ៣០ឆ្នាំ កន្លងមកហើយ តាំងពីពេលដែលដីនោះមិនទាន់បានអង្កេតវាស់វែង កត់ត្រាទុក ឬចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋទៅទៀត។ ដីប្រភេទនោះ ក្រោយមកទៀតអាចចាត់ទុកថាជាដីឯកជនរបស់រដ្ឋ ដូច្នេះវាធ្វើឲ្យមានលក្ខណៈសមស្របសម្រាប់ការកាន់កាប់ និងអាចមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិបាន (World Bank ២០១០)។ ឧទាហរណ៍ នៅដើមឆ្នាំ១៩៩០ មន្ត្រីរាជការ ត្រូវបានអនុញ្ញាតឲ្យតាំងទីលំនៅក្បែរក្រសួងរបស់រដ្ឋដែលពួកគាត់ធ្វើការ។ សុវត្ថិភាពនៃសិទ្ធិកាន់កាប់របស់ពួកគាត់ បានជួបនូវការគម្រាមកំហែងនាពេលបច្ចុប្បន្ន ពីព្រោះដីដែលគាត់បានកាន់កាប់អាចត្រូវបានចាត់ទុកថាជាដីសាធារណៈរបស់រដ្ឋ។ ទោះបីជាយ៉ាងណា វាតែងតែមិនមានភាពច្បាស់លាស់សម្រាប់ក្រសួងដែលពាក់ព័ន្ធថាតើដីពិតប្រាកដអ្វីខ្លះដែលក្រសួងកាន់កាប់ ( World Bank Inspection Panel ២០១០ )។

## ៣.៣ សហគមន៍ក្រីក្រនៅរាជធានីភ្នំពេញ

ការសិក្សាមួយរបស់សាលារាជធានីភ្នំពេញបានរាយការណ៍ថា ចន្លោះពីឆ្នាំ ១៩៨០ និង ២០១១ មានសហគមន៍ក្រីក្រចំនួន ៥១៦ ដែលមានប្រជាពលរដ្ឋចំនួន ២៥០.០០០ រស់នៅ នៅក្នុងខណ្ឌចំនួន៩ (Phnom Penh Capital ២០១២ ទំព័រទី៥)។ នៅក្នុងឆ្នាំ ២០១៣ សមាគមធាងត្នោតបានបង្ហាញថាមានសហគមន៍ក្រីក្រចំនួន ៣៩០ នៅក្នុងខណ្ឌដូចគ្នានឹងការសិក្សារបស់សាលារាជធានី (STT ២០១៤ ទំព័រទី

៨)។[១៣] តាមរយៈមន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់ រាជធានីភ្នំពេញ មកទល់ខែកញ្ញា ឆ្នាំ ២០១៤ គេរកឃើញថាមានសហគមន៍ក្រីក្រចំនួន ៥០៣ នៅក្នុងខណ្ឌទាំង១២ ក្នុងរាជធានីភ្នំពេញដែលក្នុងនោះមានប្រជាជនចំនួន ២៤.៦៦៨គ្រួសារ ឬចំនួនមនុស្ស ១៤០.១១៤ នាក់ រស់នៅ។[១៤] ភាពខុសគ្នានៃចំនួនសហគមន៍ក្រីក្រពីប្រភពទាំងបីនេះ គឺបណ្តាលមកពីនិយមន័យខុសគ្នាចំពោះពាក្យ (សហគមន៍ជាមួយការបោះទីតាំង)[១៥] និងពេលវេលានៃការប្រមូលទិន្នន័យក៏ខុសគ្នា ដែរ (សមាគមធាងត្នោតបានប្រមូលទិន្នន័យ ១៨ ទៅ ២១ខែ ក្រោយសាលារាជធានី ប៉ុន្តែ ១២ខែ មុនមន្ទីររៀបចំដែនដី នគររូបនីយកម្ម និង សំណង់ រាជធានីភ្នំពេញ)។

ចំនួនសហគមន៍ក្រីក្រនៅទីក្រុងបានកើនឡើងពី ៣៧៩ ក្នុងឆ្នាំ ១៩៩៧ ទៅចំនួន ៥៦៩ ក្នុងឆ្នាំ ២០០៣ បន្ទាប់មកបានធ្លាក់មកនៅចំនួន ៤១០ ក្នុងឆ្នាំ ២០០៩ និង ៣៤០ ក្នុងឆ្នាំ ២០១៣ (STT ២០១៤)។ លើសពីនេះ ចំនួនគ្រួសារដែលរស់នៅក្នុងសហគមន៍ក្រីក្រនៅទីក្រុងក៏បានថយចុះមកដល់ ៧.០០០គ្រួសារ ក្នុងចន្លោះឆ្នាំ ២០០៩ និង២០១៣។ ជាសរុប សហគមន៍ក្រីក្របានថយចុះនៅខណ្ឌខាងក្នុង[១៦] (ខណ្ឌ៧មករា ដូនពេញ ចំការមន និងទួលគោក) និងបានកើនឡើងនៅខណ្ឌខាងក្រៅ (ខណ្ឌដង្កោ មានជ័យ ពោធិ៍សែនជ័យ ឬស្សីកែវ និងសែនសុខ)។ ក្នុងឆ្នាំ

---

[១៣] សាលារាជធានីភ្នំពេញបានធ្វើការសិក្សានៅក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយបានសម្ភាសន៍ជាលក្ខណៈបុគ្គលតាមគ្រួសារចំនួន ២.០៣៣នាក់ និងសម្ភាសន៍ជាមួយតំណាងសហគមន៍ចំនួន ២៨១នាក់។ ការសិក្សារបស់សមាគមធាងត្នោតចាប់ផ្តើមនៅក្នុងខែឧសភា ដល់សីហា ឆ្នាំ២០១៣ ដោយមានការសម្ភាសជាមួយអ្នករស់នៅសហគមន៍ (N=២១៨) មេភូមិ (N=២១) អ្នកដឹកនាំសហគមន៍ (N=៤៧) សមាជិកគណៈកម្មការសហគមន៍ (N=១០) និងអ្នកតំណាងអ្នកបោះទីតាំង (N=៤៩) ។

[១៤] តាមការប៉ាន់ប្រមាណ គ្រួសារនៅក្នុងសហគមន៍មានសមាជិកជាមធ្យមចំនួន ៥,៦៨នាក់ (Phnom Penh Capital ២០១២ ទំព័រទី១១)។

[១៥] សមាគមធាងត្នោតផ្តោតលើការតាំងទីលំនៅរបស់ជនក្រីក្រនៅទីក្រុង ខណៈពេលដែលសាលារាជធានីផ្តោតការយកចិត្តទុកដាក់លើសហគមន៍ក្រីក្រនៅទីក្រុង។ នៅក្នុងការយល់ឃើញរបស់សាលារាជធានី ការតាំងទីលំនៅត្រូវការរៀបចំសណ្តាប់ធ្នាប់ ឧទាហរណ៍ មានមេដឹកនាំក្រុម សន្សំប្រាក់ ។ល។ ដើម្បីចាត់ទុកជាសហគមន៍។ ដូច្នេះ ការតាំងទីលំនៅអាចមានទាំងសហគមន៍ដែលមិនរៀបរយមួយ ឬលើសពីមួយ។

[១៦] «ខណ្ឌខាងក្នុងក្រុង» សំដៅទៅលើខណ្ឌទាំងឡាយណាដែលស្ថិតនៅជុំវិញកណ្តាលរាជធានីភ្នំពេញ ចំណែកឯ «ខណ្ឌខាងក្រៅ ឬជាយក្រុង»សំដៅទៅលើខណ្ឌទាំងឡាយណាដែលស្ថិតនៅឆ្ងាយពីស្នូលនៃរាជធានី ភ្នំពេញ។

១៩៩៧ សមាគមធាងត្នោតបានប៉ាន់ប្រមាណថា ៦៨% នៃសហគមន៍ក្រីក្រទាំងអស់បានតាំងទីលំនៅនៅខណ្ឌខាងក្នុង ចំណែក ៣២% តាំងទីលំនៅនៅខណ្ឌខាងក្រៅ។ ក្នុងឆ្នាំ២០១៣ និន្នាការបានផ្លាស់ប្តូរ ដែលក្នុងនោះមានសហគមន៍ក្រីក្រនៅខណ្ឌខាងក្នុងមានត្រឹមតែ ២៤% ចំណែកសហគមន៍ក្រីក្រនៅក្នុងខណ្ឌខាងក្រៅវិញមានរហូតដល់ ៧៦%។ នៅខណៈពេលដែលសហគមន៍ក្រីក្រនៅទីក្រុងបានកែលម្អ និងពង្រឹងសហគមន៍របស់ខ្លួន ដូច្នេះគេលែងហៅសហគមន៍នោះថាជាសហគមន៍ក្រីក្រទៀតឡើយ ហើយសហគមន៍តូចៗដែលមានតិចជាងដប់គ្រួសារត្រូវបានគេធ្វើសមាហរណកម្មជាមួយសហគមន៍ធំៗ។ សមាគមធាងត្នោតបានធ្វើការកត់សម្គាល់ថាការថយចុះនូវចំនួនសហគមន៍ក្រីក្រប្រមាណពាក់កណ្តាលនេះ គឺដោយសារតែការរលាយបាត់នូវសហគមន៍ក្រីក្រចំនួន ៦៤។ ក្បាលដីទាំងឡាយដែលសហគមន៍រលាយបាត់នេះបានរស់នៅពីមុន ត្រូវបានគេធ្វើការអភិវឌ្ឍន៍ឡើងវិញ ឬក៏សព្វថ្ងៃនេះនៅទំនេរ។ សមាគមធាងត្នោតបានជំទាស់ថា ការកាត់បន្ថយចំនួនសហគមន៍ក្រីក្រនេះ ប្រហែលជាសហគមន៍ទាំងនោះត្រូវបានគេផ្លាស់ទី ឬបណ្តេញចេញ។

នៅក្នុងតារាងទី៣ ខាងក្រោម បានបង្ហាញពីចំនួនសហគមន៍ក្រីក្រនៅក្នុងខណ្ឌគោលដៅទាំង៦ ដែលបានធ្លាក់ចុះពីចំនួន ២៦១ ក្នុងឆ្នាំ ១៩៩១ មកនៅ ២០៨ ក្នុងឆ្នាំ ២០១៣។

**តារាងទី៣ : ការតាំងទីលំនៅរបស់ជនក្រីក្រនៅទីក្រុង ក្នុងខណ្ឌចំនួន ៦ ពីឆ្នាំ១៩៩៧-២០១៣**

| ខណ្ឌ | ឆ្នាំ ១៩៩៧ | | ឆ្នាំ ២០០៣ | | ឆ្នាំ ២០០៩ | | ឆ្នាំ ២០១៣ | |
|---|---|---|---|---|---|---|---|---|
| | សហគមន៍ | គ្រួសារ | សហគមន៍ | គ្រួសារ | សហគមន៍ | គ្រួសារ | សហគមន៍ | គ្រួសារ |
| ចំការមន | ៦៧ | ៦៤៧៩ | ៦៨ | ៨៥៧៤ | ២៩ | ២៤២១ | ២៥ | ២២៧០ |
| ដង្កោ | ១៦ | ៩០៣ | ១៩១ | ១៩៦៩០ | ៥៩ | ៧២៩២ | ២៥ | ៣៩៧៦ |
| ដូនពេញ | ៧១ | ២៩៧០ | ៨១ | ៧១៨៨ | ៣២ | ២៣៣៧ | ១៧ | ៦១៤ |
| មានជ័យ | ៤៦ | ៦៦៥៦ | ៩៤ | ៥៣៨២ | ៩៣ | ៩០០២ | ៨៩ | ៧០១៧ |
| សែនសុខ | គ្មាន | គ្មាន | គ្មាន | គ្មាន | ៣៨ | ៤២៦០ | ៣១ | ៦២៥៥ |
| ទួលគោក | ៦០ | ៣៩១១ | ៩៨ | ៩៥៩០ | ៣៨ | ៤៩២០ | ៣១ | ២២៨៨ |
| **សរុប** | **២៦១** | **២០៩១៩** | **៤៣២** | **៥៥៣៧៤** | **២៨៩** | **៣០១៨២** | **២០៨** | **២២៤២០** |

ប្រភព (STT, ២០១៤)

## ៣.៤ ការបណ្តេញចេញ និងការបន្លាស់ទី

ចន្លោះពីឆ្នាំ១៩៩០ និង២០១១ មានប្រជាជនចំនួន ២៩.៣៥៨ គ្រួសារ (ស្មើនឹង ១៤៦.៩៧០ នាក់) ដែលរស់នៅតាមសំណង់ក្រីក្រនានាក្នុងរាជធានីភ្នំពេញ ត្រូវបានបន្លាស់ទីលំនៅ តាមរយៈផែនការបន្លាស់ទីលំនៅ ឬការបណ្តេញដោយបង្ខំ (STT ២០១១)។ នៅក្នុងឆ្នាំ២០១១ មនុស្សជាង ៣២.៤៨០ នាក់ ប្រឈមនឹងការគម្រាមបណ្តេញចេញ (HRTF ២០១១)។ ក្នុងឆ្នាំ ២០១៣ សំណង់ក្រីក្រយ៉ាងហោចណាស់ ៣៦ បានទទួលដំណឹងអំពីការបណ្តាញចេញ (STT ២០១៤ ទំព័រទី១១) ហើយគ្រួសារដែលរស់នៅក្នុងតំបន់សំណង់អនាធិបតេយ្យក្នុងកន្លែងផ្សេងទៀតនៅទូទាំងប្រទេសក៏ត្រូវបានបណ្តេញចេញដែរ។ នៅក្នុងការសិក្សារបស់អង្គការលីកាដូ បានបង្ហាញថាមានប្រជាជនចំនួន ៥៣.៧៥៨ គ្រួសារ ក្នុងរាជធានី/ខេត្ត/ក្រុង ទាំង ១៣ បានទទួលរងផលប៉ះពាល់ពីការរំលោភសិទ្ធមនុស្សពាក់ព័ន្ធនឹងបញ្ហាដីធ្លី ក្នុងចន្លោះពីឆ្នាំ ២០០៣ និង ២០០៨ (LICADHO ២០០៩ ទំព័រទី៥)។

នៅក្នុងឯកសារស្តីពី លក្ខខណ្ឌនៃការបន្លាស់ទីដោយការបណ្តេញសំណង់ក្រីក្រនៅទីក្រុងចេញ បង្ហាញថាការផ្លាស់ទៅនៅទីតាំងថ្មីជារឿយៗកើតមានឡើងក្រោមរូបភាពគម្រាមកំហែង ប្រញ៉ាប់ប្រញាល់ និងខ្វះផែនការ និងការពិចារណាអំពីការប្រឈមដែលគ្រួសារទាំងនោះនឹងជួបប្រទះនៅទីតាំងថ្មី។ ជាពិសេសកន្លែងថ្មីនោះជារឿយៗ គឺជាទីកន្លែងដែលគេយកពួកគាត់ទៅនៅដោយពុំមានការគិតគូរអំពីលំនៅឋានសមរម្យ សេវាសាធារណៈជាមូលដ្ឋាន និងពុំមានហេដ្ឋានរចនាសម្ព័ន្ធក៏ដូចជាគ្មានសេវាអប់រំ និងសេវាសុខភាព (HRFT ២០១១; STT ២០១២; UNOHCHR ២០១២)។ ជារឿយៗ ទីតាំងថ្មីទាំងនេះតែងតែស្ថិតនៅជាយក្រុងមានឱកាសការងារតិចតួច និងមិនសូវមានជម្រើស ជាហេតុនាំអោយអ្នកបានផ្លាស់ទីលំនៅត្រឡប់មករស់នៅតាមសំណង់ក្រីក្រ ដែលនៅសេសសល់កណ្តាលទីក្រុងវិញ។ អ្នកដែលទៅរស់នៅទីតាំងថ្មី ត្រូវចំណាយពេលវេលា និងប្រាក់កាសជាច្រើនដើម្បីរកប្រាក់ចំណូលក្នុងទីក្រុង។ ដោយសារមូលហេតុជាច្រើនជុំវិញលក្ខខណ្ឌរស់នៅ និងឱកាសសេដ្ឋកិច្ចសង្គមមានការថយចុះ ហើយសុវត្ថិភាពដីធ្លីមិនមានភាពប្រសើរឡើង (HRTF ២០១១)។

សហគមន៍ដែលត្រូវបានគេផ្លាស់ទីជាច្រើន មិនមានមធ្យោបាយដោយផ្ទាល់ដើម្បីទទួលបានសេវាទឹកស្អាត និងអគ្គិសនីរដ្ឋឡើយ ហើយតម្លៃប្រើប្រាស់សេវាឯកជន មានតម្លៃខ្ពស់ជាងតម្លៃធម្មតាដែលសាធារណៈជនទូទៅទទួលបាន (STT

២០១៤)។ លក្ខខណ្ឌនៃការរស់នៅរបស់ពួកគាត់ ជាទូទៅមានលក្ខណៈលំបាក ដោយសារផ្ទះតូចចង្អៀត និងគ្មានអនាម័យសុខភាព និងអនាម័យរស់នៅដែលជាកត្តាធ្វើឲ្យពួកគាត់ងាយរងគ្រោះទៅនឹងជម្ងឺផ្សេងៗ (ឧទាហរណ៍ រាករូស គ្រុនពោះវៀន គ្រុនឈាម គ្រុនចាញ់ និងជម្ងឺសើស្បែក) (NCPS ២០០៧ ទំព័រទី៩)។



# IV. លទ្ធផលនៃការសិក្សា



# IV. លទ្ធផលនៃការស្រាវជ្រាវ

## ៤.១ ព័ត៌មាននៃសហគមន៍ទាំង ១២ នៅក្នុងការសិក្សា

### *៤.១.១ សហគមន៍ថៅពញាហុក សង្កាត់បឹងកេងកង ខណ្ឌចំការមន*



*ផ្ទះសម្បែងនៅតាមផ្លូវលេខ៣៨០ ក្នុងសហគមន៍ក្រីនៅទីក្រុង*

សហគមន៍ ថៅពញាហុក មានទីតាំងនៅក្បែរផ្សារ និងសាលារៀនបឹងកេងកង តាមចិញ្ចើមផ្លូវលេខ៣៨០ ចន្លោះផ្លូវលេខ ៦៣ និងមហាវិថីព្រះនរោត្តម។ ផ្លូវនេះជាផ្លូវ ដែលមានសភាពអ៊ូរអរហើយហ៊ុំព័ទ្ធ ទៅដោយអគារជួលស្នាក់នៅនានា ហើយសំណង់ខ្លះកំពុងសាងសង់។ មានប្រជាជនចំនួន ៣០គ្រួសារ បានស្នាក់នៅទីនោះតាំងពីឆ្នាំ ១៩៩០។ គ្រួសារទាំងនោះមានប្លង់ទន់ តែសហគមន៍នេះត្រូវបានគេផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

សេវាសាធារណៈដូចជា ទឹក អគ្គិសនី ប្រព័ន្ធលូ និងសេវាប្រមូលសំរាមគឺមានសព្វគ្រប់សម្រាប់សហគមន៍នេះ។ ផ្ទះឈើមានសភាពតូចចង្អៀត ភាគច្រើនមានដំបូលស័ង្កសី និងខ្លះទៀតមានដំបូលផ្គុំឡើងដោយបន្ទះលោហៈផ្សេងៗ។ នៅទីតាំងជុំវិញសហគមន៍ និងផ្លូវថ្នល់មានសភាពស្អាតដោយគ្មានសំរាមរប៉ាត់រប៉ាយឡើយ។ ផ្ទះជាច្រើន រួមបញ្ចូលទាំងផ្ទះលក់ទំនិញ ឬតូបតូចតាចផងដែរនោះត្រូវបានធ្វើនៅខាងមុខផ្ទះ ដោយទុកចន្លោះខាងក្រោយសម្រាប់រស់នៅ។ មុខរបរទាំងនោះរួមមានទាំងហាងកាហ្វេ ជួសជុលកង់-ម៉ូតូ បោកគក់ កាត់សំលៀកបំពាក់ និងកាត់សក់ជាដើម។ ប្រជាជនភាគច្រើន ហាក់ដូចជារស់នៅដោយប្រកបរបរតាមរយៈផ្ទះរបស់ពួកគាត់ដោយសារតំបន់នោះនៅជាប់ផ្សារ។ ប្រជាជននៅទីនោះនឹងបាត់បង់មុខរបរ និងជីវភាព ប្រសិនបើពួកគាត់ត្រូវបានគេបណ្តេញចេញ។

### ៤.១.២ សហគមន៍បឹងត្របែក សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន



ផ្ទះជាច្រើននៅសហគមន៍បឹងត្របែក សង់ពីលើប្រឡាយទឹកស្អុយ

សហគមន៍នេះ គឺជាផ្នែកមួយនៃភូមិ៥ ដែលមានប្រជាជនប្រហែល ២០០គ្រួសារ ក្នុងចំណោម ៣៥០ គ្រួសារ រស់នៅតាមប្រឡាយទឹកស្អុយ ដែលហូរទៅស្ថានីយបូមទឹក ចុះពីផ្លូវលេខ ២៧១ បន្តិច។ លំនៅឋានទាំង ២០០ខ្នងនោះ មានលក្ខណៈទ្រុឌទ្រោម និងតូចចង្អៀត។ យ៉ាងហោចណាស់ ៦០ខ្នងផ្ទះបានសាងសង់ ពីលើទំបន់ទឹកស្អុយកខ្វក់ដែលជាប្រព័ន្ធប្រឡាយចំហរនេះ។ គ្រួសារភាគច្រើនជាអ្នកដើររើសអេតចាយ ហើយខ្លះជាអ្នកទិញលក់អេតចាយជាលក្ខណៈតូចតាច។ សម្រាប់អ្នកដែលចូលមករស់នៅក្នុងសហគមន៍នេះចន្លោះពីឆ្នាំ ១៩៧៩ ដល់ ១៩៩០ មានប្លង់ទន់សម្រាប់អចលនទ្រព្យរបស់ពួកគេ ក៏ប៉ុន្តែសហគមន៍ទាំងមូលត្រូវបានគេប្រាប់ជាចំហរថាពួកគាត់ត្រូវបានផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

### ៤.១.៣ សហគមន៍ភូមិអ្នកតា សង្កាត់ជើងឯក ខណ្ឌដង្កោ



លំនៅឋានទ្រុឌទ្រោមនៅក្នុងភូមិអ្នកតា

សហគមន៍ ដ៏តូចមួយនេះ មានប្រជាជនតែចំនួន១០គ្រួសារប៉ុណ្ណោះ ហើយបានកកើតមានឡើង តាំងពីដើមឆ្នាំ ១៩៨០ មកម្ល៉េះ។ សហគមន៍នេះ ក៏ជាផ្នែកមួយនៃភូមិរលួសដែលបានឆ្លងកាត់ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងបានផ្តល់ប័ណ្ណកម្មសិទ្ធ។ យ៉ាងណាមិញ សហគមន៍នេះត្រូវ

បានផ្ទៀលចេញជាផ្លូវការពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ព្រោះវាបានសង់នៅជុំវិញទីសក្ការៈដែលគេទុកឲ្យនៅទំនេរដើម្បីអោយសាធារណៈជន អាចប្រើប្រាស់សម្រាប់សកម្មភាពនានារបស់ឃុំបាន។ ទោះបីជាគេយល់ថាតំបន់នេះនៅអាចប្រើប្រាស់បានក៏ដោយ ក៏ទីសក្ការៈនេះ មានលក្ខណៈទ្រុឌទ្រោមដោយពុំមានរូបបដិមាករ ឬគ្រឿងតុបតែលម្អអ្វីនោះទេ។ គ្រួសារដែលនៅក្នុងសហគមន៍ដ៏តូចនេះពុំមានប័ណ្ណកម្មសិទ្ធិឡើយ ហើយទីតាំងដែលនៅជុំវិញភូមិអ្នកតានេះគឺជាតំបន់ពាក់កណ្តាលជនបទ និងពាក់កណ្តាល ឧស្សាហកម្មដែលមានរោងចក្រធំៗមួយចំនួននៅទីនោះ។ ផ្ទះឈើតូចតាចជាច្រើនមានសភាពទ្រុឌទ្រោម និងហាក់បីដូចជាសហគមន៍សំណង់អនាធិបតេយ្យក្រីក្រ។ តំបន់នេះមានលក្ខណៈភក់ជ្រាំ និងសំរាមពាសវាលពាសកាល។ ប្រជាជននៅទីនោះ ប្រកបរបរចិញ្ចឹមជីវិតដោយការនេសាទត្រី នៅបឹងក្បែរនោះ បេះ និងលក់ត្រួយស្លឹកអំពិល។ នៅក្នុងសហគមន៍ដ៏តូចមួយនេះ ពុំមានជំនួញ ឬតូបលក់ដូរតូចតាចនោះទេ ប៉ុន្តែមានផ្ទះលក់ទឹក និងរបស់របរប្រើប្រាស់ទទួលទានប្រចាំថ្ងៃនៅច្រកចូលទៅក្នុងសហគមន៍។ ច្រកចូលទៅក្នុងសហគមន៍នេះមានលក្ខណៈតូចចង្អៀតដែលពុំអាច ឲ្យរថយន្តពន្លត់អគ្គីភ័យអាចចូលបាន ប្រសិនមានករណីអគ្គីភ័យកើតមានជាយថាហេតុ។ ប្រព័ន្ធទឹកស្អាត និងអគ្គិសនីមានទៅដល់ទីនោះ ប៉ុន្តែប្រជាជនពុំមានលទ្ធភាពចំណាយប្រាក់សម្រាប់ការតភ្ជាប់សេវាទេ ហើយពួកគាត់ទិញសេវាទឹក និងអគ្គិសនីពីអ្នកជិតខាងវិញ។

### ៤.១.៤ សហគមន៍ចេក សង្កាត់ជើងឯក ខណ្ឌដង្កោ

សហគមន៍ចេក ស្ថិតនៅភាគខាងត្បូង នៃរាជធានីភ្នំពេញ ហើយមានប្រជាជនចំនួន ២៧៨ គ្រួសារ។ នៅភូមិនេះមានភ្ជាប់តែប្រព័ន្ធអគ្គិសនីរដ្ឋ ក៏ប៉ុន្តែពុំមានសេវាផ្សេងពីនេះទេ។ ក្នុងឆ្នាំ ២០១២ គ្រួសារភាគច្រើនបានទទួលប័ណ្ណកម្មសិទ្ធិ លើអចលនទ្រព្យរបស់ពួកគេ តាមរយៈការចុះបញ្ជីដីធ្លី មានលក្ខណៈ



*សហគមន៍ចេកដែលសាងសង់នៅតាមដងផ្លូវបង្ហូរទឹក*

ជាប្រព័ន្ធ លើកលែងតែប្រជាជនចំនួន ៣០គ្រួសារ ប៉ុណ្ណោះ ដែលត្រូវបានផ្លៀលចេញពីដំណើរការចុះបញ្ជីនេះ។ ហេតុផលនៃការផ្លៀលចេញនេះ ពុំត្រូវបានបញ្ជាក់ប្រាប់ជាផ្លូវការឡើយ ដូច្នេះ គេនៅមិនច្បាស់ថាមកពីសហគមន៍នេះបានបង្កើតឡើងលើផ្លូវបង្ហូរទឹកដែលភ្ជាប់ទឹកទៅអាងស្តុកទឹក ឬយ៉ាងណានោះទេ។ គ្រួសារសឹងតែទាំងអស់រស់នៅក្នុងស្ថានភាពក្រីក្រ ហើយទីតាំងរស់នៅមានលក្ខណៈជាសំណង់អនាធិបតេយ្យ។ គ្រួសារខ្លះបានតាំងទីលំនៅនៅទីនេះតាំងពីពាក់កណ្តាល ឆ្នាំ ១៩៨០ ហើយពួកគេប្រកបរបរដោយប្រើប្រាស់កម្លាំងដូចជា នេសាទ រត់ម៉ូតូធ្វើកម្មករ ឬបេះបន្លែត្រកួនតាមបឹងសម្រាប់លក់។ មានអ្នកភូមិជាច្រើនធ្លាប់រស់នៅលើកន្លែងដែលគេចុះបញ្ជីអោយនៅក្នុងភូមិនេះ តែពួកគាត់បានផ្លាស់ប្តូរទីតាំងមករស់នៅលើដីនៅក្នុងសហគមន៍ក្រីក្រ ដែលជាកន្លែងដែលគេកាត់ចេញពីការចុះបញ្ជីនេះ ដោយសារតែពួកគាត់ត្រូវបង្ខំចិត្តលក់ដីនោះ ដើម្បីដោះស្រាយអាសន្នអន់ក្ររបស់ក្រុមគ្រួសារ ឬក៏ពួកគាត់ត្រូវចាកចេញពីបន្ទុកឪពុកម្តាយដោយសារតែរៀបការមានក្រុមគ្រួសារថ្មី។

### ៤.១.៥ សហគមន៍ផ្លូវរថភ្លើង សង្កាត់ស្រះចក ខណ្ឌដូនពេញ



ប្រជាជននៅក្នុងសហគមន៍ផ្លូវរភ្លើង ប្រមាណ ៥០គ្រួសារដែលរស់នៅតាមបណ្តោយផ្លូវរថភ្លើង

សហគមន៍នេះ មានទីតាំងជាប់បណ្តោយរបងអភិវឌ្ឍន៍ តំបន់បឹងកក់ប៉ែកខាងកើត។ ភូមិនេះជាជំរកសម្រាប់ប្រជាជនចំនួន ២២៨ គ្រួសារ ក៏ប៉ុន្តែមាន៥១ គ្រួសាររស់នៅដោយផ្ទាល់ តាមបណ្តោយផ្លូវរថភ្លើង ដែលជាហេតុផលឲ្យនៃការផ្លៀលចេញរបស់អាជ្ញាធរ។ សហគមន៍នេះ ដើមឡើយបានមកតាំងទីលំនៅ នៅអំឡុងឆ្នាំ ១៩៩៤។ សព្វថ្ងៃនេះនៅពុំទាន់មានផែនការបណ្តេញ និងអភិវឌ្ឍន៍ឡើងវិញនៅឡើយទេ។

នៅទីនោះមានបណ្តាញទឹក និងអគ្គិសនីទៅដល់ ហើយមានតែមុខរបរតាមផ្ទះតូចតាច និងកូនហាងតូចៗប៉ុណ្ណោះ។ លំនៅឋានភាគច្រើនធ្វើអំពីឈើ មានខ្លះធ្វើ

អំពីស៊ីម៉ង់ត៍ ប៉ុន្តែផ្ទះទាំងនោះកំពុងទ្រុឌទ្រោម ហើយមានទំហំតូចចង្អៀត ៤ម៉ែត្រគុណ ៤ ម៉ែត្រ និងភាគច្រើនសង់នៅផ្ទាល់ដី។ ផ្លូវកាត់សហគមន៍មានលក្ខណៈយ៉ាប់យ៉ឺន ដោយមានជង្ហុកធំៗពោរពេញទៅដោយទឹក។ មានមាន់ ទាជាច្រើនរត់ឆ្វេចឆ្វាច និងមានក្មេងៗជាច្រើនរត់លេងតាមផ្លូវ ឬលេងទឹក។ គំនរសំរាមកាន់តែគរច្រើនឡើងៗនៅក្បែររបង ហើយតំបន់ទាំងមូលហាក់ដូចជាខ្វះភាពអនាម័យ។ ស្ថានភាពតំបន់ នោះកាន់តែមានភាពរញ៉េរញ៉ៃខ្លាំងឡើងនៅពេលដែលយើងកាន់តែដើរចូលទៅ តាមច្រកតូចៗដែលឆ្ងាយពីផ្លូវធំ។

### *៤.១.៦ ប្លុកតាន់ប៉ា សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ*



*សហគមន៍ប្លុកតាន់ប៉ា១ មានសភាពស្អាត និងសុវត្ថិភាព*

សហគមន៍ លើដំបូលប្លុកតាន់ប៉ាទាំង២ ស្ថិតនៅក្បែរផ្សារថ្មី។ សំណង់នៅសហគមន៍នេះបានកសាងឡើង លើដំបូលអាគារធំៗពីរ។ ប្លុកតាន់ប៉ា១មានប្រជាជនចំនួន ៥០ គ្រួសារ និងប្លុកតាន់ប៉ា២មានប្រហែល ២៥០ គ្រួសារ។ ប្លុកតាន់ប៉ា១ ហាក់ដូចជាមានសភាពស្អាត និងមានសុវត្ថិភាពដែលផ្ទុយពីប្លុកតាន់ប៉ា២ ដែលពោរពេញទៅដោយស៊ីរ៉ាំងចាក់ថ្នាំរបស់ពួកប្រើប្រាស់គ្រឿងញៀន។ សហគមន៍ទាំងពីរមានប្រព័ន្ធទឹកស្អាត អគ្គិសនី និងលូបង្ហូរទឹកសម្រាប់ប្រើប្រាស់។ អ្នករស់នៅទីនោះភាគច្រើនធ្វើការនៅក្រៅសហគមន៍របស់គេ ហើយមានខ្លះទៀតធ្វើរបស់របរដោយដៃ ហើយយកវាទៅលក់នៅក្បែរផ្សារថ្មី។ គ្រួសារភាគច្រើន ហាក់មានតែប្លង់ទន់សម្រាប់បញ្ជាក់ពីអចលទ្រព្យរបស់គាត់ ហើយត្រូវបានអនុញ្ញាតឲ្យធ្វើអាជីវកម្មលើទ្រព្យទាំងនោះ ដោយមានការអនុញ្ញាតតាមបែបបទរដ្ឋបាលពីអាជ្ញាធរមូលដ្ឋាន។ ទោះជាយ៉ាងណា សហគមន៍នេះត្រូវបានផ្អៀលចេញជាផ្លូវការពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

## ៤.១.៧ សហគមន៍ព្រែកតានូ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ


ច្រកផ្លូវចូលទៅសហគមន៍ព្រែកតានូ២ ដែលក្រាលឥដ្ឋ

សហគមន៍ព្រែកតានូ២ ស្ថិតនៅតាមបណ្តោយដងទន្លេមេគង្គហ៊ុំព័ទ្ធទៅដោយរោងចក្រថ្នាំជក់ និងឃ្លាំងរបស់រោងចក្រ។ កាលដើមឡើយកន្លែងនេះជាផ្សារលក់ដូរ និងជាបេនឡានតាក់ស៊ី តែកាលពី១០ឆ្នាំមុន ពេលដែលគេរំលាយវាចោល មនុស្សម្នាបានចាប់ផ្តើមធ្វើការសាងសង់ផ្ទះ នៅជុំវិញទីតាំងនោះ។ លំនៅឋានដែលបានសាងសង់កាលពីដំបូងទាំងនេះ ត្រូវបានទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋានថាជាលំនៅឋានស្របច្បាប់ ចំណែកឯលំនៅឋាន ដែលសាងសង់ថ្មីៗនៅចំពីលើដីផ្សារ និងបេនឡានកាលពីមុននោះ គឺមិនត្រូវបាន គេទទួលស្គាល់ឡើយ។

សហគមន៍នេះមានប្រជាជនរស់នៅប្រមាណ ៤០០ គ្រួសារ ដែលមានកម្រិតសេដ្ឋកិច្ចសង្គមក្នុងលំដាប់ពីក្រីក្ររហូតទៅដល់លើមធ្យម។ ប្រជាជនរស់នៅទីនោះមានមុខរបរខុសៗគ្នាក្នុងការរកប្រាក់ចំណូល មានទាំងអ្នកលក់ដូរតាមចិញ្ចើមថ្នល់ កម្មករ និងអ្នកលក់ដូរតូចតាចនៅតាមផ្សារ។ ផ្ទះជាច្រើនមានលក្ខណៈរឹងមាំ និងសាងសង់ពីស៊ីម៉ង់ត៍ ហើយផ្លូវចូលក្រាលកៅស៊ូ។ សហគមន៍ នេះមានភ្ជាប់ប្រព័ន្ធទឹកស្អាត អគ្គិសនី និងលូបង្ហូរ តែពុំមានសេវាដឹកជញ្ជូនសំរាមទេ។ សំរាមជាច្រើនត្រូវបានឃើញនៅតាមដងទន្លេមេគង្គ។

## ៤.១.៨ សហគមន៍ថ្មសាន សង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ

ស្ថិតនៅខាងត្បូងនៃរាជធានីភ្នំពេញ នាម្ខាងទៀតនៃស្ពានព្រះមុន្នីវង្ស នៅក្នុងភូមិដើមស្លែង សហគមន៍ថ្មសានត្រូវបានសាងសង់ឡើងនៅក្នុងតំបន់កប់សពចុះពីផ្លូវលេខ៣៦៩។ មានគ្រួសារជាច្រើនប្រមាណជា ៩០ ទៅ ១០០ គ្រួសារបានរស់នៅទីនេះអស់រយៈពេលប្រហែល៣០ឆ្នាំ មកហើយ។ មានគ្រួសារមួយចំនួនមានប្លង់ទន់សម្រាប់ដីឡូត៍របស់ពួកគាត់ ចំណែកអ្នកផ្សេងទៀត ដែលមករស់នៅក្រោយៗ គឺពុំ មានប្លង់ទន់នោះទេ។ ទោះយ៉ាង ណា អ្នកទាំងអស់ក្នុងសហគមន៍

នេះ ត្រូវបានគេប្រាប់ជាផ្លូវការថា ពួកគេត្រូវបានផ្ទៀលចេញពីការចុះបញ្ជីដីធ្លី មានលក្ខណៈជាប្រព័ន្ធ។ នៅក្នុងសហគមន៍នេះ ពុំមានផ្លូវឆ្លងកាត់នោះទេ គឺមានតែច្រកចេញចូលតូចចង្អៀតដែលភ្ជាប់ពីផ្លូវលេខ៣៦៩ តែប៉ុណ្ណោះ។ ម្យ៉ាងទៀតសហគមន៍នេះហាក់បីដូចជារស់នៅផ្តាច់ខ្លួនឯកោពីគេ។



ខ្ទមតូចៗរាងជាផ្ទះសង់នៅជុំវិញផ្នូរចាស់ៗ

មានប្រព័ន្ធទឹកស្អាត និងអគ្គិសនីទៅដល់ទីនោះក៏ប៉ុន្តែគ្រួសារខ្លះពុំមានលទ្ធភាពតភ្ជាប់សេវាទាំងនេះទេ។

ខ្ទមតូចៗរាងជាផ្ទះត្រូវបានសាងសង់ឡើងជុំវិញកន្លែងកប់សព ហើយគេយកផ្នូរទាំងនោះជាកន្លែងប្រើប្រាស់សម្រាប់ហាលសំលៀកបំពាក់ ឬជាគន្លងដើរចំលងទៅផ្ទះ។ ផ្ទះទាំងនេះបានសាងសង់ពីឈើប្រក់ស័ង្កសី ដែលមានសភាពទ្រុឌទ្រោមខ្លាំង។ ដោយសារតែមានដីភក់ល្បប់នៅជុំវិញសហគមន៍ ដូច្នេះគេឃើញមានទឹកដក់ស្ទើរគ្រប់កន្លែង និងមានសំរាមជាច្រើននៅតាមភក់ជ្រាំនេះ។ សហគមន៍នេះ គឺជាសហគមន៍មួយដែលក្រីក្រជាងគេ ក្នុងចំណោមសហគមន៍ទាំងអស់ក្នុងការសិក្សានេះ ដែលមើលទៅជាតំបន់អនាធិបតេយ្យពិតប្រាកដមែន។ នៅទីនោះពុំមានអាជីវកម្ម ឬហាងលក់ដូរអ្វីនោះទេ ប៉ុន្តែមានស្ត្រីខ្លះធ្វើបង្អែម ខ្លះទៀតហាលងៀតពស់ព្រលិត និងកង្កែបបោកសម្រាប់យកទៅលក់។

### *៤.១.៩ សហគមន៍ទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ*

មានប្រជាជនចំនួន ២៤ គ្រួសារ រស់នៅក្នុងភូមិដែលត្រូវបានគេផ្ទៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដោយសារតែរដ្ឋាភិបាលអះអាងថាគ្រួសារទាំងនេះបានបោះទីតាំងដោយផ្អែកលើចំណីផ្លូវដែលគ្រោងនឹងពង្រីក។ សហគមន៍នេះមានបណ្តាញសេវាសាធារណៈទៅដល់ លើកលែងតែប្រព័ន្ធលូបង្ហូរ ហើយផ្លូវមានស្ថានភាពខូចខាតខ្លាំង។ ដីម្តុំ នេះ ធ្លាប់ជាទីកន្លែងកប់សព កាលពីមុន ហើយក្រោយឆ្នាំ ១៩៧៩ ប្រជាជនបានចាប់ផ្តើម មកតាំងទីលំនៅ ក្នុងតំបន់នេះ។



ច្រកចូលផ្លូវទៅកាន់សហគមន៍ទឹកថ្លា ២

កាលពីដើមឡើយ ច្រកចូលភូមិគឺតាមរយៈ ផ្លូវដើរតូចចង្អៀតប៉ុណ្ណោះ។ ពីមួយឆ្នាំទៅមួយឆ្នាំ សហគមន៍កាន់តែរីកធំឡើង។ ផ្លូវនេះបច្ចុប្បន្នមានទំហំ ៤ ម៉ែត្រ ហើយ បានក្លាយទៅជាផ្លូវសាធារណៈដែលរដ្ឋាភិបាលគ្រោងនឹងពង្រីកបន្ថែមនាពេលអនាគត។ ជាទស្សនៈផ្ទាល់ប្រជាពលរដ្ឋរស់នៅទីនោះ សហគមន៍នេះបានកើតមានឡើងមុនពេលមានផ្លូវ និងមិនគួរត្រូវបានចាត់ទុកថាជាសំណង់អនាធិបតេយ្យឡើយ ដោយសារកាលពីពេលនោះពួកគេពុំបានរស់នៅលើផ្លូវដោយខុសច្បាប់នោះទេ។

### ៤.១.១០ សហគមន៍បុរី ១០០ ខ្នង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ



សហគមន៍បុរី១០០ខ្នង រស់នៅតាមផ្លូវរថភ្លើង

សហគមន៍នេះ មានទីតាំងនៅក្នុងខណ្ឌសែនសុខ ក្បែរបុរី ១០០ខ្នង ដែលមានភាពល្បីល្បាញនោះ ហើយក៏នៅជិតសកលវិទ្យាល័យភូមិន្ទភ្នំពេញ ផងដែរ។ មានអគារថ្មីៗមួយចំនួនបានរីកលូតលាស់ នៅក្នុងតំបន់នេះ រួមទាំង មានឃ្លាំងស្តុកទំនិញធំៗមួយចំនួន និងវត្តអារាមមួយផងដែរ។ សហគមន៍នេះត្រូវបានផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដោយសារតែសហគមន៍នេះស្ថិតនៅតាមបណ្តោយផ្លូវរថភ្លើង ហើយចំងាយ ៣០ម៉ែត្រ សងខាងផ្លូវដែកត្រូវបានអះអាងថាជាដីសាធារណៈ និងត្រូវរក្សាទុកឲ្យនៅទំនេរ។ មានប្រជាជនប្រមាណ

៥១ គ្រួសារ ដែលរស់ក្នុងសហគមន៍នេះ ដែលមួយចំនួនបានមកនៅតាំងពីដើមឆ្នាំ ១៩៨០ និងមានប្លង់ទន់សម្រាប់អចលនទ្រព្យរបស់ពួកគាត់។

សហគមន៍នេះអាចចូលទៅដល់បានតាមផ្លូវលេខ ៥៩៨ តែពុំមានផ្លូវកាត់ទទឹងត្រឹមត្រូវទេ គឺមានតែស្នាមផ្លូវដីតែប៉ុណ្ណោះ។ ផ្ទះឈើតូចៗផ្ចុំគ្នានៅតាមបណ្តោយម្ខាងនៃផ្លូវដែក ដែលវាមានសភាពដូចជាតំបន់ហួតហែង ថ្វីត្បិតតែមានមានទឹកភក់ដោយកន្លែងក៏ដោយ។ ខ្សែបណ្តាញអគ្គិសនីរត់តាមបណ្តោយផ្លូវដែកហើយលំនៅឋាននៅទីនោះ បានតភ្ជាប់បណ្តាញនេះតាមគេហដ្ឋានជាមួយនឹងបណ្តាញទឹកស្អាតផងដែរ។ ផ្ទះដែលនៅតាមបណ្តោយផ្លូវរថភ្លើងផ្ទាល់នោះបានសាងសង់អំពីឈើប្រក់ស័ង្កសី និងមានសភាពទ្រុឌទ្រោម។ ចំណែកផ្ទះដែលនៅឆ្ងាយពីផ្លូវរថភ្លើងបន្តិចនោះ មានផ្ទះខ្លះតូចៗតែមានលក្ខណៈគ្រាន់បើ (ឧទាហរណ៍ដំបូលប្រក់ក្បឿង) ខ្លះទៀតគឺទទេរល្ហល្ហេវ និងមួយចំនួនទៀតស្ថិតនៅក្នុងស្ថានភាពខ្ទេចខ្ទី។ គេមិនឃើញមានមុខរបរលក់ដូរ ឬហាងអ្វីនៅទីនោះទេ ដូច្នេះ គេអាចគិតថាប្រជាជននៅទីនោះទៅប្រកបការងារចិញ្ចឹមជីវិតនៅកន្លែងដទៃទៀត។ ជាសរុបសហគមន៍នេះដូចជាតំបន់សំណង់អនាធិបតេយ្យ ដោយមានសំរាមរប៉ាត់រប៉ាយនៅជុំវិញ មានទឹកភក់នៅគ្រប់កន្លែងហើយស្ថានភាពរស់នៅមានសភាពគ្មានអនាម័យ។

### *៤.១.១១ សហគមន៍ ១០២ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក*

សហគមន៍១០២ស្ថិតនៅតាមបណ្តោយ នៃរបងវត្តនាគវ័ន្ត ក្នុងខណ្ឌទួលគោក លើផ្លូវលេខ ៦០៨ ហើយសហគមន៍នេះ ត្រូវបានគេផ្តល់ដំណឹងជាផ្លូវការថា បានផ្លៀលចេញ ពីដំណើរការនៃការចុះបញ្ជីដីធ្លី មានលក្ខណៈជាប្រព័ន្ធ។ វាស្ថិតនៅមិនឆ្ងាយពី ស្ថាននីយ៍អយស្ម័យយាន និងបឹងកក់ទេ។ នៅទីនោះមានឃ្លាំងស្តុកទំនិញមួយចំនួន និងមានកន្លែងរោងជាងសម្រាប់ជួសជុលផ្លូវដែកមួយកន្លែង ហើយកន្លែងផ្សេងទៀតសុទ្ធសឹងតែ



*សហគមន៍១០២ នៅតាមបណ្តោយផ្លូវលេខ៦០៨*

ជាតំបន់រស់នៅ។ សហគមន៍នោះគឺជាជំរកសម្រាប់ប្រជាជនចំនួន ៥០ គ្រួសារ ដែលមានឯកសារសំអាងពីសិទ្ធិកាន់កាប់របស់ពួកគេ។ សហគមន៍នេះប្រជៀតគ្នាជាមួយនឹងជញ្ជាំងវត្ត និងផ្លូវធ្វើដំណើរ ដូច្នេះលំនៅឋានទាំងនោះមានលក្ខណៈតូចចង្អៀតជាមួយនឹងទំហំប្រហែល ៤ម៉ែត្រគុណ៥ម៉ែត្រ តែភាគច្រើនបានសាងសង់ពីរជាន់មានកូនបន្ទប់នៅពីខាងលើ។ លំនៅឋានទាំងនោះមានខ្លះធ្វើពីឥដ្ឋ ខ្លះពីឈើប្រក់ស័ង្កសីមានសភាពចាស់ តែស្អាតមានអនាម័យ មានផើងផ្កាតាមច្រកទ្វារ និងតាមចំរឹងដែកលើដំបូលផ្ទះ។ មានបណ្តាញទឹកស្អាត អគ្គិសនី លូបង្ហូរទឹក និងសេវាដឹកជញ្ជូនសំរាមផងដែរ។ ផ្លូវថ្នល់មានសភាពស្អាតដូចជាថ្នល់នៅកន្លែងធ្វើការនានានៅភ្នំពេញដែរ ដោយមានមនុស្សម្នាកំពុងធ្វើការនៅមុខផ្ទះរបស់ពួកគេ ស្ត្រីបោកគក់សំលៀកបំពាក់ ខ្លះទៀតអង្គុយពិសារកាហ្វេ ហើយក៏មានមានផ្ទះលក់ទំនិញតូចៗចំនួនពីរក្នុងនោះផ្ទះមួយលក់ភេសជ្ជៈ ឯផ្ទះមួយទៀតលក់របស់របរ តែវាហាក់ដូចជាស្ងាត់ពុំសូវមានការទិញដូរអ្វីនោះទេ។

### ៤.១.១២ សហគមន៍ ៣៤៧ សង្កាត់បឹងកក់ ១ ខណ្ឌទួលគោក



គេមានផែនការពង្រីកផ្លូវលេខ ៣៤៧
ដែលនៅទល់មុខសហគមន៍៣៧៤

សហគមន៍ ៣៤៧ ស្ថិតនៅខណ្ឌទួលគោក ដែលឈ្មោះនេះយកតាម ឈ្មោះផ្លូវនៃទីតាំងនោះ។ តំបន់ជុំវិញនោះហាក់ពុំសូវមានការអភិវឌ្ឍអ្វីទេ សកម្មភាពពាណិជ្ជកម្មក៏ហាក់នៅមានកម្រិត ប៉ុន្តែមានឃ្លាំងស្តុកទំនិញមួយចំនួន។ សេវាសាធារណៈ បណ្តាញទឹកស្អាត អគ្គិសនី លូបង្ហូរ និងសេវាដឹកជញ្ជូនសំរាមមាននៅក្នុងតំបន់នោះ។ សហគមន៍នេះមានក្រុមគ្រួសារចំនួន ២ ក្រុម ដែលបានរស់នៅក្នុងទីតាំងនេះប្រហែល ៣០ឆ្នាំ មកហើយ។ ក្រុមទី១មានប្រជាជនចំនួន ២១ គ្រួសារ ដែលរស់នៅផ្ទាល់តាមបណ្តោយផ្លូវលេខ ៣៤៧ និងពុំមានឯកសារសំអាងអំពីសិទ្ធិកាន់កាប់ឡើយ ហើយក្រុមទី២មានគ្រួសារដែល

មានចំនួនប្រហាក់ប្រហែលគ្នានឹងក្រុមទីមួយ ដោយពួកគាត់រស់នៅឆ្ងាយបន្តិចពីផ្លូវ ៣៤៧ ហើយពួកគេមានប្លង់ទន់។

គេមានផែនការពង្រីកផ្លូវលេខ៣៤៧ ដែលនៅចំពីមុខសហគមន៍នេះ។ លំនៅឋានដែលស្ថិតនៅចំផ្លូវលេខ ៣៤៧ គឺស្ថិតនៅលើគន្លងដែលគេគ្រោងពង្រីកផ្លូវ ហើយដែលត្រូវបានផ្លៀលចេញ។ លំនៅឋានភាគច្រើនតាមបណ្តោយផ្លូវលេខ ៣៤៧ មានលក្ខណៈតូចៗ សាងសង់ពីឈើប្រក់ស័ង្កសី។ មានហាងតូចៗមួយចំនួនលក់ដូរសម្រាប់អ្នកនៅក្បែរនោះ។ កន្លងមកថ្មីៗនេះ រដ្ឋាភិបាលបានចាប់ផ្តើមធ្វើការពង្រីកផ្លូវនេះ តែគ្រួសារទាំងឡាយដែលរស់នៅតាមបណ្តោយផ្លូវនេះបានបដិសេធមិនព្រមចាកចេញ ដោយពួកគេបានធ្វើការតវ៉ាថា រដ្ឋាភិបាលគួរតែពង្រីកផ្លូវទៅខាងផ្លូវដើរនៅផ្នែកម្ខាងទៀតនៃផ្លូវ ជាជាងបណ្តេញពួកគាត់ចេញពីលំនៅឋានបច្ចុប្បន្ន។ រដ្ឋាភិបាលបានបោះបង់ចោលគម្រោងការនេះ ដោយមិនឃើញមានបន្តសកម្មភាពអ្វីទៀតនោះទេ។ យ៉ាងណាមិញ តាមរយៈការសិក្សារបស់សមាគមធាងត្នោត ឆ្នាំ ២០១៤ បានឲ្យដឹងថា សហគមន៍៣៤៧ គឺជាសហគមន៍មួយក្នុងចំណោមតំបន់តាំងទីលំនៅទាំង១៥ ដែលត្រូវបានជ្រើសរើសសម្រាប់ការអនុវត្តសារាចរលេខ០៣។

## ៤.២ ការទទួលបានសេវាសាធារណៈ

សហគមន៍ក្រីក្រទាំង ១២ នៅក្នុងការសិក្សានេះបានតភ្ជាប់សេវាអគ្គិសនីរដ្ឋ ១១ សហគមន៍បានភ្ជាប់បណ្តាញសេវាទឹកស្អាត ប៉ុន្តែមានសហគមន៍តែ ៦ ប៉ុណ្ណោះដែលមានលូបង្ហូរទឹកស្អុយ និងសហគមន៍ចំនួន ៤ ទៀត បានទទួលសេវាដឹកជញ្ជូនសំរាម។ បញ្ហាអនាម័យគឺជារឿងធ្ងន់ធ្ងរជាទីបំផុត សម្រាប់ប្រជាជនដែលរស់នៅតំបន់កប់សព (សូមមើលតារាងទី៤)។ សំណាកគំរូនៃសហគមន៍ក្រីក្រនៅតំបន់ទីក្រុងក្នុងការសិក្សានេះ ហាក់ដូចជាទទួលបានសេវាអគ្គិសនី និងទឹកស្អាតច្រើនជាងសំណាកគំរូដែលបានសិក្សាដោយសមាគមធាងត្នោតកាលពីឆ្នាំ២០១៤ និងសាលាក្រុងភ្នំពេញកាលពីឆ្នាំ២០១២ ក៏ប៉ុន្តែការទទួលបាននូវសេវាលូបង្ហូរទឹកស្អុយ និងសេវាដឹកជញ្ជូនសំរាមមានលក្ខណៈតិចតួច។ យ៉ាងណាមិញ គ្រួសារទាំង ១០ នៅសហគមន៍ភូមិអ្នកតាមានភាពក្រីក្រខ្លាំងពេក ដោយពុំអាចមានលទ្ធភាពតភ្ជាប់បណ្តាញទឹកស្អាត និងអគ្គិសនីសាធារណៈ ហើយបែរជាពឹងផ្អែកលើសេវាឯកជនដែលជាទូទៅមានតម្លៃខ្ពស់ជាងតម្លៃសាធារណៈពី ៥០% ទៅ ១០០%។

### តារាងទី៩៖ ការទទួលបានសេវាសាធារណៈនៃសហគមន៍ទាំង ១២

| ខណ្ឌ | សហគមន៍ក្រីក្រ | លទ្ធភាពទទួលសេវាសាធារណៈ | | | |
|---|---|---|---|---|---|
| | | អគ្គិសនី | ទឹកស្អាត | លូទឹកស្អុយ | ប្រមូលសំរាម |
| ចំការមន | ចៅពញាហុក | ✓ | ✓ | ✓ | ✓ |
| | បឹងត្របែក | ✓ | ✓ | ✓ | |
| ដង្កោ | ភូមិអ្នកតា | ✓ (ឯកជន) | ✓ (ឯកជន) | | |
| | ចេក | ✓ | | | |
| ដូនពេញ | ផ្លូវរថភ្លើង | ✓ | ✓ | | |
| | ប្លុកតាន់ប៉ា | ✓ | ✓ | ✓ | |
| មានជ័យ | ព្រែកតាន្ទូ២ | ✓ | ✓ | ✓ | |
| | ថ្មសាន | ✓ | ✓ | | |
| សែនសុខ | ទឹកថ្លា២ | ✓ | ✓ | | ✓ |
| | បុរី២០០ខ្នង | ✓ | ✓ | | |
| ទួលគោក | ១០២ | ✓ | ✓ | ✓ | ✓ |
| | ៣៤៧ | ✓ | ✓ | ✓ | ✓ |
| % នៃសហគមន៍ដែលទទួលសេវាសាធារណៈ | | | | | |
| សំណាកនៃការសិក្សានេះ (N=១២ សហគមន៍) | | ១០០% | ៩១,៦% | ៥០% | ៣៣% |
| សំណាករបស់សមាគមធាងត្នោត ២០១៤ (N=៣៤០ សហគមន៍) | | ៨០% | ៧១,៥% | ៤៣% | ៩១% |
| សំណាករបស់សាលារាជធានីភ្នំពេញ ២០១២ (N=២៨១ សហគមន៍) | | ៩២% | ៨៥,៤% | ៧១,៨% | ៦០% |

កំណត់សម្គាល់៖ (✓) បង្ហាញពីសហគមន៍ដែលទទួលបានសេវាសាធារណៈ

## ៤.៣ ព័ត៌មានសេដ្ឋកិច្ចសង្គមនៃគ្រួសារក្នុងសហគមន៍ក្រីក្រនៅទីក្រុង

ក្នុងចំណោមប្រជាជន ៦០ នាក់ (មានស្ត្រីចំនួន ៤០នាក់) តំណាងឲ្យប្រជាជនចំនួន ៦០គ្រួសារ ពីសហគមន៍ក្រីក្រនៅទីប្រជុំជនទាំង១២ ក្នុងខណ្ឌទាំង ៦ ត្រូវបានជ្រើសរើសអោយចូលរួមក្នុងការសម្ភាស។ ប្រជាជនទាំងនោះមានអាយុ

ជាមធ្យម ៤៦ឆ្នាំ (ចន្លោះពី ២៤ ទៅ ៦៧ ឆ្នាំ) ក្នុងនោះ ៤៦នាក់ បានរៀបការរួច ១៣នាក់ ជាស្ត្រីមេម៉ាយ និងម្នាក់បានលែងលះ។ ស្ត្រីជាមេគ្រួសារមានចំនួនមួយភាគបីនៃគ្រួសារទាំងអស់។ តួលេខនេះខ្ពស់ជាងមធ្យមភាគជាតិដែលមានស្ត្រីជាមេគ្រួសារតែ (២៧%) ប៉ុណ្ណោះ (NIS ២០១៣) ប៉ុន្តែវាទាបជាងអត្រាស្ត្រីជាមេគ្រួសារក្នុងការសិក្សារបស់សាលារាជធានីភ្នំពេញ (៣៨%) បន្តិច។

ចំនួនប្រជាជនទាំង ៦០ គ្រួសារ នៃសំណាកក្នុងការសិក្សានេះមានសមាជិកគ្រួសារសរុបចំនួន ៣៦០នាក់ ដោយរួមបញ្ចូលទាំងក្មេងក្រោមអាយុ ១៨ឆ្នាំ ចំនួន ១៩២នាក់។ ជាមធ្យមក្នុងមួយគ្រួសារមានសមាជិកចំនួន ៦នាក់ (ចន្លោះពី ២នាក់ ទៅ ១៣នាក់ មេដ្យាន ៥នាក់)។ គ្រួសារទាំងអស់លើកលែងតែ ២គ្រួសារ មានក្មេងៗនៅជាមួយដែលមានអាយុ (ចន្លោះពី ១នាក់ ទៅ ៨នាក់ ជាមធ្យម ៣,៣នាក់ ក្នុងមួយគ្រួសារ)។ កុមារទាំងអស់មានចំនួនលើសពាក់កណ្តាល (៥៣%) នៃចំនួនប្រជាជនសរុបក្នុងចំណោមគ្រួសារទាំង ៦០ គ្រួសារ ដែលបានចូលរួមក្នុងការសម្ភាស។ នៅក្នុងរបាយការណ៍ជំរឿនឆ្នាំ ២០០៨ បានបញ្ជាក់ថា ប្រជាជនជាទូទៅចំនួន ៣៦% នៃប្រជាជនកម្ពុជាទាំងអស់មានអាយុក្រោម ១៨ឆ្នាំ ហើយចំនួនកូនជាមធ្យមមាន ១,៥នាក់ ក្នុងមួយគ្រួសារ (NIS ២០០៨)។ ក្នុងនោះមាន ១៦គ្រួសារដែលមានកុមារបោះបង់ចោលការសិក្សា ដោយសារតែភាពក្រីក្រផងដែរ និងដោយសារតែក្មេងនោះមិនចង់រៀនសូត្រ។ គួរអោយកត់សម្គាល់មានប្រជាជនចំនួន ៨ គ្រួសារ ដែលមានសមាជិកម្នាក់ក្នុងចំណោមសមាជិកទាំងអស់ពិការជាអចិន្ត្រៃយ៍ (២,២% នៃប្រជាជន ៦០ គ្រួសារ) ហើយគ្រួសារចំនួន ១៤ ទៀត មានសមាជិកម្នាក់ឬពីរនាក់មានជម្ងឺរ៉ាំរ៉ៃ (៦,៩% នៃប្រជាជន៦០គ្រួសារ)។[១៧] អត្រានេះខ្ពស់ជាងអត្រាមធ្យមថ្នាក់ជាតិរបស់វិទ្យាស្ថានជាតិស្ថិតិឆ្នាំ ២០១៣ (១,៣% នៃប្រជាជននៅតំបន់ប្រជុំជន មានជនពិការម្នាក់)។

ភាគច្រើននៃអ្នកតបសម្ភាសន៍ (៦៥%) មិនទទួលបានការសិក្សា ឬបានទទួលបានការសិក្សាត្រឹមតែកម្រិតបឋមប៉ុណ្ណោះ។ អ្នកតបសម្ភាសន៍ចំនួន ១៩% បានបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិ ១៣% បានបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ និង៣% ទៀតសិក្សាថ្នាក់ឧត្តម ដែលតួលេខនេះមានភាពស្របគ្នាជាមួយមធ្យមភាគថ្នាក់ជាតិ (NIS ២០១៣)។ ភាគច្រើនទាំងប្តី និងប្រពន្ធ គឺជាអ្នករកចំណូល

[១៧] មានគ្រួសារចំនួន៤ ដែលមានសមាជិកគ្រួសារទាំងពិការភាពផង និងជម្ងឺរ៉ាំរ៉ៃផង។

ចម្បងក្នុងគ្រួសារ ប៉ុន្តែមានករណីចំនួន ១១ ដែលមានកុមារជាអ្នកធ្វើការចិញ្ចឹមឪពុកម្តាយដែលមានភាពចាស់ជរា។ ពីរភាគប្រាំនៃគ្រួសារដែលបានជ្រើសរើសសម្រាប់ការសិក្សា (N=២៥) ពឹងផ្អែកទៅលើប្រភពចំណូលច្រើនជាងមួយ។ ប្រាក់ចំណូលប្រចាំថ្ងៃរបស់គ្រួសារនីមួយៗជាមធ្យមចំនួន ៨,៥ដុល្លារអាមេរិក (ចន្លោះពី ២,៥ ទៅ៣០ ដុល្លារអាមេរិក) ឬក៏តិចជាង ២៦០ដុល្លារអាមេរិក ក្នុងមួយខែ។ ប្រាក់ចំណូលនេះ បានត្រឹមតែលើសពីពាក់កណ្តាលមធ្យមភាគនៃប្រាក់ចំណូលរបស់អ្នកក្រុងភ្នំពេញបន្តិចប៉ុណ្ណោះ។ ប្រាក់ចំណូលជាមធ្យមសម្រាប់អ្នកក្រុងភ្នំពេញជាទូទៅនៅឆ្នាំ ២០០៩ គឺ៤៩២ដុល្លារអាមេរិក តែការប្រៀបធៀបប្រាក់ចំណូលនេះមិនទាន់ទាំងបានវិភាគអំពីអតិផរណាប្រចាំឆ្នាំ នៃតម្លៃលុយខុសគ្នារវាងឆ្នាំ២០០៩ និង២០១៤ នោះផង (NIS ២០០៩)។ អ្នករស់នៅទីនោះភាគច្រើនរកប្រាក់ចំណូលដោយធ្វើការបានកម្រៃទាប ដូចជា អ្នកលក់ដូរតាមចិញ្ចើមថ្នល់ អ្នកនេសាទ អ្នកលក់ចាបហ៊ួយតូចតាច អ្នករត់ម៉ូតូឌុប ឬបើកតាក់ស៊ី។ មានប្រជាជនមួយចំនួនបានធ្វើការសមរម្យក្នុងវិស័យឯកជនឬសាធារណៈ ដោយទទួលបានប្រាក់បៀវត្សន៍ទាប។[១៨]

គ្រួសារចំនួនជាងពាក់កណ្តាល (៣៥ គ្រួសារ) មានជាប់បំណុលពី ១០០ ទៅ ១០០.០០ដុល្លារអាមេរិក។[១៩] ប្រភពប្រាក់កម្ចីចម្បងគឺកម្មវិធីឥណទានដោយអង្គការមិនមែនរដ្ឋាភិបាល បន្ទាប់មកតាមរយៈអ្នកចងការប្រាក់ឯកជន ធនាគារ សាច់ញាតិ ឬមិត្តភ័ក្រ្ត។ អត្រាការប្រាក់អាស្រ័យទៅលើប្រភព គោលបំណង និងរយៈពេលនៃកម្ចី។ កម្ចីពីសាច់ញាតិជាទូទៅពុំមានយកការប្រាក់ទេ ប៉ុន្តែកម្ចីពីអង្គការមិនមែនរដ្ឋាភិបាលមានការប្រាក់រហូតដល់ ៣.៥% ក្នុងមួយខែ (៤២% ក្នុងមួយឆ្នាំ)។ ជាងនេះទៅទៀត អ្នកចងការប្រាក់ឯកជនជាទូទៅយកអត្រាការប្រាក់រហូតដល់ទៅ

---

[១៨] បើប្រៀបធៀបពីទំហំសំណាក នៃសហគមន៍ក្រីក្រដែលបានសិក្សាដោយសាលារាជធានីភ្នំពេញ (២០១២) ជាមួយចំនួនគ្រួសារក្នុងទំហំសំណាករបស់ការសិក្សានេះ សមាជិកគ្រួសារជាមធ្យមមានចំនួនប្រហាក់ប្រហែលគ្នា ប៉ុន្តែចំនួនកូនជាមធ្យមមានច្រើនជាង (៣,២នាក់ ធៀបនឹង ២នាក់ ក្នុងការសិក្សារបស់សាលារាជធានីភ្នំពេញ)។ សមាមាត្រនៃគ្រួសារដែលមានសមាជិកពិការភាពមានចំនួនដូចគ្នាក្នុងការសិក្សាទាំងពីរ។ ចំនួនគ្រួសារនៅក្នុងសំណាករបស់យើងហាក់បីដូចមានប្រាក់ចំណូលខ្ពស់ជាងការសិក្សារបស់សាលារាជធានីភ្នំពេញ (៨% មានប្រាក់ចំណូលតិចជាង ០,៥ដុល្លាអាមេរិក ក្នុងមួយថ្ងៃប្រៀបធៀបនឹង ៦០%ក្នុងការសិក្សារបស់សាលារាជធានីភ្នំពេញ) ហើយមានគ្រួសារតិចជាងដែលជំពាក់បំណុលគេ (៥០% ប្រៀបធៀបនឹង ៨៣%)។

[១៩] មានបីគ្រួសារត្រូវបានរាយការណ៍ថា មានបំណុល ១០.០០០ដុល្លារអាមេរិក។

១០% ក្នុងមួយខែ (១២០% ប្រចាំឆ្នាំ)។ គ្រួសារប្រមាណពាក់កណ្ដាលនៃគ្រួសារទាំងអស់បានខ្ចីប្រាក់សម្រាប់មុខជំនួញខ្នាតតូច ហើយពាក់កណ្ដាលទៀតបានខ្ចីប្រាក់សម្រាប់ការព្យាបាលជម្ងឺ និងចំណាយក្នុងក្រុមគ្រួសារ។ ក្នុងនោះមានតែគ្រួសារមួយចំនួនតូចប៉ុណ្ណោះដែលខ្ចីប្រាក់សម្រាប់កែលម្អលំនៅឋាន ឬក៏ទិញវត្ថុមានប្រយោជន៍ ដូចជា ម៉ូតូ ផ្ទះ ឬដី។

សរុបមក គ្រួសារដែលត្រូវបានសម្ភាសន៍នៅក្នុងសហគមន៍ក្រីក្រទាំង ១២ ជាទូទៅ មានភាពក្រខ្សត់ជាងគ្រួសារដែលមានជីវភាពមធ្យមនៅទីក្រុងភ្នំពេញ។ គ្រួសារទាំងនោះមានចំនួនកូនច្រើនដែលជាការបង្កើនបន្ទុកដល់ថវិកាគ្រួសារ។ ការព្យាបាលសមាជិកមានជម្ងឺរ៉ាំរ៉ៃ និងការថែរទាំសមាជិកដែលមានពិការភាព បានក្លាយជាបន្ទុកបន្ថែមសម្រាប់គ្រួសារ និងក្លាយជាវដ្តនៃភាពក្រីក្រតកូនតចៅ។ ប្រាក់ចំណូលមធ្យមសម្រាប់គ្រួសារសហគមន៍ក្រីក្រ ទាបជាងប្រាក់ចំណូលមធ្យមរបស់អ្នកភ្នំពេញ ហើយសហគមន៍ក្រីក្រទាំង១២ ក៏មានប្រាក់ចំណូលខុសៗគ្នាដែរ។ ជាទូទៅ សហគមន៍ក្រីក្រនៅខណ្ឌខាងក្នុងក្រុងមានស្ថានភាពជីវភាពល្អប្រសើរជាងសហគមន៍ក្រីក្រនៅខណ្ឌជាយក្រុង។[២០] (ប្រាក់ចំណូលជាមធ្យមសម្រាប់អ្នករស់នៅក្នុងខណ្ឌខាងក្នុងក្រុងគឺ ៣៦០ដុល្លារអាមេរិក បើប្រៀបធៀបទៅនឹងអ្នកដែលរស់នៅខណ្ឌជាយក្រុង ២១០ដុល្លារអាមេរិក)។ ទាំងនេះក៏បានបង្ហាញតាមរយៈលក្ខណៈជារូបវន្តនៃសហគមន៍នីមួយៗ ដែលក្រុមការងារស្រាវជ្រាវបានអង្កេតឃើញ។ ឧទាហរណ៍ សហគមន៍ភូមិអ្នកតា និងភូមិថ្មសាន បានបង្ហាញពីភាពលំបាកយ៉ាប់យឺនដែលមានតែច្រកចូលតូចចង្អៀត (សូម្បីតែឡានសង្គ្រោះបន្ទាន់ក៏មិនអាចចូលបាន) និងអគារទ្រុឌទ្រោម។ ប្រាក់ចំណូលជាមធ្យម ក្នុងសហគមន៍ទាំងពីរនេះគឺជាប្រាក់ចំណូលទាបបំផុត ក្នុងចំណោមសហគមន៍ដទៃទៀត (១៧៧ដុល្លារអាមេរិក និង១៦៨ដុល្លារអាមេរិកតាមលំដាប់លំដោយ)។ បើធ្វើការប្រៀបធៀបប្រាក់ចំណូលជាមធ្យមក្នុងសហគមន៍ អ្នករស់នៅក្នុងសហគមន៍ប្លុកតាន់ប៉ាគឺមានចំនួនខ្ពស់បំផុត (៥១០ដុល្លារអាមេរិក)។ ភាគច្រើននៃគ្រួសារទាំងឡាយមានជាប់បំណុល។ កង្វះខាតនៃប័ណ្ណកម្មសិទ្ធិ (ប្លង់រឹង) មានន័យថាពួកគាត់ពុំអាចខ្ចីប្រាក់ពីធនាគារបាទេ

[២០] សហគមន៍ខណ្ឌខាងក្នុងក្រុងរួមមាន (សហគមន៍ចៅពញាហុក បឹងត្របែក ផ្លូវរថភ្លើង ប្លុកតាន់ប៉ា សហគមន៍១០២ និងសហគមន៍ ៣៤៧) ចំណែកសហគមន៍នៅខណ្ឌជាយក្រុងរួមមាន (សហគមន៍ភូមិអ្នកតា សហគមន៍ភូមិចេក ព្រែកតានូ ២ ថ្មសាន ទឹកថ្លា ២ និងបុរី ១០០ ខ្នង)។

តែបែរជាពឹងផ្អែកលើប្រភពផ្តល់ប្រាក់កម្ចីផ្សេងទៀត ដែលជាទូទៅមានអត្រាការប្រាក់ខ្ពស់។

## ៤.៤ ប្រភេទដីដែលសហគមន៍ក្រីក្រតាំងទីលំនៅ និងមូលហេតុនៃការផ្លៀលចេញ

មានប្រជាជនចំនួន៥៥គ្រួសារ (ឬ៧៣%)បានតាំងទីលំនៅនៅក្នុងសហគមន៍ក្រីក្រមុនពេលមានច្បាប់ភូមិបាលឆ្នាំ២០០១ (ក្នុងនោះ ២៦ គ្រួសារ ឬ៤៣% បានមករស់នៅលើទីតាំងទាំងនោះនៅចន្លោះពីឆ្នាំ ១៩៧៩ និង១៩៩១ ហើយ ១៨ គ្រួសារ ឬ ៣០% បានមករស់នៅលើទីតាំងបច្ចុប្បន្ននៅចន្លោះពី ឆ្នាំ១៩៩២ និង២០០១) និង ១៦ គ្រួសារ (ឬ២៧%) ទៀតបានមករស់នៅក្រោយឆ្នាំ២០០១។ សហគមន៍ទាំងនោះលើកលែងតែសហគមន៍មួយ ដែលបានបោះទីតាំងលើដីដែលអាចត្រូវបានរក្សាទុកជាដីសាធារណៈរបស់រដ្ឋ រួមបញ្ចូលទាំងផ្លូវដើរសងខាងផ្លូវ សម្រាប់ពង្រីកផ្លូវថ្នល់តាមបណ្តោយផ្លូវរថភ្លើង លើប្រឡាយ បង្ហូរទឹកស្អុយ ឬលើដីសាធារណៈនៅក្នុងភូមិ។[២១] ជាងពាក់កណ្តាលនៃអ្នកដែលបានចូលរួមក្នុងការសិក្សានេះ (៣៣/៦០នាក់) បានដឹងដែរថាអចលនទ្រព្យរបស់ពួកគាត់ គឺស្ថិតនៅលើដីសាធារណៈមានខ្លះទៀត (១៧/៦០នាក់) គិតថាពួកគាត់បានកាន់កាប់ដីលំនៅឋានឯកជន និងមួយចំនួនទៀត (១០/៦០នាក់) មិនបានដឹងច្បាស់អំពីប្រភេទដីដែល គាត់កំពុងរស់នៅនោះទេ។ មាន ១៧គ្រួសារ បាននិយាយថាអចលនទ្រព្យរបស់ពួកគាត់ស្ថិតនៅលើដីឯកជនពីព្រោះគាត់បានបោះទីតាំងនៅក្នុងសហគមន៍មុន ច្បាប់ភូមិបាលឆ្នាំ ១៩៩២ បានចូលជាធរមាន ឬក៏ដោយសារថាគាត់បានទិញ អចលទ្រព្យនេះបន្តពីអ្នកកាន់កាប់ពីមុន និងមានប្លង់ទន់ ឬក្រដាសស្នាមផ្ទេរសិទ្ធិ ទទួលស្គាល់ត្រឹមត្រូវដោយអាជ្ញាធរមូលដ្ឋាន។

ដោយយោងទៅតាមទស្សនៈប្រជាជននៅទីនោះ អំពីប្រភេទដីដែលពួកគាត់កាន់កាប់ ពាក់កណ្តាលនៃអ្នកដែលបានតបសម្ភាសន៍បានជឿជាក់ថាពួកគាត់ត្រូវបានផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដោយសារអចលនទ្រព្យរបស់ពួកគាត់ស្ថិតនៅលើដីសាធារណៈ។ ចំណែកឯពាក់កណ្តាលទៀតគឺមិនបានដឹងអំពីមូលហេតុនៃការផ្លៀលចេញនោះទេ។ ភាគច្រើននៃមេភូមិដែលបានចូលរួមក្នុងការសិក្សានេះ មានអ្នកខ្លះក៏រស់នៅលើសហគមន៍ក្រីក្រដែលបានផ្លៀលចេញ

[២១] ប្លុកតាន់ប៉ា គឺជាសហគមន៍តែមួយគត់ដែលច្បាស់លាស់ថាមិនស្ថិតនៅលើដីរបស់រដ្ឋ។

និងមិនផ្តល់ប័ណ្ណកម្មសិទ្ធិដែរ ហើយការផ្ទៀលចេញនេះមិនមានអ្វីជាចម្ងល់ច្រើន នោះទេព្រោះសហគមន៍នោះស្ថិតនៅលើដីសាធារណៈ។ ប៉ុន្តែ មានមួយចំនួនទៀត នៅពុំបានដឹងអំពីមូលហេតុនៃការផ្ទៀលចេញនេះទេ។ មេភូមិមិនសូវនិយាយ ឬ និយាយយ៉ាងតិចតួចអំពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ ហើយនេះក៏ជាបញ្ហារសើប ដែរ ដោយសារថាពួកគាត់ត្រូវបានគេចាត់ទុកថាជាអ្នកមានទំនាក់ទំនងរដ្ឋបាល ដោយផ្ទាល់រវាងអាជ្ញាធរ និងអ្នកភូមិ។

សហគមន៍ប្លុកតាន់ប៉ា ខុសពីសហគមន៍ក្រីក្រទាំង ១១ ផ្សេងទៀត។ សហគមន៍នេះ មានទីតាំងនៅលើដំបូលនៃអាគារ ហើយពុំមានអ្វីដែលអាចបញ្ជាក់ បានថា អចលនទ្រព្យនេះ ជាសម្បត្តិរដ្ឋ ឬឯកជនឡើយ។ ប្លុកតាន់ប៉ានីមួយៗមាន ៤ ទៅ ៥ជាន់ ហើយជាន់នីមួយៗគឺជាផ្នែកនៃភូមិផ្សេងៗគ្នា។ ផ្ទះល្វែងទាំងនោះ ស្ថិតនៅតាមជាន់ខុសៗគ្នា និងមានម្ចាស់ខុសៗគ្នា។ តាមរយៈមន្ត្រីការិយាល័យ រៀបចំដែនដី នគររូបនីយកម្ម និងសំណង់ខណ្ឌដូនពេញ បានអោយដឹងថាប្លុក តាន់ប៉ា ១ និង២ ត្រូវបានគេផ្ទៀលចេញពីការចុះបញ្ជី ដោយសារតែអចលនទ្រព្យ នៅតំបន់នេះមិន ស្ថិតនៅក្រោមសមត្ថកិច្ចនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ទេ។ លើកលែង ប្លុកដែលមានច្រើនជាងមួយជាន់ នៅក្នុងភូមិតែមួយ និងមានផ្ទះ ដែលជាកម្មសិទ្ធិរបស់ម្ចាស់តែមួយ ទើបអាចផ្តល់ប័ណ្ណកម្មសិទ្ធិក្រោមការចុះបញ្ជី ដីធ្លីមានលក្ខណៈជាប្រព័ន្ធបាន។ ម្ចាស់អចលនទ្រព្យក្នុងប្លុកតាន់ប៉ា អាចទទួលបាន ប័ណ្ណកម្មសិទ្ធិ សម្រាប់អចលនទ្រព្យពួកគេ តាមរយៈការចុះបញ្ជីដីធ្លីមានលក្ខណៈ ដាច់ដោយដុំ ប៉ុន្តែវាត្រូវការចំណាយប្រាក់កាស ពេលវេលា និងការប្រឹងប្រែងច្រើន។

លទ្ធផលនៃការសិក្សានេះបានបង្ហាញថា សហគមន៍ទាំងឡាយ លើកលែង តែប្លុកតាន់ប៉ា ដែលត្រូវបានផ្ទៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធគឺ ដោយសារសហគមន៍ទាំងនោះបានកាន់កាប់ដីសាធារណៈរបស់រដ្ឋ ដែលពុំអាច ក្លាយជាម្ចាស់កម្មសិទ្ធិឯកជនបានឡើយ។ សហគមន៍ទាំងនោះត្រូវបានផ្ទៀលចេញ ហើយនៅរង់ចាំសេចក្តីសម្រេចរបស់រដ្ឋាភិបាលនៅពេលក្រោយ ជាពិសេសពី អភិបាលរាជធានីភ្នំពេញ។ តារាងទី ៥ បង្ហាញជាសង្ខេបនូវមូលហេតុនៃការផ្ទៀល សហគមន៍ក្រីក្រចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ ការសង្កេតដែល បានធ្វើឡើងនៅតាមសហគមន៍ទាំងអស់បានបញ្ជាក់ថា គ្រួសារទាំងនោះបានបោះ ទីតាំងនៅលើដីសាធារណៈរបស់រដ្ឋ។ ទោះបីជាយ៉ាងណាក៏ដោយ គ្រួសារភាគច្រើន បានមកតាំងទីលំនៅនៅលើដីនោះ មុនពេលដែលដីនោះត្រូវបានគេតំណត់អត្ត

សញ្ញាណទៅទៀត (មានតែ២៧% ប៉ុណ្ណោះ នៃគ្រួសារទាំងនោះដែលបានមកតាំងទីលំនៅក្រោយឆ្នាំ ២០០១)។

**តារាងទី៥ ៖ មូលហេតុដែលអាចបណ្តាលឲ្យមានការផ្ទៀលចេញ**

| ខណ្ឌ | ឈ្មោះសហគមន៍ក្រីក្រនៅទីប្រជុំជន | មូលហេតុនៃការផ្ទៀលចេញ |
|---|---|---|
| ចំការមន | ថៅពញាហុក | ស្ថិតលើចិញ្ចើមផ្លូវធំ |
| | បឹងត្របែក | នៅជុំវិញ និងនៅលើប្រឡាយទឹកស្អុយ |
| ដង្កោ | ភូមិអ្នកតា | នៅជុំវិញដីទំនេរដែលជាដីរួមរបស់ភូមិ |
| | ចេក | នៅលើប្រឡាយទឹក និងបឹងធំ |
| ដូនពេញ | ផ្លូវរថភ្លើង | នៅកៀកនឹងផ្លូវរថភ្លើង |
| | ប្លុកតាន់ប៉ា | មិនស្ថិតក្រោមកម្មវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធដោយសារជាន់នីមួយៗនៅប្លុកតាន់ប៉ាស្ថិតក្នុងភូមិខុសៗគ្នា និងមានម្ចាស់ផ្សេងៗគ្នា |
| មានជ័យ | ព្រែកតានូ ២ | នៅលើច្រាំងទន្លេមេគង្គ ឬស្ថិតនៅលើដីដែលជាអតីតផ្សារ និងចំណតឡានតាស៊ីដែលជាដីរដ្ឋ |
| | ថ្មសាន | នៅជុំវិញផ្នូរ លើទីវាលកប់សព |
| សែនសុខ | ទឹកថ្លា ២ | នៅលើផ្នែកនៃចិញ្ចើមផ្លូវ និងផ្លូវ |
| | បុរី ១០០ ខ្នង | នៅកៀកផ្លូវរថភ្លើងដែលកំពុងដំណើរការ |
| ទួលគោក | ១០២ | នៅលើចិញ្ចើមផ្លូវតាមបណ្តោយផ្លូវធំ |
| | ៣៤៧ | នៅលើផ្លូវដែលរដ្ឋចង់ពង្រីក |

## ៤.៥ ការយល់ដឹងរបស់ប្រជាជនស្តីពីការផ្ទៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

បើទោះបីជាសហគមន៍ក្រីក្រចំនួន ១០ ក្នុងចំណោម ១២ ត្រូវបានគេប្រាប់យ៉ាងជាក់ច្បាស់ថា សហគមន៍នោះត្រូវបានគេផ្ទៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធក៏ដោយ ក៏មានតែគ្រួសារប្រហែលជាពាក់កណ្តាលប៉ុណ្ណោះនៃគ្រួសារដែលបានសម្ភាសន៍ ធ្លាប់ត្រូវបានគេផ្តល់ដំណឹងអំពីហេតុផលជាផ្លូវការសម្រាប់ការផ្ទៀលចេញ។ តាមពិតទៅ គ្មានអ្នកតបសម្ភាសន៍ណាម្នាក់ក្នុងចំណោម ៦០នាក់ដែលបានជ្រើសរើសសម្រាប់ការសិក្សានេះ ធ្លាប់បានអាជ្ញាធរមូលដ្ឋាន ឬ

ក្រុមការងាយចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ពិគ្រោះយោបល់ជាមួយមុននឹងមានការផ្លៀលចេញនោះទេ។ ការសម្រេចចិត្តក្នុងការកាត់ចេញនូវតំបន់ណាមួយនៅក្នុងភូមិ ទំនងជាបានធ្វើឡើង ដោយគណៈកម្មាការរដ្ឋបាលនៃក្រុមចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដោយគ្រាន់តែមានការពិគ្រោះយោបល់ខ្លះៗជាមួយនឹងអាជ្ញាធរមូលដ្ឋានប៉ុណ្ណោះ។ ដោយមិនត្រូវបានគេជូនដំណឹង គ្រួសារក្រីក្របានត្រឹមតែមានមន្ទិលសង្ស័យអំពីមូលហេតុនៃការផ្លៀលចេញ និងលទ្ធផលដែលអាចនឹងកើតមានឡើងតែប៉ុណ្ណោះ។ គ្រួសារក្រីក្រ និងមេភូមិដែលបានចូលរួមក្នុងការសិក្សានេះ ហាក់ដូចជាពុំមានការស្វះស្វែងរកដំណោះស្រាយ ដូចដែលមានការលើកឡើងថា «សហគមន៍ក្រីក្រនៅទីប្រជុំជនអាចនឹងធ្វើសំណើរ តាមរយៈអជ្ញាធរមូលដ្ឋានទៅកាន់អភិបាលរាជធានីដែលលោកជាអ្នកមានសិទ្ធិសម្រេចចុងក្រោយ ទៅលើដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដើម្បីស្នើសុំឲ្យមានការដាក់បញ្ចូលសហគមន៍ដែលបានផ្លៀលចេញ ទៅក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធបាន។ ប្រសិនជាមានការយល់ព្រមពីអភិបាលរាជធានី ក្រុមការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ អាចនឹងត្រឡប់មកចុះបញ្ជីដីធ្លីក្នុងតំបន់ដែលបានផ្លៀលចេញសារជាថ្មី» (នេះបើតាមការពិភាក្សាជាក្រុមជាមួយមន្ត្រីមន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់)។

ករណីសហគមន៍ប្លុកតាន់ប៉ា បានបង្ហាញពីភាពខ្វះខាតព័ត៌មានដែលនាំឲ្យអ្នករស់នៅទីនោះបន្តរស់នៅក្នុងភាពមិនប្រាកដប្រជា។ សហគមន៍មិនបានដឹងថាហេតុអ្វីបានជាពួកគាត់ត្រូវបានផ្លៀលចេញ ហើយក៏មិនដឹងថាពួកគាត់គួរធ្វើយ៉ាងណាដើម្បីទទួលបានបណ្ណ័កម្មសិទ្ធិលើអចលនទ្រព្យរបស់ពួកគាត់នោះដែរ។ ករណីសហគមន៍ប្លុកតាន់ប៉ានេះ គឺមានលក្ខណៈខុសផ្លែកពីគេក្នុងចំណោមសហគមន៍ទាំង ១២។ មន្ត្រីមកពីមន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់ បានឲ្យដឹងថាសហគមន៍ប្លុកតាន់ប៉ាមិនបានស្ថិតនៅលើដីរបស់រដ្ឋនោះទេ តែស្ថានភាពតំបន់នោះមិនស្ថិតនៅក្រោមនីតិវិធីរបស់កម្មវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ អ្នករស់នៅតំបន់នេះក៏មិនទាន់បានដឹងថាពួកគាត់អាចនឹងទទួលបានបណ្ណ័កម្មសិទ្ធិ តាមរយៈការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំនោះដែរ។

ករណីសិក្សាទី១[២២] បង្ហាញពីកង្វះខាតចំណេះដឹង និងការយល់ដឹងអំពីការផ្លៀសចេញមិនត្រឹមតែនៅក្នុងចំណោមគ្រួសារនៅក្នុងសហគមន៍ក្រីក្រនោះទេ តែរួមទាំងអាជ្ញាធរមូលដ្ឋានផងដែរ។ កង្វះខាតព័ត៌មានក៏អាចបណ្តាលអោយមានការយល់ខុស និងខ្វះការជឿជាក់ទៅលើអាជ្ញាធរមូលដ្ឋានផងដែរ។

## ករណីសិក្សាទី ១ ៖ ខ្ញុំមិនយល់ថាហេតុអ្វីបានគេផ្លៀសដីពួកយើងចេញ

អ្នកស្រីចំប៉ា មានអាយុ ៤០ឆ្នាំ រស់នៅក្នុងសហគមន៍ប្លុកតាន់ប៉ា។ គាត់ជាអ្នកលក់ទំនិញនៅផ្សារមួយនៅក្នុងរាជធានីភ្នំពេញ រកប្រាក់ចំណូលបានប្រហែលជា ៣០ដុល្លាអាមេរិក ក្នុងមួយថ្ងៃ ដើម្បីចិញ្ចឹមកូនចំនួន២នាក់។ ក្នុងឆ្នាំ ២០០៧ គាត់បានទិញផ្ទះនៅជាន់ដំបូលមួយ ក្នុងប្លុកតាន់ប៉ាក្នុងតម្លៃ ២៥.០០០ដុល្លារអាមេរិក ដោយមានលិខិតទិញលក់ទទួលស្គាល់ដោយអជ្ញាធរមូលដ្ឋាន។ គាត់បានដឹងថា គ្រួសារខ្លះ ដែលនៅជាន់ក្រោមគាត់បានទទួលបណ្ណ័កម្មសិទ្ធិប៉ុន្តែគ្មានគ្រួសារមួយដែលនៅជាន់ដំបូលដូចគាត់មានបណ្ណ័កម្មសិទ្ធិនោះទេ។

ដោយខ្វះការយល់ដឹងពីដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងមិនមានគ្រួសារណាមួយ ក្នុងសហគមន៍របស់គាត់បានទទួលប័ណ្ណកម្មសិទ្ធិដីធ្លី វាបានបណ្តាលឲ្យអ្នកភូមិកើតគំនិតយល់ឃើញថា សហគមន៍ត្រូវបានគេផ្លៀសចេញដោយសារតែសហគមន៍គាត់ត្រូវបានគេចាត់ទុកថាជាតំបន់អនាធិបតេយ្យ។ អ្នកស្រីបានរៀបរាប់ដោយក្តីខឹងសម្បាថា ៖

> ខ្ញុំមិនយល់ថាហេតុអ្វីបានជាដីយើង ត្រូវបានគេផ្លៀសចេញពីការចុះបញ្ជី។ ពួកយើង ទាំងអស់គ្នាបានគិតថាប្រហែលជាសហគមន៍របស់យើងអាចត្រូវបានគេចាត់ទុកថា ជាសំណង់អនាធិបតេយ្យហើយបានជាគេមិនចុះបញ្ជីអោយ ក៏ប៉ុន្តែពួកយើង ភាគច្រើនមានប្លង់ទន់។ គ្មាននរណាម្នាក់មកប្រាប់យើងថាហេតុអ្វីបានជាគេមិនផ្តល់ប័ណ្ណកម្មសិទ្ធិជាផ្លូវការអោយនោះទេ។ យើងបានសួរមេភូមិ និងចៅសង្កាត់ ជាច្រើនដងហើយ ប៉ុន្តែពួកគេបានប្រាប់ថា គ្រួសាររបស់ពួកយើងអាចនឹងត្រូវបាន គេដាក់បញ្ចូលក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ នៅលើកក្រោយ។ ... អាជ្ញាធរមូលដ្ឋានដូចជាមិនសូវជួយអី ពួកយើងនោះទេ ហើយពួកគេមិនបាន ធ្វើអ្វីដើម្បីជាការជួយពួកយើងឲ្យទទួលបានប័ណ្ណកម្មសិទ្ធិនោះឡើយ។

---

[២២] ដើម្បីការពារអត្តសញ្ញាណរបស់អ្នកចូលរួមក្នុងការសិក្សានេះ គ្រប់ឈ្មោះទាំងអស់ដែលប្រើប្រាស់ក្នុង ករណីសិក្សា គឺជាឈ្មោះមិនពិត។

## ៤.៦ ការយល់ច្រឡំអំពីភស្តុតាងនៃសិទ្ធិកាន់កាប់

ជិតពាក់កណ្តាលនៃគ្រួសារ ដែលបានចូលរួមក្នុងការសិក្សានេះ (N=២៧, ៤៥%) បានឆ្លើយថាពួកគាត់មានភស្តុតាងកម្មសិទ្ធិដីធ្លីដែលបានកាន់កាប់។ ក្នុងនោះ មានតែ ១៤គ្រួសារ ប៉ុណ្ណោះមានប្លង់ទន់ ចំណែក ១៣គ្រួសារ ផ្សេងទៀត មានតែសៀវភៅគ្រួសារ និងខ្លះទៀតមានអត្តសញ្ញាណប័ណ្ណតែប៉ុណ្ណោះ។ សៀវភៅគ្រួសារដែលមានអាសយដ្ឋានបច្ចុប្បន្ន ត្រូវបានគាត់យល់ច្រឡំថាជាភស្តុតាងនៃកម្មសិទ្ធិលើ «អចលនទ្រព្យរបស់គាត់»។ សៀវភៅគ្រួសារដែលចេញដោយប៉ូលិសខណ្ឌគឺសម្រាប់គោលបំណងប្រើប្រាស់ក្នុងការងាររដ្ឋបាលតែប៉ុណ្ណោះ មិនមែនជាភស្តុតាងស្របច្បាប់បញ្ជាក់ពីភាពជាម្ចាស់កម្មសិទ្ធិ ហើយមិនមានតម្លៃស្មើនឹងប្លង់ទន់នោះទេ។ ប្លង់ទន់សំដៅទៅលើឯកសារទិញលក់អចលនទ្រព្យដែលត្រូវបានបញ្ជាក់ ឬមានសាក្សីដឹងឮពីអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធចាប់តាំងពីមេភូមិ រហូតដល់អភិបាលខេត្ត/ក្រុង។

មានហេតុផលជាច្រើនទាក់ទងនឹងកង្វះខាតភស្តុតាងនៃកម្មសិទ្ធិភាព។ អ្នកតាំងទីលំនៅដំបូង អាចបានរស់នៅលើដីទំនេរដែលមិនមានការអនុញ្ញាតស្របច្បាប់ពីអាជ្ញាធរមូលដ្ឋាន ដូចជាមុនឆ្នាំ ១៩៩០ អាជ្ញាធរមូលដ្ឋានមិនសូវរវល់ពីការសង់ទីលំនៅរបស់ប្រជាជននៅលើដីសាធារណៈ។ អ្នកខ្លះនៅបន្តរស់នៅតំបន់នោះ ឯខ្លះទៀតបានលក់ផ្ទះរបស់គេ ក៏ប៉ុន្តែការផ្លាស់ប្តូរអចលនទ្រព្យនេះគឺមិនមានការដឹងឮនោះទេ។ អ្នកតាំងទីលំនៅថ្មី រួមទាំងអ្នកភូមិក្រីក្រ បានបង្ខំចិត្តលក់ផ្ទះ ឬដីរបស់គាត់ ហើយគូរស្រេករថ្មីដែលបានចាកចេញពីផ្ទះអាណាព្យាបាលរបស់ខ្លួន ក៏បានមកតាំងទីលំនៅលើដីសាធារណៈនៅក្នុងភូមិ។ មានគ្រួសារខ្លះបានបាត់បង់ឯកសារកាន់កាប់អចលនទ្រព្យរបស់ខ្លួន ឬឯកសារទាំងនោះត្រូវបានបំផ្លាញដោយអគ្គីភ័យ ទឹកជំនន់ ឬស្ថានភាពផ្សេងៗទៀត។

## ៤.៧ ផែនការបណ្តេញចេញ

មានករណីជាច្រើនពាក់ព័ន្ធនឹងការបណ្តេញចេញដោយបង្ខំ ត្រូវបានរាយការណ៍នៅក្នុងរាជធានីភ្នំពេញ។ ប៉ុន្តែករណីនេះមិនបានកើតឡើងក្នុងរយៈពេល ២៤ខែកន្លងទៅនោះទេ។[២៣] ប្រជាជន អាជ្ញាធរមូលដ្ឋាន មន្ត្រីមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលបានចូលរួមក្នុងការសម្ភាស បានលើកឡើងថារដ្ឋាភិបាលមិនមានផែនការបណ្តេញសហគមន៍ក្រីក្រទាំង១២ ចេញដោយបង្ខំនោះទេ។ មេភូមិមួយចំនួនបានរាយការណ៍ថា បើទោះបីជាគ្រួសារទាំងនោះមិនទាន់បានទទួលប្លង់រឹងសម្រាប់បញ្ជាក់អចលនទ្រព្យក្តី ពួកគាត់នៅតែអាចបន្តរស់នៅក្នុងសហគមន៍នោះបាន ខណៈពេលដែលរង់ចាំការសម្រេចណាមួយរបស់រាជរដ្ឋាភិបាលនៅថ្ងៃអនាគត។ ប្រហែលជាជាងពាក់កណ្តាលនៃគ្រួសារដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ ជឿជាក់ថាការបណ្តេញចេញនឹងមិនកើតមានឡើងនាពេលឆាប់ៗនេះទេ។

នៅក្នុងសហគមន៍ចំនួនពីរ (ទឹកថ្លា និងព្រែកតានូ២) អ្នកភូមិបានរាយការណ៍ថា មានមនុស្សប្លែកមុខបានមកសាកសួរទិញផ្ទះរបស់ពួកគាត់។ ពួកនោះបានបង្កើតពាក្យចចាមអារាមថា ទង្វើនេះជាយុទ្ធសាស្ត្រថ្មីដែលរដ្ឋាភិបាលប្រើប្រាស់ដើម្បីទិញផ្ទះរបស់ពួកគាត់ជាជាងការបណ្តេញចេញដោយបង្ខំ។ យើងមិនអាចផ្ទៀងផ្ទាត់បានទេថា តើព័ត៌មាននេះអាចជឿជាក់បានឬយ៉ាងណា ប៉ុន្តែដោយសារតែគ្មានព័ត៌មានច្បាស់លាស់ ពាក្យចចាមអារាមនោះវាបានផ្តល់នូវសេចក្តីសង្ឃឹមខ្លះៗដល់សហគមន៍ក្រីក្រនៅទីប្រជុំជនដែលត្រូវបានគេផ្លៀលចេញ។ ករណីសិក្សាទី២ បង្ហាញពីដំណើរការនេះ។

[២៣] ប៉ុន្តែ STT (២០១៤) យោងតាមការសម្ភាសរបស់គេ មានការរាយការណ៍ថាយ៉ាងហោចណាស់សហគមន៍ក្រីក្រនៅទីក្រុងចំនួន ៣៦ ត្រូវបានទទួលព័ត៌មានពីការបណ្តេញចេញក្នុងឆ្នាំ ២០១៣។

**ករណីសិក្សាទី ២ ៖ យុទ្ធសាស្ត្រថ្មី ក្តីសង្ឃឹមថ្មី**

លោក ស័ក្កិ មានអាយុ ៣៦ឆ្នាំ មានកូនចំនួន ២នាក់។ គាត់មានមុខរបរជាអ្នកលក់ដូរតាមចិញ្ចើមថ្នល់។ គាត់ទទួលបានផ្ទះនៅសហគមន៍ ព្រែកតានូ២ ពីឪពុក ម្តាយរបស់គាត់ដែលបានរស់នៅទីនោះតាំងពីឆ្នាំ ១៩៧៩។ ផ្ទះរបស់គាត់បានឆេះ ចំនួនពីរលើក ដែលលោក ស័ក្កិ បានបាត់បង់ប្លង់ទន់របស់គាត់។ គាត់ជំពាក់បំណុល គេច្រើនពីព្រោះគាត់បានយកប្រាក់កម្ចីមកជួសជុលផ្ទះ។ នៅពេលដែលបាន សួរគាត់ថាតើគាត់មានអារម្មណ៍យ៉ាងណាចំពោះការផ្លៀលចេញ គាត់បានឆ្លើយ ថាគាត់មិនព្រួយបារម្ភអ្វីនោះទេ ពីព្រោះបច្ចុប្បន្នមិនមានការគម្រាមកំហែងពាក់ព័ន្ធ នឹងការបណ្តេញចេញ ហើយគាត់ក៏អាចប្រកបរបរបានជាធម្មតាដែរ។ គាត់ជឿជាក់ថា មេភូមិបានដឹងថាគ្រួសាររបស់គាត់បាន តាំងទីលំនៅក្នុងសហគមន៍ នេះជាច្រើន ទសវត្សរ៍មកហើយ ដូច្នេះគ្រួសារគាត់មិនមែន ជាអ្នករស់នៅខុសច្បាប់នោះទេ។ គាត់ហាក់ដូចជាជឿជាក់ថាប្រសិនបើសហគមន៍ត្រូវបានគេឲ្យផ្លាស់ប្តូរទីលំនៅរដ្ឋាភិបាលនឹងផ្តល់សំណងឲ្យគាត់សមស្រប។ គាត់បញ្ជាក់ថា៖

> យើងមិនបានដឹងអំពីផែនការណាមួយ របស់រដ្ឋាភិបាលក្នុងការបណ្តេញចេញពីនោះទេ។ ប្រសិនបើមាន វាពិតណាស់ដែលថាគ្រួសាររបស់ខ្ញុំនឹងទទួលបានសំណងយ៉ាងសមស្របមួយ។ ... សព្វថ្ងៃនេះមានឈ្មួញបានមកសហគមន៍របស់យើងដើម្បីទិញផ្ទះ។ យើងគិតថានេះជាយុទ្ធសាស្ត្រថ្មីរបស់រដ្ឋាភិបាលដើម្បីទិញផ្ទះប្រជាជន ជាជាងបណ្តេញប្រជាជនចេញ។ គេបានអោយថ្លៃផ្ទះរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនព្រមលក់ដោយសារមិនទាន់ត្រូវថ្លៃគ្នា។

## ៤.៨ ផលប៉ះពាល់នៃការផ្លៀលចេញ

គ្រួសារដែលបានតបសម្ភាសន៍ភាគច្រើនជឿជាក់ថា ការដែលមានប្លង់កម្មសិទ្ធិ គឺមានផលប្រយោជន៍ណាស់ ដោយសារវាអាចការពារពីការបណ្តេញចេញ និងអាចទទួលបានសំណងសមស្របប្រសិនជាមានការបណ្តេញចេញ អាចលក់ដូរអចលនទ្រព្យក្នុងតម្លៃប្រសើរ អាចទទួលបាននូវប្រាក់កម្ចីពីធនាគារជាមួយនឹងការប្រាក់ទាប និងអាចផ្ទេរទ្រព្យសម្បត្តិឲ្យកូនៗជំនាន់ក្រោយបានទៀតផង។ គ្រួសារទាំងអស់ចង់ទទួលបានប្លង់កម្មសិទ្ធិស្របច្បាប់ បើទោះបីជាមួយភាគបីនៃអ្នកទាំង

នោះ មិនមានអារម្មណ៍ថាការដែលត្រូវបានគេផ្លៀលចេញមានផលប៉ះពាល់អវិជ្ជមានដល់គ្រួសាររបស់គាត់ក៏ដោយ។ អ្នកដែលមិនមានអារម្មណ៍ថាការផ្លៀលចេញមានផលអវិជ្ជមាន ដោយសារតែគាត់មិនគិតថាមានហានិភ័យណាមួយ ទាក់ទងនឹងការបណ្តេញចេញ ហើយគាត់ជឿជាក់ថានឹងទទួលបានសំណង ប្រសិនបើមានការបណ្តេញចេញពិតប្រាកដមែននេះ ក៏ជាការកាត់បន្ថយអារម្មណ៍ដែលគ្មានសុវត្ថិភាពលំនៅឋានម្យ៉ាងដែរ។ មន្ត្រីមកពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានលើកឡើងថា សព្វថ្ងៃនេះរដ្ឋាភិបាលមិនមានផែនការបណ្តេញសហាគមន៍ក្រីក្រដែលមករស់នៅលើដីសាធារណៈចេញនោះទេ។ ពួកគាត់ក៏បាន បន្ថែមដែរថា ប្រសិនជាមានផែនការនោះមែន រាជរដ្ឋាភិបាលនឹងពិចារណាផ្តល់សំណងសមរម្យដល់គ្រួសារដែលនឹងត្រូវបានបណ្តេញចេញទាំងនោះ ហើយទីតាំងថ្មីក៏នឹងត្រូវបានរៀបចំជាមុនអោយបានសមរម្យដែរ។ ករណីសិក្សាទី ៣ បង្ហាញពីការរំពឹងទុករបស់អ្នករស់នៅក្នុងសហាគមន៍ក្រីក្រនៅទីក្រុងទាក់ទិននឹងសំណងសមរម្យ ដែលគាត់អាចនឹងទទួលបានប្រសិនបើមានការតាំងទីលំនៅថ្មី។

មានប្រជាជនខ្លះបាននិយាយថា ប្លង់កម្មសិទ្ធិគឺមិនសូវចាំបាច់ទេ ពីព្រោះគ្រួសារដែលរស់នៅក្នុងសហាគមន៍ក្រីក្រទាំង១២ ជាទូទៅនៅតែទទួលបានសេវាសាធារណៈ ដូចជាទឹកស្អាត អគ្គិសនី ប្រព័ន្ធលូ និងសេវាប្រមូលសំរាមដែរ។ គ្រួសារនានា និងកូនៗរបស់គាត់ក៏អាចទទួលបានសេវាសុខភាព និងការអប់រំដែរ។ ទោះបីជាយ៉ាងនេះក្តី ក្រៅពីសហាគមន៍ថៅពញ្ញាហុក សហាគមន៍ប្លុកតាន់ប៉ា និងសហាគមន៍១០២ ដែលមានទីតាំងនៅផ្លូវធំ ឬតំបន់ពាណិជ្ជកម្មនោះ សហាគមន៍ចំនួន៩ផ្សេងទៀត មានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាពិសេសផ្លូវថ្នល់ ប្រព័ន្ធលូតិចតួចប៉ុណ្ណោះ។ ប្រជាជនបានរៀបរាប់ថា ដោយសារតែសហាគមន៍របស់គាត់ត្រូវបានអាជ្ញាធរមូលដ្ឋានចាត់ទុកជាតំបន់អនាធិបតេយ្យ ដូច្នេះពុំសូវមានកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងសហាគមន៍ទាំងនេះឡើយ។ ជារឿយៗ អ្នកភូមិរស់នៅក្នុងសហាគមន៍ក្រីក្របានប្រើប្រាស់ធនធានផ្ទាល់ខ្លួនក្នុងការជួសជុលផ្លូវ ប្រព័ន្ធលូទឹកស្អុយ និងប្រមូលសំរាម។ នេះគឺជាមូលហេតុចម្បងៗដែលនាំឲ្យពួកគេមានអារម្មណ៍ខឹងសម្បារដល់អាជ្ញាធរមូលដ្ឋាន និងរាជរដ្ឋាភិបាល។

**ករណីសិក្សាទី ៣ ៖ ខ្ញុំជឿថារដ្ឋាភិបាលគិតគូដល់យើង**

លោក រុំ អង្គុយនៅលើគ្រែឈើតូចចាស់មួយនៅក្រោមដើមស្វាយនៅក្នុងវាលកប់សព។ នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ គាត់ និងគ្រួសារ បានសាងសង់ខ្ទមតូចមួយទំហំ ៣ម៉ែត្រគុណនឹង៣ម៉ែត្រ ក្នុងវាលកប់សពនៅថ្មសានដោយមានការអនុញ្ញាតពីមេភូមិ។ គាត់ធ្វើការសំណង់ ហើយរកចំណូល បាន១ថ្ងៃ ៥ដុល្លារអាមេរិក ដើម្បីផ្គត់ផ្គង់គ្រួសារទាំងមូលដែលមានកូនចំនួន ២នាក់។ ប៉ុន្មានខែថ្មីៗ ប្រពន្ធរបស់គាត់បានយកកូនម្នាក់ទៅស្រុកកំណើតនៅខេត្តស្វាយរៀង និងមិនទាន់ត្រឡប់មកវិញទេ។គាត់ជឿថាប្រពន្ធ និងកូនគាត់នឹងមិនត្រឡប់មកវិញទេ ពីព្រោះបើពួកគេបន្តរស់នៅជាមួយគាត់ គាត់នឹងមិនមានលទ្ធភាពចិញ្ចឹមពួកគេទេ ដោយសារ តែប្រាក់ចំណូលតិចតួច និងមិនទៀងទាត់។

គាត់ក៏ដូចជាគ្រួសារចំនួន ៩០ ផ្សេងទៀត ដែលរស់នៅវាលកប់សពនេះដែរ គឺត្រូវបានគេផ្លៀសដីចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ ពេលដែលសួរថា គាត់គិតដូចម្តេចនៅពេលដែលត្រូវបានគេផ្លៀសចេញដូចនេះ គាត់ឆ្លើយដោយញញឹមថា៖

> យើងបានរស់នៅក្នុងវាលកប់ខ្មោច ហើយក៏មិនដែលសង្ឃឹមទេថាទទួលបានប្លង់កម្មសិទ្ធិនោះដែរ។ ដូច្នេះខ្ញុំមិនខ្វល់ថានឹងបានទទួលប្លង់កម្មសិទ្ធិ ឬយ៉ាងណានោះទេ។ នេះគឺជាផ្ទះតែមួយគត់ដែលខ្ញុំមាន ហើយខ្ញុំមិនដែលឮពីផែនការបណ្តេញចេញនោះទេ ប៉ុន្តែបើទោះបីជាមានមែន ក៏ខ្ញុំគិតថារដ្ឋាភិបាលនឹងផ្តល់សំណងអ្វីមួយដល់ពួកយើងដែរ។

### *៤.៨.១ ការភ័យខ្លាច និងក្តីកង្វល់*

ក្នុងចំណោមអ្នកដែលគិតថា មានផលប៉ះពាល់អវិជ្ជមានដោយសារតែមានការផ្លៀសចេញ និងគ្មានប័ណ្ណកម្មសិទ្ធិជាផ្លូវការ ការភ័យខ្លាចរបស់ពួកគាត់កើតមានដោយសារក្តីកង្វល់ចំពោះអសន្តិសុខ ការភ័យខ្លាចមានការបណ្តេញចេញ និងភាពមិនច្បាស់លាស់នៃអនាគតរបស់គាត់។ កង្វល់ទាំងនេះត្រូវបានលើកឡើងដោយអ្នកចូលរួមតបសម្ភាសន៍ចំនួន ៤៨% នៃគ្រួសារដែលត្រូវបានសម្ភាសន៍។ ស្ត្រី (៥៨%) គឺជាអ្នកមានអារម្មណ៍ភ័យខ្លាច និងក្តីកង្វល់ខ្លាំងបើធៀបនឹងបុរស

(៣០%) ដូចករណីសិក្សាទី៤ បានបង្ហាញ។ ការសិក្សាមួយអំពីផលប៉ះពាល់នៃការបណ្តេញចេញដែលកើតមានឡើងចំពោះស្ត្រី បានបង្ហាញថា សុវត្ថិភាពលំនៅឋានមានសារៈសំខាន់បំផុតសម្រាប់ស្ត្រី ព្រោះវាបានធ្វើអោយស្ត្រីមានអារម្មណ៍ថាមានសុវត្ថិភាព និងឯករាជ្យភាព។ សម្រាប់បុរសវិញ សុវត្ថិភាពលំនៅឋានត្រូវបានគេគិតថាជាមធ្យោបាយមួយក្នុងការទទួលបានជីវភាពធូរធារ និងឋានៈក្នុងសង្គម។ កង្វះខាតសុវត្ថិភាពលំនៅឋានបានកាត់បន្ថយ លទ្ធភាពទទួលបានការងារដែលមានសុវត្ថិភាពសម្រាប់ស្ត្រីដើម្បីទ្រទ្រង់គ្រួសាររបស់គាត់ និងធានាអំពីអនាគតរបស់កូនៗ។ ភាពតានតឹងអំពីលំនៅឋានមិនជាក់លាក់ អាចបង្កើតឲ្យមានហានិភ័យនៃអំពើហិង្សានៅក្នុងគ្រួសារ (Strey Khmer ២០១៣)។ បើទោះបីជារបកគំហើញខាងក្រោមនេះមើលទៅដូចជាមិនសូវជាមានលក្ខណៈធ្ងន់ធ្ងរ អ្នកដែលរស់នៅក្រោយការចេញច្បាប់ភូមិបាលឆ្នាំ ២០០១ មានការភ័យខ្លាចជាង បើប្រៀបធៀបទៅនឹងអ្នកដែលតាំងទីលំនៅមុនឆ្នាំ ២០០១ (៥៦% នៃអ្នកតាំងទីលំនៅថ្មីមានអារម្មណ៍ភ័យខ្លាចប្រៀបធៀបនឹង ៣៦% នៃអ្នកតាំងទីលំនៅចាស់)។ ជាងនេះទៅទៀតជាងពាក់កណ្តាល (៥៣%) នៃគ្រួសារ ដែលត្រូវបានសម្ភាសន៍ដែលរស់នៅក្នុងខណ្ឌជាយក្រុង បានបង្ហាញអំពីអារម្មណ៍ភ័យខ្លាច បើប្រៀបធៀបទៅនឹង ៣០% នៃអ្នកដែលរស់នៅក្នុងខណ្ឌក្នុងទីក្រុង។ យើងមានការភ្ញាក់ផ្អើលដែលបានរកឃើញថាអ្នកដែលមានប្លង់ទន់[២៤] មានការភ័យខ្លាចជាងអ្នកមិនមានប្លង់ទន់(៥៩%និង ២៧%)។

[២៤] នេះរួមទាំងគ្រួសារដែលមានប្លង់ទន់ ព្រមទាំងអ្នកទាំងឡាយដែលមានសៀវភៅគ្រួសារសំអាងថាជាភស្តុតាងកម្មសិទ្ធិស្របច្បាប់ដែរ។

## ករណីសិក្សា ៤ ៖ អ្នកដែលត្រូវបានផ្លៀលចេញ និងអសន្តិសុខភាព

អ្នកស្រី បុប្ផា អាយុ ៤៣ ឆ្នាំ ប្តី និងកូនប្រុសរបស់គាត់រស់នៅភូមិចេក ខណ្ឌដង្កោ។ អ្នកស្រីមានហាងតូចមួយលក់ដូរគ្រឿងទេស ហើយប្តីរបស់អ្នកស្រីជាអ្នករត់ម៉ូតូឌុប។ គ្រួសារគាត់មានប្រាក់ចំណូល រួមប្រហែលជា ១២ដុល្លារអាមេរិក ក្នុងមួយថ្ងៃ គ្រួសាររបស់គាត់មានជីវភាពប្រសើរជាងអ្នករស់នៅជិតខាង ដោយសារគាត់មានផ្ទះធំ។ អ្នកស្រីទិញផ្ទះរបស់គាត់ពីរបីឆ្នាំកន្លងមកហើយពីបងស្រីដែល ស្នាក់នៅសហគមន៍ក្រីក្រនេះជាច្រើនទសវត្សរ៍មកហើយ។

អ្នកស្រី បុប្ផា មានការខឹងសម្បារ នឹងអាជ្ញាធរមូលដ្ឋានដែលបានផ្លៀលសហគមន៍របស់គាត់ចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ ទោះបីជាការផ្លៀលចេញនេះ មិនមានផលប៉ះពាល់ដោយផ្ទាល់ដល់ជីវភាពគ្រួសារគាត់ក៏ដោយ អ្នកស្រីព្រួយបារម្ភពីសុវត្ថិភាពលំនៅឋានរបស់គ្រួសារ ពីព្រោះអ្នកស្រីភ័យខ្លាចថាថ្ងៃណាមួយសហគមន៍នេះនឹងត្រូវបង្ខំឲ្យចាកចេញ។ អ្នកស្រីនិយាយថាប្រជាជនមួយចំនួនដែលទទួលបានប័ណ្ណកម្មសិទ្ធិបានមើលងាយដល់គ្រួសារអ្នកស្រី និងគ្រួសារអ្នកជិតខាងក្នុងសហគមន៍ក្រីក្រ។ ចំពោះអ្នកស្រី អារម្មណ៍ដែលមិនមានសុវត្ថិភាពដីធ្លី និងការមិនផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីសម្រាប់អ្នកភូមិគឺជាការកាត់ផ្តាច់ពួកគាត់ចេញពីសង្គម។

គ្រួសារដែលត្រូវបានសម្ភាសន៍ចំនួន ១០% បានលើកឡើងពីក្តីកង្វល់ដែលកើតមានឡើងដោយសារមានអារម្មណ៍ថា មានភាពមិនប្រាកដប្រជាក្នុងការរស់នៅ។ ឧទាហរណ៍ បើទោះបីជាមានថវិកាក៏ពួកគាត់មានអារម្មណ៍ស្ទាក់ស្ទើរក្នុងការជួសជុលផ្ទះរបស់គាត់ដែរ។ ពួកគាត់មិនមានអារម្មណ៍ជឿជាក់ថាមានទ្រព្យសម្បត្តិដើម្បីផ្ទេរឲ្យកូនៗរបស់គាត់ទេ។ នេះគឺជាករណីរបស់អ្នកស្រីឈ្មោះស្រី ដូចមានក្នុងករណីសិក្សាទី៥។

## ករណីសិក្សា ៥ ៖ ជីវិតរស់នៅក្នុងតំបន់មិនពិតប្រាកដ

អ្នកស្រី ស្រី អាយុ ៤៧ឆ្នាំ បម្រើការងារនៅអង្គការមួយ មានកូន ៧នាក់។ កូនចំនួន ២នាក់ តែងតែឈឺជារឿយៗ និង២នាក់ផ្សេងទៀតបានឈប់រៀនពីព្រោះគ្រួសារមិនអាចផ្គត់ផ្គង់បាន។ ក្នុងឆ្នាំ ១៩៩៤ គ្រួសារអ្នកស្រីបានទិញផ្ទះតូចមួយនៅសហគមន៍ ផ្លូវរថភ្លើងដែលមានចំងាយប្រហែលពីរបីម៉ែត្រពីផ្លូវរថភ្លើងដែលមិនប្រើប្រាស់។ ផ្ទះរបស់អ្នកស្រីក៏ដូចជាផ្ទះអ្នកផ្សេងទៀត នៅក្នុងសហគមន៍ដែរ គឺមិនទទួលបាននូវទឹកស្អាត និងសេវាប្រមូលសំរាមនោះទេ។ កង្វះទឹកស្អាតគឺជាបញ្ហាដ៏សំខាន់នៅក្នុងសហគមន៍នេះ។ គ្រួសារអ្នកស្រីមិនមានលទ្ធភាពបង់សេវាកម្មតភ្ជាប់ ទឹកស្អាត អគ្គិសនីសាធារណៈទេ ហើយក៏ត្រូវបង្ខំចិត្តតភ្ជាប់សេវាទាំងនេះពីឯកជន ដែលមានតម្លៃ ២.០០០រៀល ($០,៥) សម្រាប់ទឹក ១ម៉ែត្រគូប នឹង ១៤.០០រៀល ($០,៣២) សម្រាប់អគ្គិសនី ១គីឡូវ៉ាត់ម៉ោង ដែលមានតម្លៃប្រហែលទ្វេរដងនៃតម្លៃដើម ។

ចំណូលដែលអ្នកស្រី និងប្តីរកបាន គឺមិនអាចគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ដល់កូនៗនោះទេ។ ក្នុងឆ្នាំ ២០១០ កូនរបស់អ្នកស្រីឈឺធ្ងន់ អ្នកស្រីបានយកប្រាក់កម្ចីពីអង្គការមួយចំនួន ១.២០០ដុល្លារអាមេរិក ដើម្បីចំណាយលើការព្យាបាលកូន និងអាហារសម្រាប់គ្រួសារ។ ដោយមិនមានប័ណ្ណកម្មសិទ្ធិជាផ្លូវការ គ្រួសារអ្នកស្រីមិនអាចយកប្រាក់កម្ចីពីធនាគារដែលមានអត្រាការប្រាក់សមរម្យនោះទេ ប៉ុន្តែអាចបានត្រឹមតែខ្ចីពីអ្នកចងការប្រាក់ឯកជនដែលមានអត្រាការប្រាក់ពី៣% រឺ ៣៦%ក្នុងមួយឆ្នាំ។ ដោយមានប្រាក់ចំណូលមធ្យម១០ដុល្លារអាមេរិក ប្រចាំថ្ងៃ សម្រាប់ផ្គត់ផ្គង់សមាជិកគ្រួសារចំនួន៩នាក់ ដូច្នេះ គ្រួសារគាត់ត្រូវប្រើពេលយូរ ក្នុងការសងប្រាក់កម្ចីដែលខ្ចីនៅឆ្នាំ ២០១០ នោះ។

គ្រួសារអ្នកស្រី និងអ្នករស់នៅ ៥០គ្រួសារផ្សេងទៀតនៅតាមបណ្តោយផ្លូវរថភ្លើង នឹងបន្តរស់នៅក្នុងភាពមិនប្រាកដប្រជា បន្ទាប់ពីត្រូវបានគេផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ ប្រហែលជាមិនយូរប៉ុន្មាននោះទេ ប្រជាជន ក្នុងតំបន់នេះនឹងត្រូវរើផ្ទះរបស់ពួកគាត់ចេញយ៉ាងតិច ៣៥ម៉ែត្រ ពីផ្លូវរថភ្លើង។ នេះជារឿងដែលមិនអាចទៅរួចនោះទេ សម្រាប់គ្រួសាររបស់អ្នកស្រីដែលរស់នៅលើដីមួយ ដែលមានទំហំត្រឹមតែ ៣,៥ម៉ែត្រគុណនឹង១០ម៉ែត្រ ប៉ុណ្ណោះ។ អ្នកស្រី មានក្តីសង្ឃឹមថា រដ្ឋាភិបាលនឹងផ្តល់សំណងដែលអាចទទួលយកបាននៅពេលដែលគ្រួសាររបស់អ្នកស្រីត្រូវផ្លាស់ប្តូរលំនៅឋាន និងសង្ឃឹមថានឹងមិនមានការបណ្តេញចេញដោយបង្ខំទេ។

### ៤.៨.២ ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គម

ជាទូទៅគ្រួសារភាគច្រើនបានរាយការណ៍ថា ការផ្លៀលចេញមិនមានផលប៉ះពាល់អវិជ្ជមានដល់ផ្នែកសេដ្ឋកិច្ចសង្គមរបស់គ្រួសារគាត់នោះទេ។ មានតែប្រជាជនចំនួន ១១គ្រួសារ (ឬ១៨%) ប៉ុណ្ណោះ ដែលបានបង្ហាញថាមានផលប៉ះពាល់ដល់លទ្ធភាពរកប្រាក់ចំណូលរបស់ពួកគាត់ ហើយផលប៉ះពាល់នេះមិនមានភាពខុសប្លែកគ្នារវាងបុរស និងស្ត្រីនោះទេ។ ដោយសារគ្រួសារភាគច្រើនដែលរស់នៅក្នុងសហគមន៍ក្រីក្រដែលត្រូវបានផ្លៀលចេញ ប្រកបរបរដែលរកចំណូលបានទាបលើកលែងតែផ្នែកខ្លះនៃសហគមន៍ថៅពញាហុក ដែលអាចលក់ដូរលក្ខណៈខ្នាតតូចនៅមុខផ្ទះរបស់គាត់បាន ដូច្នេះ ការដែលមានប្លង់រឹងមិនសូវជាមានផលប៉ះពាល់អវិជ្ជមានដល់ការរកប្រាក់ចំណូលរបស់ពួកគាត់នោះទេ។ ទោះជាយ៉ាងណា ក៏ដោយអ្នករស់នៅក្នុងសហគមន៍ក្រីក្រក្នុងខណ្ឌខាងក្នុងក្រុង បានរាយការណ៍ពីផលប៉ះពាល់ជាអវិជ្ជមានផ្នែកសេដ្ឋកិច្ចសង្គម ច្រើនជាងអ្នកដែលរស់នៅខណ្ឌជាយក្រុង (២៣% និង១៣,៣%)។ ការរកឃើញនេះ ស្របគ្នានឹងការរកឃើញក្នុងការសិក្សាមួយរបស់ McGinn (២០១៤) ដែលបានរកឃើញថា ស្ត្រីដែលមានជីវភាពពឹងផ្អែកលើតំបន់ដែលគាត់ធ្លាប់រស់នៅ បានទទួលរងនូវផលប៉ះពាល់យ៉ាងខ្លាំងដោយសារការផ្លាស់ប្តូរទីលំនៅដោយបង្ខំ។ អ្នករស់នៅក្នុងសហគមន៍ក្រីក្រនៅទីក្រុងនៅក្នុងខណ្ឌខាងក្នុង ដូចជា នៅប្លុកតាន់ប៉ានៅជិតផ្សារធំថ្មី គឺមានជីវភាពប្រសើរ បើប្រៀបធៀបជាមួយអ្នករស់នៅក្នុងសហគមន៍ក្រីក្រដែលនៅខណ្ឌជាយក្រុង ដោយសារតែពួកគេទទួលផលប្រយោជន៍ពីទីតាំងដែលនៅកណ្តាលទីក្រុង។

ប្រជាជនចំនួន ៦គ្រួសារ ដែលភាគច្រើនជាអ្នកដែលលក់ដូរតូចតាចបានត្អូញត្អែរថាការដែលមិនមានប័ណ្ណកម្មសិទ្ធិប៉ះពាល់ដល់ជីវភាពរបស់ពួកគាត់ ពីព្រោះពួកគាត់មិនអាចទទួលបាននូវប្រាក់កម្ចីច្រើន ដែលមានអត្រាការប្រាក់ទាបពីធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីយកមកធ្វើជំនួញ ឬជួសជុលផ្ទះបាននោះទេ។ ក្នុងករណីបន្ទាន់ ពួកគាត់មិនមានប័ណ្ណកម្មសិទ្ធិធ្វើជារបស់បញ្ចាំដើម្បីទទួលបានប្រាក់កម្ចីភ្លាមៗនោះទេ ពួកគាត់បានត្រឹមតែខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជនដែលគិតការប្រាក់ពីគាត់អាចរហូតដល់ ១២០% ក្នុងមួយឆ្នាំ។[២៥] ស្ត្រីដែលជាអ្នកចូលរួមក្នុងការសម្ភាសម្នាក់ បានលើកឡើងក្នុងពេលពិភាក្សាជាក្រុមថា៖

---

[២៥] អ្នកមានប្លង់ទន់អាចយកប្រាក់កម្ចីបានច្រើនដោយមានអត្រាការប្រាក់ទាបជាងអ្នកផ្តល់ប្រាក់កម្ចីឯកជន ប៉ុន្តែអ្នកដែលមានប្លង់រឹងអាចចរចាបានអត្រាការប្រាក់កាន់តែទាប។

...មានថ្ងៃមួយ កូនប្រុសរបស់ខ្ញុំធ្លាក់ខ្លួនឈឺខ្លាំង និងត្រូវការព្យាបាល។ យើងគ្មានលុយ។ ខ្ញុំបានទៅខ្ចីលុយពីគេក្នុងភូមិ។ គេបានសុំប្លង់កម្មសិទ្ធិជារបស់បញ្ចាំតែខ្ញុំមិនមាន។ ហេតុដូច្នេះហើយ ខ្ញុំអាចខ្ចីបានតែ១០ម៉ឺនរៀល ($២៥)។ យើងជួបបញ្ហាធំ ហើយត្រូវតែយកប្រាក់កម្ចីពីអ្នកចងការប្រាក់ និងសាច់ញាតិផ្សេងទៀត ដើម្បីបង់ថ្លៃព្យាបាលកូន។

## ៤.៨.៣ ការលំបាកក្នុងការលក់ដូរអចលនទ្រព្យ

កង្វះខាតប័ណ្ណកម្មសិទ្ធិជាផ្លូវការ ប៉ះពាល់ដល់លទ្ធភាពគ្រួសារមួយចំនួនក្នុងការលក់ដូរទ្រព្យសម្បត្តិរបស់គេក្នុងតម្លៃដ៏ល្អប្រសើរមួយ។ ដីដែលនៅក្នុងតំបន់អានាធិបតេយ្យមានតម្លៃទាបជាងឆ្ងាយ បើធៀបទៅនឹងកន្លែងដែលមានហេដ្ឋារចនាសម្ព័ន្ធល្អ និងមានសុវត្ថិភាពដីធ្លី។ អ្នកចង់ទិញដីពួកគាត់អាចមានការស្ទាក់ស្ទើរក្នុងការផ្តល់តម្លៃទីផ្សារសម្រាប់អចលនទ្រព្យគ្មានប្លង់រឹង ឬពេលខ្លះមិនចង់ទិញតែម្តង។ ដោយហេតុផលនេះ គ្រួសារមួយចំនួនមានអារម្មណ៍ថាពួកគាត់ជាប់គាំងក្នុងស្ថានភាពបច្ចុប្បន្ន។ ទោះយ៉ាងក៏ដោយ មានគ្រួសារមួយចំនួន រួមទាំងមេភូមិផងដែរ ដែលមិនជឿថានឹងមានហានិភ័យនៃការបណ្តេញចេញ ហើយការដែលមានប្លង់រឹងដូចជាមិនសូវមានការចាំបាច់សម្រាប់ពួកគាត់។ ពួកគាត់និយាយថា ការលក់ដូរអចលនទ្រព្យដែលមានប្លង់ទន់មានភាពរហ័សជាង ហើយដំណើរការផ្ទេរកម្មសិទ្ធិក៏លឿន និងថូរថ្លៃជាងអចលនទ្រព្យដែលមានប្លង់រឹងដែរ។

## ៤.៨.៤ ការរើសអើង និងការមិនរាប់អានពីសង្គម

អ្នកតបសម្ភាសន៍ខ្លះដែលរស់នៅក្នុងសហគមន៍ក្រីក្រនៅទីក្រុង បានបង្ហាញថា មុនពេលដែលមានការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ អ្នកភូមិទាំងអស់គឺមានស្ថានភាពដូចគ្នា (មិនមានប្លង់រឹង ហើយទំនាក់ទំនងរវាងប្រជាជនដែលរស់នៅក្នុងសហគមន៍មានលក្ខណៈល្អប្រសើរ)។ ប៉ុន្តែ ស្ថានភាពនេះបានផ្លាស់ប្តូរបន្ទាប់ពីសហគមន៍ក្រីក្រ ត្រូវបានគេផ្សៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ កាលពីដំបូង គ្រួសារមួយចំនួនក្នុងសហគមន៍ក្រីក្រនៅទីប្រជុំជនចាប់ផ្តើមព្រួយបារម្ភពីការបណ្តេញចេញដែលពួកគាត់មិនដែលមានពីមុនមក។ សំខាន់ជាងនេះទៅទៀត គ្រួសារចំនួន ៨ (១៣% និងភាគច្រើនជាបុរស) មានអារម្មណ៍ថា បន្ទាប់ពីត្រូវបានគេផ្សៀលចេញ អ្នកជិតខាងដែលទទួលបានប្លង់រឹងចាប់ផ្តើមមើលងាយពួកគាត់។

នៅក្នុងក្រសែភ្នែករបស់អ្នកជិតខាងដែលមានប័ណ្ណកម្មសិទ្ធិ គ្រួសារដែលត្រូវបានគេផ្លៀលចេញ ប្រែជាអ្នកគ្មានតម្លៃ «អ្នករស់នៅក្នុងតំបន់អនាធិបតេយ្យ»។ ការប្រកាន់ និងការរើសអើងបានកើតឡើង។ ស្ត្រីម្នាក់ក្នុងសហគមន៍ទឹកថ្លា២ មានការខឹងសម្បារដោយលើកឡើងថា៖

> ... ខ្ញុំមិនយល់ថាហេតុអីបានជាអ្នកជិតខាងទទួលបានប្លង់កម្មសិទ្ធិ ហើយពួកយើងមិនបាន។ កាលដើមឡើយ យើងមានទំនាក់ទំនងល្អ។ ឥឡូវនេះគេទទួលប្លង់កម្មសិទ្ធិ ហើយយើងមិនបានទទួល។ គេចាប់ផ្តើមមើលងាយយើងពីព្រោះគេមើលឃើញយើងជាអ្នករស់នៅក្នុងតំបន់អនាធិបតេយ្យលើចិញ្ចើមផ្លូវ ...។ គេនិយាយថា ដោយសារតែផ្ទះរបស់យើងហ្នឹងហើយ បានរដ្ឋាភិបាលមិនអាចពង្រីកផ្លូវ ដូច្នេះហើយបានគេស្អប់យើង។

ករណីសិក្សាទី៦ ពិពណ៌នាបន្ថែមអំពីអ្វីដែលស្ត្រីខាងលើបានរៀបរាប់ និងហេតុផលនានាដែលធ្វើឲ្យគ្រួសារដែលត្រូវគេផ្លៀលចេញមិនបានគិតថា ពួកគាត់ជាអ្នកបំពានផលប្រយោជន៍សាធារណៈ ក៏ប៉ុន្តែតាមពិតគឺពួកគាត់ជាអ្នករងគ្រោះនៃការអភិវឌ្ឍទីក្រុងជុំវិញសហគមន៍របស់គេ។

## ៤.៩ កិច្ចខិតខំប្រឹងប្រែងដើម្បីទទួលបានប្លង់រឹង

អ្នកតបសម្ភាសន៍ភាគច្រើនបាននិយាយថា គាត់មិនបានធ្វើអ្វីទាល់តែសោះ នៅពេលដែលគេដឹងថាគ្រួសាររបស់ពួកគាត់ត្រូវបានផ្លៀលចេញ ហើយក៏មិនមានផែនការតស៊ូមតិដើម្បីទទួលបានប្លង់រឹងនោះដែរ។ គ្រួសារដែលត្រូវបានសម្ភាសន៍មួយចំនួន បានទៅសាកសួរអាជ្ញាធរមូលដ្ឋានអំពីហេតុផលនៃការផ្លៀលចេញ និងពេលវេលាដែលគ្រួសាររបស់ខ្លួនទទួលបានប្លង់រឹង។ ពួកគាត់ទទួលបានចម្លើយថា រដ្ឋាភិបាលកំពុងតែគិតអំពីបញ្ហានេះ ហើយប្រហែលគេនឹងដាក់បញ្ចូលគ្រួសារពួកគាត់នៅក្នុងជំហានបន្ទាប់នៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ ប៉ុន្តែពួកគាត់ហាក់មិនជឿនូវចម្លើយនោះទេ ដោយមានអារម្មណ៍ថាចម្លើយនោះមិនពិត ហើយអាជ្ញាធរមូលដ្ឋានចេះតែនិយាយដើម្បីឲ្យពួកគាត់ស្ងប់ចិត្តតែប៉ុណ្ណោះ។ គ្រួសារដែលត្រូវបានសម្ភាសន៍មួយភាគធំបានគិតថា ការធ្វើសកម្មភាពនានារបស់ពួកគាត់គឺជារឿងឥតប្រយោជន៍ពីព្រោះរដ្ឋាភិបាលនឹងមិនយកទៅពិចារណានោះទេ។ ពួកគាត់ក៏មានអារម្មណ៍ដែរថា ការធ្វើអ្វីមួយនឹងអាចនាំឲ្យមានអំពើហិង្សាពីសំណាក់អាជ្ញាធរមូលដ្ឋាន ដូចជាករណីសហគមន៍បឹងកក់ និងបុរីកីឡា។

ការពិតដែលថាមិនទាន់មានការគម្រាមកំហែងពីការបណ្តេញចេញ និង ដោយការជឿថារដ្ឋាភិបាលនឹងផ្តល់សំណងយ៉ាងសមស្រប ប្រសិនបើមានការប្តូរទីលំនៅអាចជាមូលហេតុដែលនាំឲ្យពួកគាត់មិនមានសកម្មភាពតវ៉ាណាមួយ។ ទោះយ៉ាងណាក៏ដោយ តាមរយៈការសម្ភាសបានបង្ហាញយ៉ាងច្បាស់ថា គ្រួសារទាំងនោះនឹងធ្វើការតវ៉ាប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ប្រសិនជាវាកើតមានឡើង។

**ករណីសិក្សាទី ៦ ៖ មិនមែនជាអ្នករំលោភបំពានផលប្រយោជន៍សាធារណៈ ប៉ុន្តែជាជនរងគ្រោះនៃការអភិវឌ្ឍ**

លោក សុខ មានអាយុ ៦២ឆ្នាំ មានកូនចំនួន ៤នាក់។ កូនបីនាក់ក្នុងចំណោមកូនទាំងនោះរស់នៅជាមួយគាត់នៅក្នុងផ្ទះចាស់តូចមួយ ដែលមានទីតាំងនៅចិញ្ចើមផ្លូវនៃសហគមន៍ទឹកថ្លា២។ នៅដើមទសវត្សរ៍១៩៨០ ប្រជាជនចាប់ផ្តើមតាំងទីលំនៅនៅលើដីមួយប្លង់ដែលធ្លាប់ជាវាលកប់សពនៅក្នុងសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា។ នៅឆ្នាំ១៩៩៦ លោក សុខ បានទិញដីមួយប្លង់នៅទីនោះ។ នៅឆ្នាំ ២០១១ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធបានចាប់ផ្តើមនៅក្នុងភូមិ ហើយគាត់មិនដឹង ពីហេតុផលដែលប្រជាជន ចំនួន២៤គ្រួសារ ដែលរួមមានទាំងគ្រួសារគាត់ផងនោះ គឺត្រូវបានគេផ្លៀលចេញនោះទេ។ ការពិតគ្មានគ្រួសារណានៅក្នុងសហគមន៍ ត្រូវបានគេពន្យល់ណែនាំពីការផ្លៀលចេញនោះទេ។ គ្រួសារទាំងអស់បានត្រឹមតែសន្និដ្ឋានថា ពួកគាត់ត្រូវបានផ្លៀលចេញ ដោយសារតែផ្ទះរបស់ ពួកគាត់បានសាងសង់នៅលើចិញ្ចើមថ្នល់។

អាជ្ញាធរមូលដ្ឋានចង់ពង្រីកផ្លូវ ប៉ុន្តែមិនមានទីកន្លែងដើម្បីផ្លាស់ប្តូរផ្ទះពួកគាត់ចេញពីចិញ្ចើមផ្លូវ។ លោក សុខ បានចោទសួរពីការលើកឡើងដែរថា ផ្ទះចំនួន ២៤គ្រួសារ គឺជាឧបសគ្គក្នុងការអភិវឌ្ឍផ្លូវដោយនិយាយថា៖

> ... ពេលបច្ចុប្បន្ន វាមើលទៅហាក់ដូចជាផ្ទះទាំងនោះមានទីតាំងនៅលើផ្លូវថ្នល់។ អ្នកដែលបានដឹងពីប្រវត្តិនៃសហគមន៍នេះ ទើបដឹងថា យើងមិនបានរំលោភយកដីចំណីថ្នល់ទេ។ តាមពិតផ្លូវទេដែលរំលោភលើដីយើង។ កាលពីដំបូងផ្លូវនៅមុខផ្ទះយើង គឺជាផ្លូវសម្រាប់ដើរតូចមួយ។ ពេលដែលចរាចរណ៍កើនឡើងនៅតាមផ្លូវដើរនេះ យើងបានពង្រីកផ្លូវ ហើយយើងបានអស់ដីមួយផ្នែកតូចរបស់យើងរួចហើយ។ ពីមួយឆ្នាំទៅមួយឆ្នាំ ដោយមានការអភិវឌ្ឍហាងទំនិញ និងផ្ទះនៅជិតខាង ផ្លូវកាន់តែបានពង្រីកធំ (ឥឡូវនេះមានផ្លូវទំហំ៤ម៉ែត្រ) ហើយសព្វថ្ងៃគេគិតថា យើងជាអ្នករស់នៅអនាធិបតេយ្យនៅតាមដងផ្លូវ ...។ ចុងបញ្ចប់យើងក្លាយជាជន រងគ្រោះនៃការអភិវឌ្ឍទៅវិញ។

## ៤.១០ ការរំពឹងទុក និងដំណោះស្រាយ

គ្រួសារភាគច្រើនមានក្តីរំពឹងតិចតួច ដែលថាថ្ងៃណាមួយគាត់នឹងទទួលបានប័ណ្ណកម្មសិទ្ធ ពីព្រោះគាត់គេជឿជាក់ថាគាត់បានសង់លំនៅឋានលើដីសាធារណៈ ឬពីព្រោះពួកគាត់គិតថាគាត់កំពុងតែរស់តំបន់អនាធិបតេយ្យ ដែលរដ្ឋមិនអាចផ្តល់ប័ណ្ណកម្មសិទ្ធិឲ្យបាន។ គ្រួសារក្នុងសហគមន៍ក្រីក្រនៅទីក្រុងមួយចំនួន ជាពិសេសអ្នកដែលរស់នៅសហគមន៍ប្លុកតាន់ប៉ាដែលមានប្លង់ទន់រំពឹងថា ថ្ងៃណាមួយគាត់នឹងអាចទទួលបានប្លង់រឹង។ ទោះក្នុងករណីណាក៏ដោយ ពួកគាត់និយាយថាគ្រួសារគាត់នឹងបន្តរស់នៅកន្លែងសព្វថ្ងៃដល់ពេលណា ដែលគាត់អាចលក់ដូរផ្ទះបានក្នុងតម្លៃសមរម្យមួយ ទទួលប័ណ្ណកម្មសិទ្ធិ ឬរដ្ឋាភិបាលផ្តល់ជូននូវសំណងដែលអាចទទួលយកបានសម្រាប់ការផ្លាស់ប្តូរទីលំនៅរបស់គាត់។

ប្រហែលជាពាក់កណ្តាល នៃគ្រួសារដែលរស់នៅក្នុងសហគមន៍ក្រីក្រនៅទីក្រុងចង់ទទួលបានប័ណ្ណកម្មសិទ្ធិដើម្បីមានលទ្ធភាពធ្វើការសម្រេចចិត្តក្នុងការចាត់ចែងផ្ទះរបស់ខ្លួនក្នុងថ្ងៃអនាគត។ គ្រួសារពាក់កណ្តាលផ្សេងទៀត សង្ឃឹមថាគាត់នឹងទទួលបានសំណងសមរម្យ ប្រសិនបើគាត់ត្រូវប្តូរទីលំនៅ។ គ្រួសារភាគច្រើនចង់បានសំណងជាទឹកប្រាក់ និងមួយចំនួនចង់បានសំណងជាកញ្ចប់ដែលរួមមានដីមួយប្លង់/ផ្ទះមួយ និងថវិកាមួយចំនួន។ គាត់ចង់បានទីលំនៅថ្មីដែលមានទឹកស្អាត អគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងមានទីតាំងជិតទីក្រុងដែលជាទីកន្លែងដែលគ្រួសារភាគច្រើនអាចរកចំណូលបាន។

មន្ត្រីមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង និង អង្គការមិនមែនរដ្ឋាភិបាល បានលើកឡើងថា រដ្ឋាភិបាលបច្ចុប្បន្នផ្តល់អាទិភាពលើការអភិវឌ្ឍនៅនឹងកន្លែង និងព្យាយាមជៀសវាងការបណ្តេញចេញដោយបង្ខំ។ យោងតាមមន្ត្រីមន្ទីរដែនរៀបចំដែនដី នគរូបនីយកម្ម និងសំណង អភិបាលក្រុងភ្នំពេញ កំពុងពិចារណាផ្តល់ប័ណ្ណកម្មសិទ្ធិជូនដល់គ្រួសារក្នុងសហគមន៍ក្រីក្រនៅទីក្រុង ដែលគេបានផ្លៀសចេញ ក្នុងករណីសហគមន៍ទាំងនោះបានរៀបចំចងក្រងបានល្អ និងមានហេដ្ឋារចនាសម្ព័ន្ធល្អគ្រប់គ្រាន់។ ឧទាហរណ៍ សហគមន៍ទួលស្លែងឥឡូវនេះត្រូវបានដាក់បញ្ចូលក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ បន្ទាប់ពីត្រូវបានគេផ្លៀសចេញជាច្រើនឆ្នាំមកហើយ។ មន្ត្រីមន្ទីរដដែលនោះបានបន្ថែមទៀតថា សហគមន៍ក្រីក្រនៅទីក្រុងដែលមានការរៀបចំបានល្អ ហើយការរស់នៅរបស់សហគមន៍នោះមិនមានផលប៉ះពាល់ដល់ប្រយោជន៍សាធារណៈ អាចស្នើសុំដាក់

បញ្ចូលសហគមន៍របស់ខ្លួន ទៅក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ តាមរយៈអាជ្ញាធរមូលដ្ឋានរបស់ខ្លួនទៅកាន់សាលាក្រុងភ្នំពេញ។ វាអាចនឹងត្រូវប្រើពេលយូរមុនពេលដែលរដ្ឋាភិបាលអនុម័តនូវសំណើនោះ ពីព្រោះរដ្ឋាភិបាលត្រូវការពេលវេលាសិក្សាសមរម្យមួយលើសំណើនោះ និងត្រូវពិគ្រោះយោបល់ជាមួយនឹងភ្នាក់ងារពាក់ព័ន្ធនានា។

មន្ត្រីមួយរូបមកពីអង្គការ GIZ បានលើកឡើងថាអង្គការរបស់គាត់បានធ្វើការជាមួយនឹងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីសាកល្បងចងក្រង និងរៀបចំសហគមន៍ក្រីក្រនៅទីក្រុងឲ្យបានល្អដើម្បីឲ្យសហគមន៍ទាំងនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងដាក់បញ្ចូលទៅក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅពេលក្រោយ។ សមាគមធាងត្នោត កំពុងតែធ្វើការលើកម្មវិធីប្រហាក់ប្រហែលគ្នានេះ។ ដូច្នេះ ហើយសហគមន៍ក្រីក្រនៅទីក្រុងមួយចំនួនដែលស្ថិតនៅក្នុងការសិក្សានេះអាចនឹងទទួលបានប្លង់កម្មសិទ្ធិនៅថ្ងៃអនាគត។



# IV. ការពិភាក្សា និងសេចក្តីសន្និដ្ឋាន និងអនុសាសន៍



# V. ការពិភាក្សា និងសេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.១ ការពិភាក្សា និងសេចក្តីសន្និដ្ឋាន

កម្មវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ បានចាប់ផ្តើមនៅក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ២០០៣ ក្រោមកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់សុវត្ថិភាពដីធ្លី ជាពិសេស សម្រាប់គ្រួសារក្រីក្រ។ ស្របពេលដែលកម្មវិធីនេះ ទទួលបាននូវភាពជោគជ័យ ជាពិសេសនៅតាមតំបន់ជនបទ សហគមន៍ក្រីក្រជាច្រើននៅរាជធានីភ្នំពេញ ត្រូវបានគេផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ បើទោះបីជាពួកគាត់មានភស្តុតាងបញ្ជាក់ពីសិទ្ធិកាន់កាប់ក៏ដោយ ហើយមូលហេតុនៃការផ្លៀលចេញនេះក៏មិនទទួលបាននូវការពន្យល់ជាផ្លូវការដែរ។ ភាពជោគជ័យនៃកម្មវិធីនេះ ត្រូវបានគេវាស់វែងជាចម្បងទៅលើចំនួនប័ណ្ណកម្មសិទ្ធិ ដែលបានចេញឲ្យប្រជាជន ក៏ប៉ុន្តែមានការសិក្សាតិចតួចអំពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គម នៃការផ្តល់ប័ណ្ណកម្មសិទ្ធិ។ ការសិក្សានេះគឺជាការសិក្សាជាលើកដំបូងក្នុងការពិនិត្យមើលផលប៉ះពាល់នៃការផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ លើគ្រួសារក្រីក្រដែលរស់នៅក្នុងតំបន់ទីក្រុង។ ការសិក្សានេះផ្តោតលើសហគមន៍ក្រីក្រចំនួន ១២ ក្នុងរាជធានីភ្នំពេញដែលត្រូវបានគេផ្លៀលចេញ។

ដូចជាការសិក្សាមុនៗអំពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធផងដែរ ការសិក្សានេះបានរកឃើញថា មានកង្វះខាតជាខ្លាំងទៅលើទិន្នន័យពាក់ព័ន្ធនឹងដំណើរការ កំណត់តំបន់វិនិច្ឆ័យសម្រាប់ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ មន្ត្រីពាក់ព័ន្ធនានា ជារឿយៗមានភាពរារែកក្នុងការនិយាយអំពីករណីជាក់លាក់ណាមួយ។ សហគមន៍ក្រីក្រចំនួន ១០ ក្នុងចំណោម ១២ បានឲ្យដឹងថាសហគមន៍របស់ពួកគាត់ត្រូវបានគេផ្លៀលចេញ ប៉ុន្តែមានតែពាក់កណ្តាលនៃពួកគាត់ប៉ុណ្ណោះដែលត្រូវបានគេប្រាប់ជាផ្លូវការពីមូលហេតុនៃការផ្លៀលចេញនោះ។ ចំពោះសហគមន៍ក្រីក្រចំនួន ១១ មូលហេតុដែលសហគមន៍ទាំងនោះត្រូវបានផ្លៀលចេញ ទំនងជាដោយសារតែសហគមន៍ទាំងនោះស្ថិតនៅលើដីសាធារណៈរបស់រដ្ឋ។ សហគមន៍ក្រីក្រទាំងអស់ក៏មិនត្រូវបានគេប្រាប់ឲ្យដឹងពីដំណោះស្រាយនាពេលអនាគតដែរ ដែលនេះជាហេតុធ្វើឲ្យប្រជាជនរស់នៅក្នុងភាពមិនប្រាកដប្រជាក្នុងចិត្ត។ សូម្បីតែប្រធានភូមិក៏មើលទៅទំនងជាបានដឹងព័ត៌មានតិចតួចដែរ។ កង្វះខាតព័ត៌មាននាំមកនូវការយល់ខុស និងការមិនទុកចិត្តចំពោះអាជ្ញាធរមូលដ្ឋាន។

ភាពមិនច្បាស់លាស់ មិនត្រឹមតែទៅលើហេតុផលនៃការផ្លៀលចេញនោះទេ តែថែមទាំងទៅលើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធផងដែរ។ ឧទាហរណ៍ ប្រជាជនមានការយល់ខុសអំពីសិទ្ធិកាន់កាប់អចលនទ្រព្យរបស់ខ្លួន និងឯកសារដែលអាចយកមកបញ្ជាក់ពីភាពជាកម្មសិទ្ធិលើអចលនទ្រព្យរបស់ខ្លួន។ គ្រួសារក្នុងសហគមន៍ក្រីក្រមួយចំនួនបានគិតថា សហគមន៍របស់ពួកគាត់ត្រូវបានផ្លៀលចេញដោយសារតែសហគមន៍នោះត្រូវបានគេចាត់ទុកថាជាសំណង់អនាធិបតេយ្យ ប៉ុន្តែដោយសារតែមិនមានព័ត៌មានគ្រប់គ្រាន់ ពួកគាត់បានត្រឹមតែមានមន្ទិលសង្ស័យ។ វាពិតជាមានតម្រូវការ ក្នុងការផ្តល់ព័ត៌មានជាសាធារណៈអំពីដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ អំពីអ្វីទៅដែលអាចយកមកធ្វើជាភស្តុតាងបញ្ជាក់ពីភាពជាម្ចាស់កម្មសិទ្ធិ និងអំពីវិធានការនានាដែលសហគមន៍ក្រីក្រអាចធ្វើទៅបានដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិ (ដូចជាចងក្រងជាសហគមន៍ឲ្យបានត្រឹមត្រូវ ឬការកែលម្អផ្ទះឲ្យបានប្រសើរជាងមុន)។

ទោះបីជាសហគមន៍ក្រីក្រនៅទីក្រុងក្នុងការសិក្សានេះ ទំនងដូចជាមិនមានហានិភ័យក្នុងការបណ្តេញចេញ តែពាក់កណ្តាលនៃគ្រួសារដែលត្រូវបានសម្ភាសន៍ដែលភាគច្រើនជាស្ត្រី បានសម្តែងនូវអារម្មណ៍ភ័យព្រួយ និងពិបាកចិត្តអំពីស្ថានភាពរបស់គ្រួសារពួកគាត់។ អ្នកដែលទើបតែតាំងទីលំនៅថ្មីក្នុងសហគមន៍ទាំងនោះជាពិសេសអ្នកមកតាំងទីលំនៅក្រោយឆ្នាំ ២០០១ មានការបារម្ភច្រើនជាងអ្នកដែលបានតាំងទីលំនៅក្នុងសហគមន៍នោះយូរមកហើយ។ ជាការគួរឲ្យភ្ញាក់ផ្អើលជាងនេះទៅទៀតនោះ គ្រួសារដែលមានប្លង់ទន់មានការព្រួយបារម្ភច្រើនជាងអ្នកដែលមិនមានបណ្ណ័កម្មសិទ្ធិអ្វីទាំងអស់។ ស្ថានភាពរបស់អ្នកទើបមកតាំងទីលំនៅថ្មីគឺ មានភាពផុយស្រួយ ដោយសារតែពួកគាត់មកតាំងទីលំនៅក្រោយច្បាប់ភូមិបាលឆ្នាំ ២០០១ និងមិនអាចទាមទារភាពជាម្ចាស់កម្មសិទ្ធិបាន។ សម្រាប់អ្នកដែលមានប្លង់ទន់ អាចនឹងមានសេចក្តីព្រួយបារម្ភ ដោយសារតែពួកគាត់អាចមានមន្ទិលសង្ស័យពីភាពស្របច្បាប់នៃប្លង់ទន់ដែលគាត់មាន។ ពួកគាត់អាចបានចំណាយថវិកាច្រើនទៅលើអចលនទ្រព្យរបស់ខ្លួន ព្រោះគាត់ទុកចិត្តថាវាមានសុវត្ថិភាពផ្នែកកម្មសិទ្ធិ ដោយសារហេតុផលនេះហើយទើបអាចបណ្តាលអោយពួកគាត់មានការព្រួយបារម្ភកាន់តែខ្លាំង ក្នុងករណីដែលពួកគាត់មិនបានទទួលនូវប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ។

ផលវិបាកដទៃទៀតនៃការផ្លៀលចេញ ដែលបានរកឃើញតាមរយៈការសម្ភាសគ្រួសារនានាមានដូចជា៖ ការមិនទទួលបាននូវប្រាក់ឥណទានដែលមានការប្រាក់ទាបពីធនាគារដើម្បីយកទៅប្រើប្រាស់ក្នុងមុខជំនួញ និងការមិនមានលទ្ធភាពលក់អចលនទ្រព្យរបស់ខ្លួនក្នុងតម្លៃខ្ពស់។ អ្នកខ្លះមានអារម្មណ៍ថាដូចជាជាប់គាំងនៅក្នុងសហគមន៍មួយដែលការរស់នៅមានភាពមិនច្បាស់លាស់។ ការមិនមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ និងការមិនមានសុវត្ថិភាពក្នុងការតាំងទីលំនៅបានធ្វើឲ្យពួកគាត់មានអារម្មណ៍ថាបានបាត់បង់នូវសិទ្ធិអំណាច។ អ្នកចូលរួមខ្លះទៀតក៏បានរាយការណ៍ថា ពួកគេត្រូវបានរើសអើង និងមិនអើពើពីអ្នកជិតខាង។

ការផ្លៀលចេញនូវសហគមន៍មួយចំនួននៅក្នុងភូមិណាមួយ អាចនឹងនាំមកនូវជម្លោះរវាងអ្នកជិតខាងដែលធ្លាប់តែល្អនឹងគ្នា និងអាចមានផលអាក្រក់ដល់ទំនាក់ទំនងសង្គមរវាងអ្នកជិតខាង។ នៅពេលដែលអ្នកតបសម្ភាសន៍ជាស្ត្រីបានរាយការណ៍ពីការព្រួយបារម្ភអំពីស្ថានភាពរបស់គ្រួសារពួកគេគាត់ អ្នកតបសម្ភាសន៍ជាបុរសភាគច្រើន ហាក់បានរាយការណ៍ពីការដែលត្រូវបានរើសអើងពីសំណាក់អ្នកជិតខាង។

ជាសរុប សហគមន៍ក្រីក្រដែលត្រូវបានគេផ្លៀលចេញ ជាទូទៅគឺត្រូវបានគេធ្វើឲ្យមានការខូចប្រយោជន៍ផ្នែកសេដ្ឋកិច្ចសង្គម។ ការទទួលបានសេវាសាធារណៈ និងសេវានានានៅមានកម្រិត។ ប្រជាជននៅទីនោះក៏ប្រឈមមុខទៅនឹងបញ្ហាអនាម័យដែលបណ្តាលមកពីកង្វះអនាម័យ និងសេវាប្រមូលសំរាម។ ភាគច្រើននៃអ្នករស់នៅក្នុងសហគមន៍ក្រីក្រមានប្រាក់ចំណូលទាប ដែលស្ទើរតែមិនគ្រប់សម្រាប់ផ្គត់ផ្គង់គ្រួសាររបស់ពួកគាត់ផង ដូច្នេះ ពួកគាត់មិនអាចមានលទ្ធភាពកែលម្អគេហដ្ឋាន ឬសហគមន៍របស់ពួកគាត់អោយបានរៀបរយឡើយ។ ការផ្លៀលចេញបានធ្វើឲ្យស្ថានភាពរស់នៅ ដែលកំពុងតែមានសភាពលំបាកស្រាប់របស់សហគមន៍កាន់តែលំបាកថែមទៀត ដោយហេតុថាវាបានបង្កើតនូវភាពមិនប្រាកដប្រជាថែមទៀតសម្រាប់អនាគតរបស់ពួកគាត់។ បើទោះបីជាគ្រួសារដែលត្រូវបានសម្ភាសន៍មិនបានរាយការណ៍ពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន ដោយសារតែការផ្លៀលចេញក៏ដោយ ក៏ក្នុងករណីមួយចំនួន វាមើលទៅទំនងជាថាមានវិធានការណ៍មួយចំនួនអាចនឹងត្រូវបានធ្វើឡើង ដើម្បីធ្វើឲ្យស្ថានភាពរបស់ពួកគាត់មានភាពប្រសើរឡើង។ ឧទាហរណ៍ មានគ្រួសារមួយចំនួនត្រូវបានផ្លៀលចេញដោយសារតែពួកគាត់រស់នៅតាមផ្លូវរថភ្លើងដែលមិនប្រើប្រាស់។ ប្រសិនបើរដ្ឋាភិបាលមិន

ទាន់មានផែនការក្នុងការកែលម្អផ្លូវរថភ្លើងនោះទេ ដីដែលលែងមានតម្លៃសម្រាប់ប្រយោជន៍សាធារណៈនោះ អាចនឹងត្រូវបានគេដាក់ជាដីឯកជនរបស់រដ្ឋ ហើយគ្រួសារទាំងនោះអាចទទួលបានប័ណ្ណកម្មសិទ្ធិ ក្នុងករណីដែលពួកគាត់មានភស្តុតាងបញ្ជាក់ពីការតាំងទីលំនៅស្របច្បាប់របស់ខ្លួន។

## ៥.២ អនុសាសន៍

### ការយល់អំពីបញ្ហា

១) ធ្វើផែនទី និងផ្សព្វផ្សាយពីលទ្ធផលនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅក្នុងរាជធានីភ្នំពេញ ដោយរួមបញ្ចូលៈ ១) តំបន់ណាខ្លះដែលបានធ្វើការវិនិច្ឆ័យ ប្រភេទ និងចំនួនប័ណ្ណកម្មសិទ្ធិដែលបានចេញរួចរាល់ក្នុងស្រុក ឃុំ និងភូមិនីមួយៗក្នុងតំបន់ដែលបានធ្វើការវិនិច្ឆ័យរួចរាល់នេះ។ ២) នៅតំបន់ដែលបានធ្វើការវិនិច្ឆ័យរួចនីមួយៗ ផ្តល់ព័ត៌មានពីកន្លែងដែលបានផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងមូលហេតុផ្លូវច្បាប់នៃការផ្លៀលចេញ (មាត្រានានានៃច្បាប់ និងអនុក្រឹត្យ)។ ៣) តំបន់ណាខ្លះដែលមិនទាន់បានជ្រើសរើសសម្រាប់ការវិនិច្ឆ័យ ហើយពេលណាដែលតំបន់នោះអាចនឹងត្រូវបានជ្រើសរើស។ ៤) តំបន់ណាដែលនឹងត្រូវបានគេជ្រើសរើសដើម្បីវិនិច្ឆ័យ និងហេតុផលផ្លូវច្បាប់នានាដែលពាក់ព័ន្ធ (មាត្រា នានានៃច្បាប់ និងអនុក្រឹត្យ)។

២) ធ្វើផែនទី និងផ្សព្វផ្សាយពីស្ថានភាពនៃដីទាំងអស់ក្នុងទីក្រុងភ្នំពេញដែលជាដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ ឬដីឯកជន ព្រមទាំងដីសម្បទានសេដ្ឋកិច្ច និងដីសម្បទានសង្គមកិច្ច ក៏ដូចជាទាំងប្លង់មេសម្រាប់អភិវឌ្ឍន៍រាជធានីភ្នំពេញ។

### ភាពច្បាស់លាស់ និងតម្លាភាព (ក្រសួង និងសាលារាជធានីភ្នំពេញ)

៣) កំណត់ឲ្យបានច្បាស់លាស់ និងផ្សព្វផ្សាយនូវប្រភេទឯកសារនានា ព្រមទាំងអាជ្ញាយុកាលនៃការចេញឯកសារស្របច្បាប់ដែលបញ្ជាក់ពីសិទ្ធិនៃការកាន់កាប់។
៤) ផ្តល់ព័ត៌មានគ្រប់គ្រាន់ និងធ្វើអោយមានការចូលរួមពេញលេញពីសំណាក់មេភូមិក្នុងដំណើរការផ្តល់បណ្ណកម្មសិទ្ធិ និងការផ្លៀលចេញនូវតំបន់ណាមួយក្នុងភូមិរបស់គាត់ ហើយត្រូវមានការជូនដំណឹងជាផ្លូវការឲ្យច្បាស់លាស់ដល់ម្ចាស់អចលនទ្រព្យ

ដើម្បីកុំឲ្យមានពាក្យចរចាមអារាមមិនល្អ និងការរំពឹងខុស ក៏ដូចជាដើម្បីជំរុញឲ្យមានដំណោះស្រាយដែលអាចទទួលយកបាន។

## ការដោះស្រាយជាមួយនឹងតំបន់ដែលផ្លៀលចេញ

៥) នៅគ្រប់តំបន់ដែលមិនទាន់ត្រូវបានជ្រើសរើសសម្រាប់ធ្វើការវិនិច្ឆ័យ ឬដែលបានផ្លៀលចេញក្នុងពេលវិនិច្ឆ័យគួរតែមានកិច្ចប្រជុំដែលមានការចូលរួមពីអាជ្ញាធរដែនដីដែលមានសិទ្ធិសម្រេច និងប្រជាជនដែលនៅក្នុងតំបន់ផ្លៀលចេញ ឬអ្នកតំណាងរបស់ពួកគេ (ឧទាហរណ៍ អង្គការមិនមែនរដ្ឋាភិបាល ទីប្រឹក្សាផ្នែកច្បាប់)។ នៅក្នុងកិច្ចប្រជុំនេះ មាត្រានានាដែលពាក់ព័ន្ធនៅក្នុងច្បាប់ភូមិបាលគួរតែត្រូវបានគេពន្យល់ ហើយផែនការសកម្មភាពនានា ត្រូវលើកយកមកពិភាក្សាសម្រេចនៅក្នុងអង្គប្រជុំ (ឧទាហរណ៍ ការអភិវឌ្ឍនៅនឹងកន្លែង ការជម្លៀសចេញពីទីតាំងដោយមានសំណងសមស្រប) ដើម្បីជាការការពារសិទ្ធិរបស់ប្រជាជនក្នុងការមានលំនៅឋានមានហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងសេវាសាធារណៈនានា ព្រមទាំងមានឱកាសសម្រាប់ជីវភាពរស់នៅ។

៦) នៅគ្រប់តំបន់ទាំងអស់ដែលត្រូវបានគេផ្លៀលចេញ ដែលប្រជាជននៅទីនោះមានភស្តុតាងបញ្ជាក់ពីកម្មសិទ្ធិស្របច្បាប់ ដូចដែលបានកំណត់នៅក្នុងច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ២៩ មាត្រា ៣០ និងមាត្រា ៣១ ដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គួរតែអនុវត្តសាជាថ្មី។

៧) គ្រួសារដែលត្រូវបានគេផ្លៀលចេញ ពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធដោយសារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (ឧទាហរណ៍ ការពង្រីកផ្លូវ) បន្ទាប់ពីពួកគាត់បានចូលមកកាន់កាប់ដីនៅក្នុងសហគមន៍នោះ គួរតែត្រូវបានគេចាត់ទុកថាជាអ្នកដែលត្រូវបានបំពានដោយភាគីរដ្ឋ ឬការអភិវឌ្ឍទីក្រុងដោយភាគីឯកជន ហើយពួកគាត់មិនមែនជាអ្នករស់នៅអនាធិបតេយ្យ បំពានលើដីរដ្ឋសម្រាប់ការអភិវឌ្ឍនោះទេ។ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ គួរតែត្រូវបានគេធ្វើឡើងសារជាថ្មីដូចដែលបានលើកឡើងក្នុងអនុសាសន៍ទី ៦ ហើយជំហាននានាគួរតែអនុវត្តដូចមានក្នុងអនុសាសន៍ទី ៨ ដើម្បីស្វែងរកដំណោះស្រាយនានាដែលគ្រួសារទាំងនោះអាចទទួលយកបាន (ឧទាហរណ៍ ដូចនៅសហគមន៍ ៣៤៧ គេគួរតែពង្រីក

ផ្លូវទៅចំណែកផ្លូវដែលនៅទំនេរម្ខាងទៀត ហើយមិនគួរពង្រីកផ្លូវនៅចំណែកផ្លូវដែលមានផ្ទះប្រជាជនកំពុងតែរស់នៅនោះទេ។ ចំពោះសហគមន៍ដែលមិនអាចអភិវឌ្ឍន៍បាននៅនឹងកន្លែង ពួកគេគួរតែទទួលបានសំណងសមស្រប និង ឬ ផ្លាស់ទីតាំងទៅទីកន្លែងដែលនៅក្បែរៗទីតាំងចាស់)។

៨) ចំពោះសហគមន៍ដែលត្រូវគេផ្លៀសចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដោយសារតែត្រូវបានគេចាត់ទុកថាស្ថិតនៅលើដីរដ្ឋ ក៏ប៉ុន្តែដីនោះលែងផ្តល់ជាប្រយោជន៍សាធារណៈ (ឧទាហរណ៍ ម៉ុំផ្លូវរថភ្លើងដែលមិនប្រើប្រាស់ និងម៉ុំអតីតផ្សារ និងចំណតឡានតាស៊ីក្នុងសហគមន៍ព្រៃកតាន្ធ) បើតាមមាត្រា ១៦ នៃច្បាប់ភូមិបាល ដីនោះគួរត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញជាដីឯកជនរបស់រដ្ឋ ហើយការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធគួរតែត្រូវបានគេដំណើរការសារជាថ្មី។

## ដំណោះស្រាយជាមួយនឹងសហគមន៍ក្រីក្រ

៩) កំណត់ឲ្យបានច្បាស់លាស់នូវអត្ថន័យនៃសហគមន៍ក្រីក្រនៅទីក្រុង និងធ្វើជំរឿននៅទីតាំងនៃសហគមន៍ក្រីក្រនៅទីក្រុងក្នុងរាជធានីភ្នំពេញ ដោយមានកំណត់ទីកន្លែង និងស្ថានភាពដីផងដែរ( ឧទាហរណ៍ កំណត់អោយបានច្បាស់ថាសហគមន៍ក្រីក្រនៅទីប្រជុំជនមួយណាដែលមានទីតាំងលើដីសាធារណៈ ហើយស្ថិតនៅក្នុងការអនុវត្តសារាចរលេខ ០៣)។ ដោយប្រើប្រាស់កម្រងសំណួរដែលជាឧបសម្ព័ន្ធនៅក្នុងសារាចរលេខ ០៣ ដើម្បីកំណត់ឲ្យបានជាក់ច្បាស់ ហើយផ្សព្វផ្សាយនូវលក្ខណៈប្រជាសាស្ត្រ លក្ខខណ្ឌបច្ចុប្បន្ន និងតម្រូវការនានាសម្រាប់សហគមន៍ក្រីក្រនៅទីប្រជុំជនទាំងអស់ទាក់ទងនឹងសេវានានា និងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងបញ្ចូលបញ្ហាសហគមន៍ទាំងនោះទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

១០)កំណត់អាទិភាពការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍ក្រីក្រនៅទីប្រជុំជនដែលមិនទាន់ទទួលបានសេវាសាធារណៈ ដូចជាអគ្គិសនី ទឹកស្អាត ប្រព័ន្ធលូបង្ហូរ និងការប្រមូលសំរាម។ ស្វែងយល់ពីប្រាក់ចំណូលរបស់គ្រួសារក្នុង សហគមន៍ក្រីក្រ និងជួយសម្រួល ឬជួយឧបត្ថម្ភទុនឲ្យពួកគាត់អាចតភ្ជាប់បណ្តាញ ទឹកស្អាត អគ្គិសនី និងថ្លៃសេវាប្រើប្រាស់។ ធានាអោយបានថាការអភិវឌ្ឍសេវាកម្មនានា រួមបញ្ចូលនូវ

ការទទួលបានសេវាអប់រំ និងសុខភាព ព្រមទាំងការគាំទ្រគ្រួសារ ដែលមានកូនគ្រប់អាយុចូលរៀនដើម្បីកុំឲ្យក្មេងបោះបង់ចោលការសិក្សាដោយសារតែកត្តាភាពក្រីក្រ។

១១) ដោយមានជំនួយពីអង្គការមិនមែនរដ្ឋាភិបាល សហគមន៍ក្រីក្រនៅទីក្រុងគួរតែត្រូវបានលើកទឹកចិត្តឲ្យមានការចងក្រងសហគមន៍បានប្រសើរជាងមុន ឧទាហរណ៍ដូចជាការរៀបចំឲ្យមានក្រុមសន្សំប្រាក់ ការរៀបចំផែនការអភិវឌ្ឍន៍សហគមន៍ ការរៀបចំដើម្បីឲ្យពួកគាត់ទទួលបានប័ណ្ណកម្មសិទ្ធិស្របច្បាប់ និងការតស៊ូមតិជាមួយនឹងរដ្ឋាភិបាល និងសង្គមស៊ីវិលដើម្បីទទួលបាននូវតម្រូវការជាមូលដ្ឋាន និងសិទ្ធិនានា។

១២) សហគមន៍ក្រីក្រនៅទីក្រុងដែលត្រូវបានផ្លៀសចេញ គួរតែធ្វើសំណើមួយទៅអភិបាលរាជធានីភ្នំពេញដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិស្របច្បាប់។ អង្គការមិនមែនរដ្ឋាភិបាលដូចជា អង្គការ GIZ អាចមានលទ្ធភាពជួយសហគមន៍ទាំងនោះក្នុងការធ្វើសំណើ។

១៣) ប្រសិនបើការផ្លាស់ប្តូរទីតាំងសហគមន៍ក្រីក្រ ជារឿងដែលមិនអាចជៀសបាន គេគួរមានផែនការផ្លាស់ប្តូរទីតាំងឲ្យបានម៉ត់ចត់ ដោយការធ្វើផែនការនោះគួរមានការពិគ្រោះយោបល់ជាមួយគ្រួសារក្នុងសហគមន៍ក្រីក្រ និងអ្នកតំណាងរបស់ពួកគេ (អង្គការមិនមែនរដ្ឋាភិបាល ឬទីប្រឹក្សាផ្នែកច្បាប់) ព្រមទាំងផ្តល់សំណងគ្រប់គ្រាន់។ ផែនការ និងបរិមាណសំណងគួររៀបចំឲ្យបានរួចរាល់ និងមានការឯកភាពគ្នាជាមុន មុននឹងមានការផ្លាស់ប្តូរទីតាំងសហគមន៍ក្រីក្រនៅទីក្រុងចេញពីទីលំនៅបច្ចុប្បន្ន។

១៤) ដើម្បីការពារការរីករាលដាលនៃសហគមន៍ក្រីក្រនៅទីក្រុង បង្ការជម្លោះរវាងប្រជាជន និងអាជ្ញាធរ ព្រមទាំងដោះស្រាយបញ្ហាការបណ្តេញចេញ និងការតាំងទីលំនៅថ្មី អ្នកមកតាំងទីលំនៅខុសច្បាប់លើដីសាធារណៈរបស់រដ្ឋគួរតែមានការតាមដាន និងចាត់វិធានការណ៍ទាន់ពេលដោយមានការចូលរួមពីសំណាក់អ្នកមករស់នៅថ្មីនោះ និងអ្នកតំណាងរបស់ពួកគាត់។

# ឯកសារយោង

Amnesty International (2008). *Rights razed: Forced evictions in Cambodia*. Phnom Penh: Amnesty International.

Anttonen, J. (2012). “Multi-donor efforts for improving land administration systems in developing countries: Lessons learnt from the Cambodian Land Management and Administration Project (LMAP).” Paper presented at the *FIG Working Week*, 6-10 May, Rome, Italy.

Biddulph, R. (2014). *Cambodia’s Land Management and Administration Project* (WIDER Working Paper 2014/086). Helsinki: World Institute for Development Economics Research.

Bridges Across Borders-Cambodia (2014). Land Management and Administration Project: World Bank Inspection Panel complaint. Retrieved 24 June 2014, from http://babcambodia.org/developmentwatch/lmap/

Bugalski, N. & Pred, D. (2009). “Formalizing inequality: Land titling in Cambodia.” In Bridges Across Borders (BAB) (Ed.), *A Year in Review 2009*. Phnom Penh: BAB Cambodia.

Cambodian Center for Human Rights (CCHR) (2013). *Cambodia: Land in conflict - An overview of the land situation.* Phnom Penh: CCHR.

Channyda, C. & Seiff, A. (2013). “Phnom Penh’s slums swell in 2012.” *Phnom Penh Post*, 19 February. Retrieved 15 November 2014 from http://www.phnompenhpost.com/national/phnom-penh’s-slums-swell-2012

FIAN Germany (2011). Additional Information Presented by FIAN Germany to the Committee on Economic, Social and Cultural Rights, 46th Session, 2 May. FIAN Germany.

Grimsditch, M. & Henderson, N. (2009). *Untitled: Tenure insecurity and inequality in the Cambodian land sector*. Phnom Penh: Bridges Across Borders Cambodia.

Hap, P. (2007). *The implementation of Cambodia's laws on land tenure: Squatters on private land.* (LLM), Nagoya: Nagoya University.

Housing Rights Task Force (HRTF) (2011). *Socio-economic impact of forced eviction at the household level in Phnom Penh*. Phnom Penh: HRTF.

Land Administration Sub-Sector Program (LASSP) (2011). *Land is Life*. Phnom Penh: LASSP.

LICADHO (2009). *Land grabbing and poverty in Cambodia: The myth of development*. Phnom Penh: LICADHO.

Lindström, N. (2013). *Policy for the poor? Phnom Penh, tenure Security, and Circular 03*. Phnom Penh: The Urban Initiative.

McGinn, C. (2014). “Economic trajectories following forced evictions in Phnom Penh, Cambodia: An analysis of displaced women’s narratives.” *Journal of Internal Displacement*, *4*(1), 53-77.

National Committee for Population and Development (NCPD) (2007). *Urbanization profile of Cambodia*. Phnom Penh: Secretariat for NCPD, Council of Ministers.

National Institute of Statistics (NIS) (2008). *General population census of Cambodia*. Phnom Penh: NIS, Ministry of Planning.

National Institute of Statistics (NIS) (2013). Cambodia inter-censal population survey 2013: Final report. Phnom Penh: NIS, Ministry of Planning.

Phnom Penh Capital (2012). *The Phnom Penh urban poor assessment: A baseline survey on the social and economic situations and capacity of existing services in urban poor communities*. Phnom Penh: Phnom Penh Capital with support of UNICEF and IP3.

Sahmakum Teang Tnaut (STT) (2011). *Displaced families: Phnom Penh 1990-2011- Facts and Figures* (Vol. 19, pp. 1-6). Phnom Penh: STT.

Sahmakum Teang Tnaut (STT) (2012). *A tale of two cities: Review of the development paradigm in Phnom Penh*. Phnom Penh: STT.

Sahmakum Teang Tnaut (STT) (2014). *The Phnom Penh survey: A study on urban poor settlements in Phnom Penh*. Phnom Penh: STT.

Strey Khmer Organization (2013). “*They took my land, they took my life:” A report on the psychosocial impacts of land evictions on women in Cambodia*. Phnom Penh: Strey Khmer Organization.

UN-HABITAT (2012). *State of the world cities, 2010/2011: Bridging the urban divide*. London: Earthscan.

UNOHCHR (2012). *Eviction and resettlement in Cambodia: Human costs, impacts and solutions*. Phnom Penh: UNOHCHR.

Williams, R. (2013). “Title through possession or position? Respect for housing, land, and property rights in Cambodia.” In J. Unruh & R. Williams (Eds.), *Land and post-conflict peacebuilding* (pp. 411-436). London: Earthscan.

World Bank (2009). *Cambodia Land Management and Administration Project enhanced review report*. New York: World Bank.

World Bank Inspection Panel (2010). *Cambodia: Land Management and Administration Project - Investigation report*. New York: World Bank.

World Vision & NGO Forum (2012). *Access to land title in Cambodia: A study of systematic land registration in three Cambodian provinces and the Capital*. Phnom Penh: World Vision and NGO Forum on Cambodia.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ A ៖ ផែនទីនៃទីតាំងសហគមន៍ក្រីក្រនៅទីក្រុងដែលបានជ្រើសរើស



# ឧបសម្ព័ន្ធ ៖ គម្រូងសំណួរ

## គម្រូងសំណួរសម្រាប់សម្ភាសន៍គ្រួសារ

*សម្គាល់ ៖*

- *គ្រួសារមានន័យថាអ្នកទាំងអស់ដែលរស់នៅក្រោមដំបូលផ្ទះតែមួយ*
- *ត្រូវសម្ភាសន៍ប្តី រឺប្រពន្ធដែលជាសមាជិកក្នុងគ្រួសារ*
- *សម្ភាសន៍តែអ្នកដែលជាម្ចាស់ផ្ទះ ( មិនមែនអ្នករស់នៅផ្ទះជួល)*
- *អ្នកចូលរួមចំនួនពាក់កណ្តាលនៃក្នុងសហគមន៍ក្រីក្រនីមួយៗជាស្ត្រី*

ភូមិ_____________ ស.ក _____________ ខ.ណ_____________

ឈ្មោះសហគមន៍_____________ តាំងទីលំនៅឆ្នាំ_____________

**ព័ត៌មានទូទៅ ៖**

ភេទ៖ ប/ស អាយុ_____________ ឆ្នាំ កំរិតវប្បធម៌_____________

ស្ថានភាពអាពាហ៍ពិពាហ៍៖

១.រៀបការ ២.នៅលីវ ៣.មេម៉ាយ/ពោះម៉ាយ ៤.លែងលះ ៥.បែកបាក់/រស់នៅដោយឡែក

**ព័ត៌មានគ្រួសារ ៖**

| ល.រ | សំនួរ | សរុប | ប្រុស |
|---|---|---|---|
| ១ | ចំនួនសមាជិកគ្រួសារ | | |
| ២ | ចំនួនសមាជិកគ្រួសារដែលមានភាពពិការ | | |
| ៣ | ចំនួនសមាជិកគ្រួសារដែលមានជម្ងឺរ៉ាំរ៉ៃ | | |
| ៤ | ចំនួនកូន | | |
| ៥ | ចំនួនកូនដែលកំពុងតែរស់នៅក្នុងបន្ទុក | | |
| ៦ | ចំនួនកូនដែលបានបោះបង់ការសិក្សា | | |
| | a. មូលហេតុនៃការបោះបង់ចោលការសិក្សា | | |

**ជីវភាពរស់នៅ**

៧. អ្នកណាជាអ្នករកប្រាក់ចំណូលធំក្នុងគ្រួសារ ? _________________

៨. ប្រភពចំណូលសំខាន់ៗក្នុងគ្រួសារ (មុខរបរចម្បងៗ)៖

a. មុខរបរចម្បងទី១_____________________________

b. មុខរបរចម្បងទី២ _____________________________

៩. ប្រាក់ចំណូលប្រចាំថ្ងៃរួមជាមធ្យមសម្រាប់គ្រួសារទាំងមូល?

១០. ការចំណាយសំខាន់ៗបីនៅក្នុងគ្រួសារ?

c. ______________________________

d. ______________________________

e. ______________________________

១១. ទ្រព្យសម្បត្តិដែលមានតម្លៃនៅក្នុងគ្រួសារចំនួន៣?

f. ______________________________

g. ______________________________

h. ______________________________

១២. ពេលបច្ចុប្បន្ន តើគ្រួសាររបស់អ្នកមានជំពាក់បំណុលគេទេ? ______

i. បើមាន ប៉ុន្មាន? ______________________________

j. ជំពាក់អ្នកណា?______________________________

k. ជំពាក់ពីពេលណា? ______________________________

l. ដោយសារអ្វី? ______________________________

m. ការប្រាក់មួយខែប៉ុន្មានភាគរយ? __________________

១៣. តើផ្ទះរបស់អ្នកមានភ្ជាប់ប្រព័ន្ធលូ អគ្គិសនី ទឹកស្អាត និងសេវាប្រមូលសំរាមរបស់រដ្ឋដែរឬទេ?

n. បើសិនជាមិនមាន តើហេតុអ្វី?

o. តើបច្ចុប្បន្នអ្នកចំណាយប៉ុន្មានសម្រាប់ទឹក១$m^3$ និងអគ្គិសនី ១kw?

p. អ្នកធ្វើដូចម្ដេចជាមួយនិងសំរាម?

១៤. មុខរបបសំខាន់ៗចំនួន៣ របស់ប្រជាជនក្នុងសហគមន៍?

១៥. តើស្ថានភាពរស់នៅរបស់អ្នកមានភាពខុសផ្លែកគ្នាយ៉ាងណា មុន និងក្រោយពេលដែលគ្រួសារអ្នកមិនត្រូវបានគេឲ្យប្លង់រឹង? ជជីកសួរ

## ការតាំងទីលំនៅ និងសុវត្ថិភាពដីធ្លី

១៦. តើដីប្រភេទណា (ដីរដ្ឋ ដីឯកជន ដីរួម) ដែលគ្រួសារអ្នកកំពុងតាំងទីលំនៅលើ?

a. តើអ្នកដឹងពីប្រភេទដីនោះដោយរបៀបណា?

១៧. តើគ្រួសារអ្នកមានឯកសារបញ្ជាក់ពីកម្មសិទ្ធិ ទៅលើកន្លែងរស់នៅពេលបច្ចុប្បន្ននេះដែរឬទេ?

a. បើមាន ជាឯកសារអ្វី? ________________________

b. បើមិនមាន តើគ្រួសាររបស់អ្នកមកតាំងទីលំនៅ ទីនេះដោយរបៀបណា?

១៨. តើអ្នកមានប្លង់រឹងសម្រាប់កន្លែងដែលអ្នកកំពុងរស់នៅដែររឺទេ? ______

a. បើមាន តាំងពីពេលណាមក និងមានតាមរបៀបណា?

b. បើមិនមាន តើហេតុអ្វី? ________________________

១៩. តើអ្នកមានបានដឹងពីមូលហេតុនានា ដែលគ្រួសារ/សហគមន៍អ្នកត្រូវបានគេកាត់ចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដែរឬទេ?

a. តើគ្រួសារ/សហគមន៍អ្នកត្រូវបានគេកាត់ចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ តាំងពីពេលណាដែរ?

b. តើគ្រួសារ/សហគមន៍អ្នកមានប្រតិកម្មយ៉ាងណាចំពោះការកាត់ចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ?

២០. តើគ្រួសារ/សហគមន៍អ្នកយល់យ៉ាងណាដែរ ចំពោះការកាត់ចេញពីការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធនេះ?

a.តើសហគមន៍/គ្រួសារអ្នកបានធ្វើអ្វីខ្លះ ឬនឹងធ្វើជាការតស៊ូមតិចំពោះការផ្លៀលចេញនេះ?

b. ប្រសិនជាបានធ្វើសកម្មភាព តើមានលទ្ធផលយ៉ាងណាដែរ?

c. តើមានអង្គការ ឬស្ថាប័នណាខ្លះជួយគាំទ្រសកម្មភាពនេះ?

២១. តើប្លង់រឹងវាសំខាន់សម្រាប់គ្រួសាររបស់អ្នកដែររឺទេ? ហេតុអ្វី?

២២. តើការកាត់ចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ មានផលប៉ះពាល់អវិជ្ជមានយ៉ាងណាខ្លះដល់?

a. សហគមន?

b. ខ្លួនអ្នកផ្ទាល់?

c. ប្តីឬប្រពន្ធរបស់អ្នក?

d. កូនៗរបស់អ្នក?

២៣. តើគេមានគម្រោងធ្វើអ្វីជាមួយសហគមន៍នេះ (ជម្លៀសចេញ ធ្វើការអភិវឌ្ឍន៍តំបន់នេះ ឬក៏ ...) ?

a. តើគ្រួសារអ្នកត្រូវបានគេសួរយោបល់ពីផែនការនេះទេ? ជជីកសួរ:

២៤. តើគ្រួសារអ្នកមានបានទទួលការជូនដំណឹងឲ្យចាកចេញពីទីនេះដែរឬទេ?

a. បើសិនជាមាន តើជាការជូនដំណឹងផ្លូវការ ឬក្រៅផ្លូវការ?
b. តាំងពីពេលណាមក ហើយមកពីប្រភពណា?
c. តើគេបានផ្តល់នូវហេតុផលផ្លូវការ និងមិនផ្លូវការយ៉ាងណាដែរ?
d. តើគ្រួសារ/សហគមន៍អ្នកមានប្រតិកម្មយ៉ាងណាដែរ?
e. បើសិនជាអាចមានការជម្លៀសចេញពីទីកន្លែងនេះមែន តើគេចង់ផ្តល់សំណងដល់គ្រួសារអ្នកប៉ុន្មាន?
តើអ្នកយល់យ៉ាងណាចំពោះសំណងនេះ? តើមានសំណងជាពិសេសដល់មេគ្រួសារដែលជាស្ត្រី ឬគ្រួសារជនពិការដែរឬទេ?

២៥. តើមានសង្ឃឹមថានឹងមានថ្ងៃណាមួយ ដែលគ្រួសារអ្នកនឹងទទួលបានប្លង់រឹងដែរឬទេ? មូលហេតុអ្វី?

២៦. តើគ្រួសារអ្នកមានផែនការយ៉ាងណា (បន្តរស់នៅទីនេះ ទៅរស់នៅកន្លែងផ្សេង ឬ...)? ជជីកសួរ

**ដំណោះស្រាយ/អនុសាសន៍**

២៧. តើអ្នកមានការស្នើសុំយ៉ាងណាដល់រដ្ឋាភិបាល ចំពោះការផ្លៀសចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះ?

២៨. តើអាចមានដំណោះស្រាយណាផ្សេងចំពោះការផ្លៀសចេញ?

# កម្រងសំណួរសម្រាប់អ្នកតំណាងសហគមន៍/ប្រធានភូមិ

ភូមិ____________ ស.ក ____________ខ.ណ____________

ភេទ៖ ប/ស តួនាទី ____________តាំងទីលំនៅឆ្នាំ____________

**ព័ត៌មានសហគមន៍**

១. ភាគរយនៃគ្រួសារទូទៅក្នុងភូមិដែលគេដឹងថាមានប្លង់រឹង?

a. ហេតុអ្វីបានជាគ្រួសារផ្សេងមិនទទួលបានប្លង់រឹង?

២. ចំនួនតំបន់នៅក្នុងភូមិដែលត្រូវបានគេចាត់ទុកថាជាសហគមន៍ក្រីក្រ ឬតំបន់អណាធិបតេយ្យ?

| ឈ្មោះ UPC | # HH | # ប្រជាជន | # កុមារ |
|---|---|---|---|
| a. | | | |
| b. | | | |

៣. មូលហេតុដែលគេចាត់ទុកតំបន់ទាំងនោះថាជាសហគមន៍ក្រីក្រ ឬតំបន់អណាធិបតេយ្យ?

៤. តើការចុះបញ្ជីដីធ្លីជាប្រព័ន្ធត្រូវបានគេធ្វើនៅសហគមន៍ក្រីក្រនេះហើយឬនៅ?

a. បើសិនជាបានធ្វើ តើធ្វើនៅពេលណា?

b. តើសហគមន៍ក្រីក្រទាំងអស់ និងគ្រួសារដែលរស់នៅក្នុងសហគមន៍ក្រីក្រទាំងអស់បានទទួលនូវប្លង់រឹងដែរឬទេ? បើសិនជាទេ មូលហេតុ?

c. ប្រសិនជាមិនបានធ្វើ មូលហេតុ?

៥. ភាគរយ ឬចំនួនគ្រួសារនៅក្នុងសហគមន៍ក្រីក្រនីមួយៗ ដែលត្រូវបានគេដកចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ? មូលហេតុ?

៦. សកម្មភាពរកប្រាក់ចំណូលសំខាន់ៗចំនួន៣ របស់គ្រួសារនៅក្នុងសហគមន៍ក្រីក្រ?

៧. កម្រិតជីវភាពទូទៅរបស់គ្រួសារនៅក្នុងសហគមន៍ក្រីក្រ?

៨. សកម្មភាពរកប្រាក់ចំណូលសំខាន់ៗចំនួន៣ របស់គ្រួសារនៅក្នុងសហគមន៍ក្រីក្រដែលត្រូវបានគេផ្ទៀលចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ?

៩. កម្រិតជីវភាពទូទៅរបស់គ្រួសារនៅក្នុងសហគមន៍ក្រីក្រដែលត្រូវបានគេផ្ទៀលចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ?

### ការតាំងទីលំនៅ និងសុវត្ថិភាពដីធ្លី

១០. ភាគរយនៃគ្រួសាររស់នៅក្នុងសហគមន៍ក្រីក្រ ដែលមានឯកសារស្របច្បាប់បញ្ជាក់ពីការតាំងទីលំនៅរបស់ខ្លួន?

១១. ភាគរយនៃគ្រួសារដែលត្រូវបានគេដកចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ ដែលមានឯកសារស្របច្បាប់បញ្ជាក់ពីការតាំងទីលំនៅរបស់ខ្លួន?

១២. តើដីប្រភេទណា (ដីរដ្ឋ ដីឯកជន ដីរួម) ដែលគ្រួសារក្នុងសហគមន៍ក្រីក្រ និងគ្រួសារដែលត្រូវបានគេផ្លៀលចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ កំពុងតាំងទីលំនៅលើ?

១៣. ហេតុអ្វីបានជាសហគមន៍ក្រីក្រ ឬគ្រួសារដែលត្រូវបានគេផ្លៀលចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធមិនត្រូវបានគេដាក់បញ្ចូលក្នុងការចុះបញ្ជីដីធ្លីជាប្រព័ន្ធ? តាំងពីពេលណា?

   a. តើអ្នកបានដឹងដោយរបៀបណា?
   b. តួនាទី និងអំណាចរបស់មេភូមិក្នុងដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធ?

១៤. តើគេមានគម្រោងធ្វើអ្វីជាមួយសហគមន៍ក្រីក្រនេះ (ជម្លៀសចេញ ធ្វើការអភិវឌ្ឍន៍តំបន់នេះ ឬក៏ ...) ?

   a. តើអ្នកឬអ្នកភូមិត្រូវបានគេសួរយោបល់ពីផែនការនេះឬទេ? ជជីកសួរ
   b. តើការផ្លៀលចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ មានផលប៉ះពាល់អវិជ្ជមានយ៉ាងណាខ្លះដល់សហគមន៍?
   c. សហគមន៍ក្រីក្រ
   d. គ្រួសារដែលត្រូវបានគេដកចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ
   e. ស្ត្រី និងកុមារក្នុងសហគមន៍ក្រីក្រ

១៥.តើអ្នក ឬគ្រួសារដែលត្រូវបានគេផ្លៀលចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធបានធ្វើអ្វី ឬនឹងធ្វើអ្វីចំពោះការផ្លៀលចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធនេះ?

   a. បើសិនជាបានចាត់វិធានការណ៍ តើទទួលបានលទ្ធផលយ៉ាងណា?
   b. តើគិតថានឹងទទួលបានលទ្ធផលបែបណា ប្រសិនជាមានចាត់វិធានការដើម្បីទទួលបាននូវការដាក់បញ្ចូលទៅក្នុងការចុះបញ្ជីដីធ្លីជាប្រព័ន្ធ?

**ដំណោះស្រាយ/អនុសាសន៍**

១៦. តើអ្នកមានការស្នើសុំយ៉ាងណាដល់រដ្ឋាភិបាល ចំពោះការផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះ?

១៧. តើក្រុមប្រឹក្សាឃុំ/មេភូមិអាចធ្វើអ្វីបាន ចំពោះគេផ្លៀលចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ?

១៨. តើអាចមានដំណោះស្រាយណាផ្សេងចំពោះការផ្លៀលចេញ?

# សំណួរសម្រាប់ការពិភាក្សាក្រុមជាមួយតំណាងសហគមន៍ក្រីក្រ

ភូមិ______________ ស.ក ______________ ខ.ណ______________

ឈ្មោះសហគមន៍______________ តាំងទីលំនៅពី______________

ចំនួនអ្នកចូលរួម (ចំនួនបុរស )

**ព័ត៌មានសហគមន៍**

១. ភាគរយនៃគ្រួសារទូទៅក្នុងភូមិដែលគេដឹងថាមានប្លង់រឹង? ហេតុអ្វីបានជាគ្រួសារផ្សេងមិនទទួលបានប្លង់រឹង?

២. មូលហេតុដែលគេចាត់ទុកតំបន់ទាំងនោះថាជាសហគមន៍ក្រីក្រនៅទីក្រុង? តើអ្នកយល់យ៉ាងណាចំពោះការធ្វើចំណាត់ថ្នាក់នេះ?

៣. តើការចុះបញ្ជីដីធ្លីជាប្រព័ន្ធត្រូវបានគេធ្វើនៅសហគមន៍នេះហើយឬនៅ?

៤. ភាគរយនៃគ្រួសាររស់នៅក្នុងសហគមន៍ក្រីក្រ ដែលមានឯកសារស្របច្បាប់បញ្ជាក់ពីការតាំងទីលំនៅរបស់ខ្លួន?

៥. តើដីប្រភេទណា (ដីរដ្ឋ ដីឯកជន ដីរួម) ដែលគ្រួសារក្នុងសហគមន៍ក្រីក្រ និងគ្រួសារដែលត្រូវបានគេផ្លៀលចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ កំពុងតាំងទីលំនៅលើ?

៦. ហេតុអ្វីបានជាសហគមន៍ក្រីក្រ ឬគ្រួសារដែលត្រូវបានគេផ្លៀលចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ? ជជីកសួរ

៧. តើគេមានគម្រោងធ្វើអ្វីជាមួយសហគមន៍ក្រីក្រនេះ ឬគ្រួសារដែលត្រូវបានគេផ្លៀលចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ (ជម្លៀសចេញ ធ្វើការអភិវឌ្ឍន៍ តំបន់នេះ ឬក៏ ...) ?

៨. តើការផ្លៀលចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ មានផលប៉ះពាល់អវិជ្ជមានយ៉ាងណាខ្លះដល់សហគមន៍ក្រីក្រ គ្រួសារ ស្ត្រីនិងកុមារក្នុងសហគមន៍?

៩. តើស្ថានភាពរស់នៅរបស់អ្នកមានភាពខុសផ្លែកគ្នាយ៉ាងណា មុន និងក្រោយពេលដែលគ្រួសារអ្នកមិនត្រូវបានគេឲ្យប្លង់រឹង? ជជីកសួរ

១០. តើក្រុមប្រឹក្សាឃុំបាននឹងកំពុងធ្វើ ឬនឹងធ្វើអ្វីចំពោះការផ្លៀលចេញ។

១១. តើគ្រួសារអ្នក/សហគមន៍បាននឹងកំពុងធ្វើអ្វី ឬនឹងធ្វើអ្វីចំពោះការផ្លៀលចេញ

១២. ពិភាក្សាអំពីការជន្លៀសប្រជាជន និងសំណងនានា

**ដំណោះស្រាយ/អនុសាសន៍**

១៣. តើអ្នកមានការស្នើសុំយ៉ាងណាដល់រដ្ឋាភិបាល ចំពោះការផ្លៀលចេញពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះ?

១៤. តើក្រុមប្រឹក្សាឃុំ/អង្គការមិនមែនរដ្ឋាភិបាល អាចធ្វើអ្វីបានចំពោះការផ្លៀលចេញ?

១៥. តើអាចមានដំណោះស្រាយណាផ្សេងចំពោះការផ្លៀលចេញ?

# សំណួរសម្រាប់តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងUN

ភេទ ស/ប ទូរស័ព្ទ___________________

តួនាទី___________________ ស្ថាប័ន___________________

## ការផ្លៀលចេញ

១. តើមានដឹងថាមានផែនទីតំបន់ ឬប្លង់មេដែលបង្ហាញពីតំបន់ ផ្លៀលចេញ ពីមុន បច្ចុប្បន្ន និងអនាគត ដែររឺទេ?

a. តើរដ្ឋាភិបាលអាចមានផែនការយ៉ាងណាដែរចំពោះតំបន់ផ្លៀលចេញ?

២. តើផែនការនោះធ្វើឡើងដោយរបៀបណា?

៣. តើដីប្រភេទណា (ដីរដ្ឋ ដីឯកជន ដីរួម) ដែលគ្រួសារក្នុងសហគមន៍ក្រីក្រ និងគ្រួសារដែលត្រូវបានគេផ្លៀលចេញកំពុងតាំងទីលំនៅលើ?

a. តើការផ្លៀលចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធមានផលប៉ះពាល់អវិជ្ជមានយ៉ាងណាខ្លះដល់សហគមន៍ក្រីក្រ គ្រួសារ ស្ត្រី និងកុមារ ក្នុងសហគមន៍ក្រីក្រ?

៤. តើស្ថាប័នរបស់អ្នកបាននឹងកំពុងតែ ឬនឹងធ្វើអ្វីចំពោះការផ្លៀលចេញនេះ?

៥. ប្រសិនជាបានធ្វើសកម្មភាព តើបានទទួល ឬនឹងបានទទួលលទ្ធផលយ៉ាងណា?

៦. តើមានបញ្ហាចម្បងសំខាន់ៗអ្វីខ្លះទាក់ទិនទៅនឹងការចុះបញ្ជីដីធ្លីជាប្រព័ន្ធជាពិសេសបញ្ហាដែលឈានទៅដល់ការផ្លៀលចេញ?

## ដំណោះស្រាយ/អនុសាសន៍

៧. តើអាចមានដំណោះស្រាយណាផ្សេងដែរឬទេ? តើអ្នកមានការស្នើសុំយ៉ាងណាដល់រដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងឬគ្រួសារ /សហគមន៍ក្រីក្រ ចំពោះការផ្លៀលចេញនេះ?

# សំណួរសម្រាប់ការពិភាក្សាក្រុមជាមួយមន្ត្រីរដ្ឋាភិបាល

ភេទ ស/ប ទូរស័ព្ទ________________

តួនាទី________________ ស្ថាប័ន________________

## ការផ្លៀលចេញ

១. ភាគរយ ឬចំនួនគ្រួសារក្នុងទីក្រុងភ្នំពេញ ឬខ័ណ្ឌដែលមានប្លង់រឹង?

២. ចំនួនសហគមន៍ក្រីក្រ ក្នុងទីក្រុងភ្នំពេញ ឬខ័ណ្ឌដែលគេផ្លៀលចេញ?

៣. ភាគរយ ឬចំនួនសហគមន៍ក្រីក្រដែលកំពុងត្រូវគេផ្លៀលចេញ? មូលហេតុ?

៤. តើមានផែនទីតំបន់ ឬប្លង់មេដែលបង្ហាញពីតំបន់ផ្លៀលសហគមន៍ក្រីក្រចេញពីការចុះបញ្ជីដីធ្លីពីមុន បច្ចុប្បន្ន និងអនាគត ដែររឺទេ?

៥. តើស្ថាប័នណាខ្លះដែលទទួលខុសត្រូវជាចម្បង ក្នុងការកំណត់តំបន់វិនិច្ឆ័យសម្រាប់ការចុះបញ្ជីដីធ្លីជាប្រព័ន្ធ?

៦. តើរដ្ឋាភិបាលអាចមានផែនការយ៉ាងណាដែរចំពោះតំបន់ផ្លៀលចេញ?

a. តើផែនការនោះ ធ្វើឡើងដោយរបៀបណា?

៧. តើដីប្រភេទណា (ដីរដ្ឋ ដីឯកជន ដីរួម) ដែលគ្រួសារក្នុងសហគមន៍ក្រីក្រ និងគ្រួសារដែលត្រូវបានគេផ្លៀលចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ កំពុងតាំងទីលំនៅលើ?

៨. តើការផ្លៀលចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ មានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងណាខ្លះដល់សហគមន៍ក្រីក្រ គ្រួសារ ស្ត្រី និងកុមារ ក្នុងសហគមន៍ក្រីក្រ?

៩. តើស្ថាប័នរបស់អ្នកបាននឹងកំពុងតែ ឬនឹងធ្វើអ្វីដើម្បីចំពោះការផ្លៀលចេញនេះ?

b. ប្រសិនជាបានធ្វើសកម្មភាព តើបានទទួល ឬនឹងបានទទួលលទ្ធផល យ៉ាងណា?

## ដំណោះស្រាយ/អនុសាសន៍

១០. តើអាចមានដំណោះស្រាយណាចំពោះការផ្លៀលចេញ?

១១. តើអ្នកមានការស្នើសុំយ៉ាងណាដល់រដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងឬគ្រួសារ/សហគមន៍ក្រីក្រ ចំពោះការផ្លៀលចេញនេះ?

១២. តើញឹកញាប់ប៉ុណ្ណា ដែលការផ្លៀលចេញឈានទៅដល់ការជន្លៀសប្រជាជនចេញពីតំបន់នោះ? មូលហេតុ? តើមានការគិតគូរជាពិសេសដល់ស្ត្រី និងកុមារដែលឬទេមុនពេលមានការជន្លៀសចេញ? ជជីកសួរ




**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា**

អាសយដ្ឋានៈ ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១ ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រ ២២៩៥ ភ្នំពេញ-៣
ទូរស័ព្ទលេខៈ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខៈ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែលៈ ngoforum@ngoforum.org.kh
គេហទំព័រៈ www.ngoforum.org.kh